មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែធ្នូ ឆ្នាំ ២០១៨

# កំណត់ត្រាសង្ខេបស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស

## ការទប់ស្កាត់ ការកាត់បន្ថយ និងការដោះស្រាយការរំលោភសិទ្ធិនានាពាក់ព័ន្ធនឹង បញ្ហាដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ចំណុចកែលម្អទាំងប្រាំពីរយ៉ាង



## បុព្វកថា

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ពន្ធ ឯករាជ្យដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ចក្ខុវិស័យរបស់ ម.ស.ម.ក. ចង់ឱ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋានប្រកបដោយសមភាព ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យនិងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក ចង់បាននីតិរដ្ឋជាជាងនទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយកនិងសាទរជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញាសម្គាល់របស់ ម.ស.ម.ក រំលេចដោយរូបព្រាបស ហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវ ដែលជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃដៃគូសន្ទនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពក្នុងការបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្មអែសអូអែស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) និងជាសមាជិក OECD-Watch។ គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org របស់ ម.ស.ម.ក បានទទួលជ័យលាភីពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ក្នុងចំណាត់ថ្នាក់ «សិទ្ធិនិងសេរីភាព» និងបានទទួលពានរង្វាន់ខាងទំនាក់ទំនង ដើម្បីផ្លាស់ប្តូរសង្គមប្រចាំឆ្នាំ២០១៣ ពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងនិងការផ្លាស់ប្តូរសង្គមនៅសកលវិទ្យាល័យឃ្វីនស្លេន ក្នុងទីក្រុងប្រីសបែន ប្រទេសអូស្ត្រាលី។

## សេចក្តីថ្លែងអំណរគុណ

កំណត់ត្រាសង្ខេបនេះ អាចធ្វើឡើងទៅបាន ដោយសារមានការឧបត្ថម្ភគាំទ្រពីអង្គការអាក់សិនអេត។ ម.ស.ម.ក ក៏សូមថ្លែងអំណរគុណដល់ដៃគូរបស់យើងផងដែរ គឺអង្គការអាក់សិនអេតកម្ពុជា ដែលបានចូលរួមវិភាគទានក្នុងកិច្ចការនេះ និងមជ្ឈមណ្ឌលស្រាវជ្រាវសាជីវកម្មអន្តរជាតិ (SOMO) ដែលបានរួមចំណែកស្រាវជ្រាវអំពីក្រុមហ៊ុនសាជីវកម្ម។ ទន្ទឹមនឹងនេះ ម.ស.ម.ក ក៏សូមថ្លែងអំណរគុណចំពោះមន្ត្រីរាជរដ្ឋាភិបាលតំណាងអាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ដែលបានចូលរួមក្នុងការឆ្លើយសំណួររបស់ ម.ស.ម.ក ក៏ដូចជាចំពោះតំណាងក្រុមហ៊ុន សុកហ៊្វីន ខេស៊ីឌី សម្រាប់ការចូលរួមផ្តល់ព័ត៌មានក្នុងកិច្ច ស្រាវជ្រាវនេះ។ ជាចុងក្រោយ ម.ស.ម.ក សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកឆ្លើយតបបទសម្ភាសន៍ទាំង ឡាយ ដែលជាមូលដ្ឋានសម្រាប់ចងក្រងកំណត់ត្រាសង្ខេបនេះឡើង។

## សំណួរ និងមតិត្រឡប់

កំណត់ត្រាសង្ខេបនេះ និងការបោះពុម្ពផ្សាយផ្សេងទៀតទាំងអស់របស់ ម.ស.ម.ក មានដាក់នៅលើគេហទំព័រ www.cchrcambodia.org និង www.sithi.org។

ប្រសិនបើលោកអ្នកមានសំណួរ ឬ ត្រូវការព័ត៌មានបន្ថែមអំពីកំណត់ត្រាសង្ខេបនេះ ឬ ប្រសិនបើលោកអ្នកចង់ផ្តល់មតិត្រឡប់ណាមួយ សូមផ្ញើអ៊ីមែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org។

ឬក៏ទូរសព្ទមកលេខ +៨៥៥ (០) ២៣ ៧២ ៦៩ ០១ ឬទាក់ទងមកយើងខ្ញុំតាមរយៈអាសយដ្ឋានផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ឧបត្ថម្ភដោយ

actionaid

cc BY NC SA

# មាតិកា


បុព្វកថា ........ i

អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ........ i

សេចក្តីថ្លែងអំណរគុណ ........ i

សំណួរ និងមតិត្រឡប់ ........ ii

មាតិកា ........ iii

អក្សរកាត់ និងសេចក្តីសម្រង់ខ្លីៗ ........ v

មូលន័យសង្ខេប ........ ១

វិធីសាស្ត្រ ........ ៥

គោលបំណង ........ ៥

ការបង្កើតកម្រងសំណួរ ........ ៦

ការចុះស្រាវជ្រាវដល់មូលដ្ឋាន ........ ៦

ដែនកំណត់ និងបញ្ហាប្រឈម ........ ៧

សេចក្តីផ្តើម ........ ៩

ទិដ្ឋភាពទូទៅនៃករណីទាំងបី ........ ១២

ករណីក្រុមហ៊ុន មីតផ័រ ភូល ........ ១៣

ករណីក្រុមហ៊ុន សុកហ៊ិន ខេស៊ីឌី ........ ១៥

ករណីរបស់ក្រុមហ៊ុន អឹម.ឌី.អេស ........ ២១

របកគំហើញ និងការបកស្រាយ ........ ២៤

របកគំហើញទី១៖សិទ្ធិមានកម្មសិទ្ធិត្រូវតែផ្តល់ជូនដោយសមរម្យ ........ ២៤

របកគំហើញទី២៖ លក្ខខណ្ឌតម្រូវដើម្បីអនុវត្ត និងគោរពការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវដាក់ឱ្យអនុវត្ត និងតាមដាន ........ ២៦

របកគំហើញទី៣៖ត្រូវរៀបការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ រងផលប៉ះពាល់ ........ ៣០

របកគំហើញទី៤៖ការប្រើកម្លាំង និងការតាំងលំនៅថ្មីដោយបង្ខំ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត ........ ៣៣

របកគំហើញទី៥៖សហគមន៍ត្រូវតែទទួលបានការអនុញ្ញាតឱ្យតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគាត់ និងត្រូវទទួលបានការការពារឱ្យបានសមស្រប ............ ៣៥

របកគំហើញទី៦៖ត្រូវមានការខិតខំប្រឹងប្រែង ដើម្បីធានាថាជនរងគ្រោះទទួលបានដំណោះស្រាយទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ............ ៤០

របកគំហើញទី៧៖គួរសម្របសម្រួលឱ្យយន្តការដោះស្រាយវិវាទដីធ្លីផ្សេងៗ និងថ្មីៗទៀត ............ ៥២

សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ ............ ៥៥

អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ............ ៥៦

អនុសាសន៍សម្រាប់សហគមន៍ធុរកិច្ច ............ ៥៧

អនុសាសន៍សម្រាប់អង្គការសង្គមស៊ីវិល ............ ៥៧

## អក្សរកាត់ និងសេចក្តីសម្រង់ខ្លីៗ

| | |
|---|---|
| បណ្តឹងរបស់ពលរដ្ឋប្រឆាំងនឹងក្រុមហ៊ុន មីតផ័រ ភូល ថៃ («មិតផ័រ ភូល») ខែមេសា ឆ្នាំ២០១៨ | «សង្ខេបករណី៖ បណ្តឹងពីពលរដ្ឋកម្ពុជាប្រឆាំងនឹងក្រុមហ៊ុនស្ករមីតផ័រ ភូល» យោងតាមអង្គការអភិវឌ្ឍន៍ដោយមានការចូលរួមអន្តរជាតិថ្ងៃទី២ ខែមេសា ឆ្នាំ ២០១៨ |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក.អ.ក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| សង្គមស៊ីវិល | អង្គការសង្គមស៊ីវិល |
| បទបញ្ញាលេខ 001 | បទបញ្ញាស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច |
| អាយ.ឌី.អាយ | អង្គការអភិវឌ្ឍន៍ដោយមានការចូលរួមអន្តរជាតិ |
| អ៊ី.ស៊ី | អង្គការសមធម៌កម្ពុជា |
| សម្បទានដីសេដ្ឋកិច្ច | សម្បទានដីសេដ្ឋកិច្ច |
| ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| ការវិនិច្ឆ័យលើការជំនុំជម្រះក្តីរបស់ Nanterre ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ | Tribunal de Grande Instance de Nanterre, 6e Chambre ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៧ nº 15/10981 |
| ការយល់ព្រមជាមុន | ការយល់ព្រមដោយពេញចិត្ត ដោយប្រាប់ឱ្យដឹងជាមុននិងទទួលបានព័ត៌មានពេញលេញ |
| អ្នកការពារសិទ្ធិមនុស្ស | អ្នកការពារសិទ្ធិមនុស្ស |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ក.អ.ស.ស.ស.វ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ក.ស.ក | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| របាយការណ៍ស្តីពី រស់ជាតិល្វីងនៃ ស្ករអំពៅ ខែឧសភា ឆ្នាំ២០១៥ | កម្ពុជា៖ «រសជាតិល្វីងនៃស្ករអំពៅ ការចាកចេញដោយបង្ខំចិត្តនិងការដកហូតសិទ្ធិកាន់កាប់សិទ្ធដីធ្លីក្នុងខេត្តឧត្តរមានជ័យ» អង្គការអាក់សិនអេតកម្ពុជានិងអង្គការអុកហ្វាម ខែឧសភា ឆ្នាំ២០១៥ |
| ក្រសួងដែនដី | ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ |
| ក.អ.ជ | ក្រសួងអភិវឌ្ឍន៍ជនបទ |
| អង្គាការមិនមែរដ្ឋាភិបាល | អង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| តំបន់សេដ្ឋកិច្ចពិសេស | តំបន់សេដ្ឋកិច្ចពិសេស |
| ស.ដ.ស.ក | សម្បទានដីសង្គមកិច្ច |
| ការឆ្លើយតបរបស់ សុកហ៊ិន ចំពោះរបាយការណ៍របស់ អេហ្វ.អាយ.ឌី.អេច | «សិទ្ធិរបស់សុកហ៊ិន ក្នុងការឆ្លើយតបចំពោះរបាយការណ៍របស់ អេហ្វ.អាយ.ឌី. អេច» សុកហ៊ិន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១១ |
| អនុក្រឹត្យលេខ ១៩ | អនុក្រឹត្យលេខ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ |
| អនុក្រឹត្យលេខ ៦០ | អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខ ៦០ អន.ក្រ.បក |
| អនុក្រឹត្យលេខ ១៤៦ | អនុក្រឹត្យលេខ ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច |
| អនុក្រឹត្យលេខ ១៤៨ | អនុក្រឹត្យលេខ ១៤៨ ស្តីពីការបង្កើតឡើង និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស |
| ស.ប.ស.ស | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| គោលការណ៍គ្រឹះ និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការបណ្តេញចេញ និងការដកហូតទីជម្រកសម្រាប់ការអភិវឌ្ឍ | 'គោលការណ៍គ្រឹះ និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការដកហូតទីជម្រកសម្រាប់ការអភិវឌ្ឍន៍-អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានគ្រប់គ្រាន់A/HRC/4/18 |
| គោលការណ៍ណែនាំ | គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្សការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា(អូ.អេច.ស៊ី.អេច.អរ) ឆ្នាំ២០១១ |
| មតិទូទៅលេខ ៣១ របស់ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ | មតិទូទៅលេខ ៣១ លក្ខណៈនៃកាតព្វកិច្ចច្បាប់ទូទៅ ដែលកំណត់លើរដ្ឋជាភាគីនៃកតិកាសញ្ញា» *គណៈកម្មាធិការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ* ខែឧសភា ២០០៤ |

## មូលន័យសង្ខេប

យោងតាមធនាគារពិភពលោក ក្នុងរយៈកាលជាងពីរទសវត្សរ៍កន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជាសម្រេច បាននូវ «កំណើនសេដ្ឋកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ»។ ចន្លោះពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤ អត្រាភាពក្រីក្ររបស់កម្ពុជាបានធ្លាក់ចុះពី ៤៧,៨% មកនៅត្រឹមតែ១៣,៥% ដែលជាការសម្រេចលើសទិសដៅកាត់បន្ថយភាពក្រីក្រ ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួនទៅទៀត។ ចាប់តាំងពីឆ្នាំ១៩៩០ មកអត្រាមរណភាពមាតាត្រូវបានកាត់បន្ថយពាក់កណ្តាលហើយការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាជាសកលជិតសម្រេចបានស្ទើរទាំងស្រុងហើយសម្រេចបាននូវវឌ្ឍនភាពជាច្រើនក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍។ ក្នុងរយៈកាលជាង ២០ ឆ្នាំមកនេះ កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ជាមធ្យមគឺ ៧,៦% ហើយត្រូវបានរំពឹងថានឹងបន្តមានកំណើនក្នុងកម្រិត ៧% នៅក្នុងឆ្នាំ២០១៩ ។

ទោះជាយ៉ាងណា ទំនាស់ដីធ្លី នៅតែជាឧបសគ្គមួយក្នុងចំណោមឧបសគ្គដែលត្រូវបានលើកឡើងខ្លាំងជាងគេបំផុត ចំពោះការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា។ គិតត្រឹមខែមីនា ឆ្នាំ២០១៤ ប្រជាពលរដ្ឋជាងកន្លះលាននាក់ ត្រូវបានរាយការណ៍ថាមានជាប់ពាក់ព័ន្ធក្នុងទំនាស់ដីធ្លី។ ចន្លោះពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៤ គ្រាន់តែនៅក្នុងរាជធានីភ្នំពេញតែមួយកន្លែង មានប្រពលរដ្ឋជាង ២៩.៧០០ គ្រួសារ ត្រូវបានរាយការណ៍ថាត្រូវបានបណ្តេញចេញ ឬដកហូតលំនៅដ្ឋានរបស់ពួកគេ។ ការប៉ាន់ប្រមាណបានបង្ហាញថាសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា បានបាត់បង់ដីធ្លីពីបរមបុរាណរបស់ពួកគេចំនួន ៣០% ក្នុងឆ្នាំ២០១៧។

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ដំណោះស្រាយទំនាស់ដីធ្លីគឺជារបៀបវារៈចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល»)។ អាជ្ញាធរសាធារណៈបានចាត់វិធានការមួយចំនួន រួមទាំងការលើកកម្ពស់សុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លី តាមរយៈការចេញប័ណ្ណកម្មសិទ្ធិដីធ្លីការបង្កើតដំណើរការប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច និងការបង្កើតគណៈកម្មាធិការជាច្រើនដើម្បីដោះស្រាយទំនាស់ដីធ្លី។ នៅក្នុងខែធ្នូ ឆ្នាំ២០១៧ ឧបនាយករដ្ឋមន្ត្រី ស ខេង បានសង្កត់ធ្ងន់ទៅលើតម្រូវការឱ្យមានការបែងចែកដីធ្លីប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព ហើយឱ្យពន្លឿនការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីធ្លីថែមទៀតផង។ នៅក្នុងខែសីហា ឆ្នាំ២០១៨ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ («ក្រសួងដែនដី») បានរាយការណ៍ថា បានទទួលបណ្តឹងចំនួន ៩.១៣១ ករណី ដែលពាក់ព័ន្ធទំនាស់ដីធ្លី ដែលក្នុងនោះបណ្តឹងចំនួន ១.៤៥៩ ករណី នៅពុំទាន់បានដោះស្រាយរួចនៅឡើយ។ រដ្ឋាភិបាលកម្ពុជាបានរាយការណ៍ថា បានផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ដល់សហគមន៍ជនជាតិដើមភាគតិចចំនួន ២៤ សហគមន៍ ដែលស្មើនឹងប័ណ្ណកម្មសិទ្ធិចំនួន ៦៦៩ ប័ណ្ណ សម្រាប់ប្រជាពលរដ្ឋចំនួន ២.៣៣៥ គ្រួសារ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះគួរត្រូវបានពង្រឹងបន្ថែមទៀតដើម្បីធានាថាទំនាស់ដីធ្លីត្រូវបានដោះស្រាយបានលឿនប្រកប

ដោយតម្លាភាព និងសមធម៌ អនុលោមតាមកាតព្វកិច្ចរបស់កម្ពុជាឆ្លើយតបនឹងសិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស («គោលការណ៍ណែនាំ»)។

ម.ស.ម.ក បានធ្វើការលើបញ្ហាដីធ្លីក្នុងប្រទេសកម្ពុជា ចាប់តាំងពីខ្លួនត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០២ មកម្ល៉េះ។ ជាផ្នែកមួយនៃគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស ម.ស.ម.ក បានធ្វើការសិក្សាស្រាវជ្រាវដើម្បីវាយតម្លៃលើស្ថានភាពទំនាស់ដីធ្លីនៅក្នុងប្រទេសកម្ពុជា និងផលប៉ះពាល់នៃទំនាស់ដីធ្លីនេះមកលើសិទ្ធិមនុស្ស ដោយផ្តោតលើករណីចំនួនបី។ ដោយមានការសហការជាមួយនឹងអង្គការអាក់សិនអេត ម.ស.ម.ក បានកំណត់យកទំនាស់ដីធ្លីចំនួនបី ដែលប៉ះពាល់ប្រជាពលរដ្ឋជាង ១.៦០០ គ្រួសារ៖

- ទំនាស់ដីធ្លីដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋជាមួយនឹងក្រុមហ៊ុនស្ករស មីតផ័រ ភូល នៅក្នុងសង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ
- ទំនាស់ដីធ្លីពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិច និងក្រុមហ៊ុនចម្ការកៅស៊ូ សុកហ៊្វិន ខេស៊ីឌី នៅក្នុងឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ហើយករណីចុងក្រោយគឺ
- ទំនាស់ដីធ្លីពាក់ព័ន្ធនឹងអ្នកភូមិ និងក្រុមហ៊ុន អ៊ឹម.ឌី.អេស នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសថ្មដា អឹម.ឌី.អេស ស្ថិតក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ក្រោយពីបានធ្វើការពិនិត្យយ៉ាងល្អិតល្អន់ទៅលើច្បាប់ជាតិ និងអន្តរជាតិដែលមានស្រាប់ពាក់ព័ន្ធនឹងទំនាស់ដីធ្លី និងបន្ទាប់ពីបានស្រាវជ្រាវផ្ទាល់នៅមូលដ្ឋានចំនួន ៦ លើក ក្នុងនោះ ម.ស.ម.ក បានសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាល អាជ្ញាធរថ្នាក់ខេត្ត និងមូលដ្ឋាន តំណាងក្រុមហ៊ុន ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងពលរដ្ឋ ដែលរងផលប៉ះពាល់ដោយផ្ទាល់ដោយសារទំនាស់ដីធ្លីទាំងនោះ ម.ស.ម.ក បានរកឃើញចំណុចជាក្តីបារម្ភចំនួនប្រាំពីរ ដែលជាចំណុចស្នូលនៃទំនាស់ពាក់ព័ន្ធនឹងដីធ្លីក្នុងប្រទេសកម្ពុជានិងដែលបានរារាំងដល់ការអភិវឌ្ឍដោយយុត្តិធម៌ ដោយសមធម៌ និងប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេស។ ទោះជាយ៉ាងណា ម.ស.ម.ក ក៏បានរកឃើញដែរនូវវិធានការងាយៗដើម្បីទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយក្តីកង្វល់ទាំងនេះប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់ឱ្យមានដំណើរការដោះស្រាយទំនាស់ដីធ្លី ទូទាំងប្រទេសប្រកបដោយយុត្តិធម៌ តម្លាភាព និងប្រសិទ្ធភាពជាងមុន។

ជាបឋម ការស្រាវជ្រាវរបស់ ម.ស.ម.ក បង្ហាញថា ថ្វីដ្បិតតែមានក្របខ័ណ្ឌច្បាប់ស្តីពីការការពារសិទ្ធិមនុស្ស សិទ្ធិដីធ្លី និងលក្ខខណ្ឌតម្រូវផ្នែកបច្ចេកទេសសម្រាប់ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងសម្បទានដីសេដ្ឋកិច្ចដែលមានភាពរឹងមាំខ្លះក្តី ក៏ប៉ុន្តែ ដំណើរការទាំងនេះមិនត្រូវបានគោរពឱ្យបានពេញលេញនោះទេ។ កិច្ចខិតខំប្រឹងប្រែងក្នុងការវាយតម្លៃ ថាតើសហគមន៍ដែលរងផលប៉ះពាល់ មានសិទ្ធិស្របច្បាប់លើដីដែលរងផលប៉ះពាល់ និងថាតើពួកគេមានសិទ្ធិកាន់កាប់ដីធ្លី ឬប័ណ្ណកម្មសិទ្ធិផ្លូវការយ៉ាងណា ហាក់ដូចជាពុំបានអនុវត្តឱ្យបានពេញលេញនោះទេ។ ជាងនេះទៀត ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម រាប់បញ្ចូលទាំងការពិគ្រោះយោបល់ផងដែរ មិនដែលត្រូវបានធ្វើឡើងជានិច្ចជាកាលនោះទេ ហើយប្រសិនបើបានធ្វើឡើងក៏ការវាយ

តម្លៃនោះគឺគ្រាន់តែសម្រាប់បង្គ្រប់កិច្ចតែប៉ុណ្ណោះ ពោលគឺមិនមែនជាការខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយកម្រិតផលប៉ះពាល់របស់គម្រោងដែលអាចកើតមានលើសហគមន៍មូលដ្ឋាននោះឡើយ។ ជារឿយៗ ប្រជាពលរដ្ឋត្រូវបានគាបសង្កត់ ឬបង្ខំ ឱ្យចុះហត្ថលេខាប្រគល់ដីរបស់ខ្លួនទៅឱ្យអាជ្ញាធរ ឬក្រុមហ៊ុន។ ជារឿងគួរឱ្យសោកស្តាយខ្លាំងណាស់ ដែលមនុស្សជាច្រើនត្រូវបានបណ្តេញចេញដោយបង្ខំនៅក្នុងករណីទាំងបីខាងលើនេះ ដែលជួនកាលមានទាំងអំពើហិង្សាទៀតផង។ ដើម្បីជៀសវាងស្ថានភាពបែបនោះ ជាការសំខាន់ដែលត្រូវមានការពិចារណាសមស្របលើសិទ្ធិមានកម្មសិទ្ធិ (**របកគំហើញទី១**) ដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមត្រូវបានអនុវត្តឡើង មុនពេលចាប់ផ្តើមប្រតិបត្តិការ (**របកគំហើញទី២**) និងមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យមុនពេលមានការអភិវឌ្ឍណាមួយ (**របកគំហើញទី៣**)។ សំខាន់បំផុត ការប្រើប្រាស់កងកម្លាំង និងការតាំងលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តគួរត្រូវមានការហាមប្រាមដាច់ខាត (**របកគំហើញទី៤**)។

ការស្រាវជ្រាវរបស់ ម.ស.ម.ក ក៏បានបង្ហាញដែរថា សហគមន៍ដែលរងផលប៉ះពាល់អវិជ្ជមានពីតំបន់សេដ្ឋកិច្ចពិសេស ឬសម្បទានដីសេដ្ឋកិច្ច ហើយដែលមានបំណងតវ៉ា បានប្រឈមនូវបញ្ហាធ្ងន់ធ្ងរ ដូចជាការគំរាមកំហែងនិងសម្លុត ការចាប់ខ្លួន និងការឃុំខ្លួន ការឃ្លាំមើល និងអំពើហិង្សា។ ដើម្បីជំរុញដំណោះស្រាយដោយយុត្តិធម៌ និងមានប្រសិទ្ធភាពសម្រាប់ទំនាស់ដីធ្លី សំខាន់អាជ្ញាធរត្រូវអនុញ្ញាតឱ្យអ្នកដែលរងផលប៉ះពាល់ទាំងនោះអាចតស៊ូមតិទាមទារសិទ្ធិរបស់ខ្លួនដោយគ្មានការរារាំង (**របកគំហើញទី៥**)។

ចុងក្រោយ ការស្រាវជ្រាវរបស់ ម.ស.ម.ក បានបង្ហាញថា ផលប៉ះពាល់នៃទំនាស់ដីធ្លីមានទំហំលើសពីការបាត់បង់ដីធ្លីទៅទៀត៖ ប្រជាពលរដ្ឋបានបាត់បង់ផ្ទះសម្បែងនិងទ្រព្យសម្បត្តិរាប់បញ្ចូលទាំងឯកសាររដ្ឋបាលសំខាន់នានាជាច្រើន សហគមន៍ជនជាតិដើមភាគតិចបាត់បង់ប្រពៃណីរបស់ខ្លួន និងមិនអាចចូលទៅទីសក្ការៈបូជា និងប្រជាពលរដ្ឋលែងមានសមត្ថភាពទ្រទ្រង់ជីវភាពខ្លួនឯងហើយកុមារវិញត្រូវឈប់រៀនដោយសារតែការផ្លាស់ទីលំនៅ សមាជិកក្រុមគ្រួសារត្រូវបានចាប់ដាក់ពន្ធនាគារ មានមនុស្សជាច្រើនបានធ្លាក់ខ្លួនជំពាក់បំណុលគេ។ ថ្វីដ្បិតតែមានផលប៉ះពាល់ច្រើនបែបនេះក្តី ករណីទំនាស់ដីធ្លីទាំងបីនេះបានកើតឡើងជាងមួយទសវត្សរ៍មកហើយ ហើយទោះបីជាមានការព្យាយាមជាច្រើនលើកពីសំណាក់អាជ្ញាធរ ក្នុងគោលបំណងដោះស្រាយទំនាស់ដីធ្លីនោះក៏ដោយ ក៏មនុស្សភាគច្រើនដែល ម.ស.ម.ក បានសម្ភាសបានរាយការណ៍ថា ពួកគេមិនមានអារម្មណ៍ថាមានសេរីភាពក្នុងការទទួលយកដំណោះស្រាយដែលបានស្នើឡើងនោះទេ តែផ្ទុយមកវិញ ពួកគេមានអារម្មណ៍ថា ពួកគេគ្មានជម្រើសអ្វីផ្សេងក្រៅតែពីការព្រមទទួលយកនោះឡើយ។ និយាយដោយខ្លី ដំណោះស្រាយទំនាស់ដែលបានស្នើឡើងសម្រាប់ករណីទាំងបីនោះ គឺមិនត្រឹមតែមិនបានដោះស្រាយឱ្យបានពេញលេញចំពោះការរំលោភបំពានដែលពួកគេទទួលរងប៉ុណ្ណោះទេ ប៉ុន្តែក៏មិនបានគោរពតាមបទដ្ឋានអន្តរជាតិផងដែរ។ ជាលទ្ធផល ត្រូវមានការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាឱ្យមានដំណោះស្រាយទាន់ពេលវេលា និងមានប្រសិទ្ធភាពសម្រាប់គ្រប់ជនរងគ្រោះទាំងអស់ (**របកគំហើញទី៦**) និងគួរសម្របសម្រួលឱ្យអាចទទួលនូវដំណើរការដោះស្រាយទំនាស់ដែលមានជម្រើសផ្សេងទៀតនិងប្រកបដោយភាពច្នៃប្រឌិត (**របកគំហើញទី៧**)។

កំណត់ត្រាសង្ខេបនេះនឹងបញ្ចប់ដោយមាន**អនុសាសន៍ចំនួន១៥** សម្រាប់រដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនឯកជនដែលមានប្រតិបត្តិការក្នុងប្រទេសកម្ពុជា និងអង្គការសង្គមស៊ីវិលនានាអនុវត្ត ដោយបានដាក់ចេញនូវវិធានការសោមញ្ញ ដែលត្រូវអនុវត្តក្នុងបំណងទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយបញ្ហាសិទ្ធិមនុស្សដែលកើតចេញពីសកម្មភាពធុរកិច្ចនៅក្នុងប្រទេសកម្ពុជា។

អនុសាសន៍សំខាន់ៗរួមមានដូចខាងក្រោមៈ

- គោរពទស្សនទាននៃការយល់ព្រមដោយពេញចិត្ត ដោយប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញរបស់សហគមន៍ ដែលរងផលប៉ះពាល់ពាក់ព័ន្ធនឹងការប្រគល់ដីធ្លី ឬការទទួលយកដំណោះស្រាយណាមួយ
- អនុវត្ត គោរព និងពិនិត្យតាមដានលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ផ្តល់ដំណោះស្រាយទាន់ពេលវេលា និងមានប្រសិទ្ធភាព
- បញ្ឈប់ការតាមដាន ការបៀតបៀន និងការដាក់ទោសទណ្ឌទៅលើអ្នកការពារសិទ្ធិមនុស្ស
- ត្រូវធ្វើការត្រួតពិនិត្យដ៏ត្រឹមត្រូវដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស
- សម្រាប់អង្គការសង្គមស៊ីវិលវិញ គួរបន្តពិនិត្យតាមដានលើទំនាស់ដីធ្លី ហើយជំរុញឱ្យមានការសន្ទនាជាមួយនឹងរដ្ឋាភិបាលកម្ពុជា និងតួអង្គសាជីវកម្ម ដើម្បីជំរុញការគោរពតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស («សេចក្តីណែនាំ»)។

## វិធីសាស្ត្រ

កំណត់ត្រាសង្ខេបនេះគឺជាផ្នែកមួយនៃគម្រោង «ពង្រឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្សពីសំណាក់ក្រុមហ៊ុនសាជីវកម្មក្នុងវិស័យដីធ្លី» ដែលអនុវត្តដោយ ម.ស.ម.ក និងអង្គការអាក់សិនអេតកម្ពុជា។ គម្រោងនេះមានបំណងលើកកម្ពស់ការប្រតិបត្តិរបស់ក្រុមហ៊ុនតាមរយៈការតស៊ូមតិ ឱ្យអាជ្ញាធរត្រួតពិនិត្យលើការប្រតិបត្តិរបស់ក្រុមហ៊ុន តាមរយៈការគាំទ្រដល់សិទ្ធិរបស់សហគមន៍ និងការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ ព្រមទាំងតាមរយៈការបង្កលក្ខណៈឱ្យមានសុវត្ថិភាពសម្រាប់សង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស បង្កើតកិច្ចសន្ទនា និងកិច្ចសហការរវាងរដ្ឋាភិបាល តួអង្គសាជីវកម្ម សហគមន៍មូលដ្ឋាននិងអង្គការសង្គមស៊ីវិល ក៏ដូចជាធ្វើឱ្យលេចចេញជារូបរាងនូវការអនុវត្តតាមបទដ្ឋានធុរកិច្ច និងសិទ្ធិមនុស្សនៅក្នុងវិស័យដីធ្លីផងដែរ។ ខ្លឹមសារទាំងស្រុងនៃរបាយការណ៍នេះគឺជាការទទួលខុសត្រូវរបស់ម.ស.ម.ក ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកចូលរួមក្នុងរបាយការណ៍នោះទេ។

## គោលបំណង

គោលបំណងនៃកំណត់ត្រាសង្ខេបនេះ គឺដើម្បីកំណត់រកឱ្យឃើញនូវបញ្ហាសំខាន់ៗដែលទាក់ទងនឹងសិទ្ធិមនុស្សក្នុងវិស័យធុរកិច្ចនៅក្នុងប្រទេសកម្ពុជា តាមរយៈការវិភាគលើទំនាស់ពាក់ព័ន្ធនឹងដីធ្លីចំនួនបីករណី និងដើម្បីស្នើជាអនុសាសន៍ក្នុងគោលបំណងទប់ស្កាត់ និងដោះស្រាយការរំលោភបំពានសិទ្ធិមនុស្សពាក់ព័ន្ធនឹងដីធ្លី។ ម.ស.ម.ក សហការជាមួយអង្គការអាក់សិនអេតកម្ពុជា បានជ្រើសរើសករណីចំនួនបីដើម្បីឆ្លុះបញ្ចាំងៈ ពោលគឺទំនាស់ដីធ្លីពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិចជាមួយនឹងក្រុមហ៊ុនចម្ការកៅស៊ូ សុកហ៊ុីន ខេស៊ីឌី នៅក្នុងឃុំ ប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី («ករណីក្រុមហ៊ុន សុកហ៊ុីន ខេស៊ីឌី ») ករណីមួយទៀតគឺពាក់ព័ន្ធនឹងប្រជាពលរដ្ឋ និងក្រុមហ៊ុនស្ករស មីតផ័រ ភូល ក្នុងសង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ («ករណីក្រុមហ៊ុន មីតផ័រ ភូល») និងចុងក្រោយគឺទំនាស់ដីធ្លីពាក់ព័ន្ធនឹងប្រជាពលរដ្ឋ និងក្រុមហ៊ុន អឹម.ឌី.អេស ក្នុងតំបន់សេដ្ឋកិច្ចពិសេសថ្មដា អ៊ឹម.ឌី.អេស ស្ថិតនៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ («ករណីក្រុមហ៊ុន អឹម.ឌី.អេស»)។ កំណត់ត្រាសង្ខេបនេះគឺផ្អែកលើការពិនិត្យមើលឯកសារ និងការស្រាវជ្រាវដល់កន្លែងចាប់តាំងពីខែមករា ឆ្នាំ២០១៧។ ក្រុមការងាររបស់ ម.ស.ម.ក បានចុះស្រាវស្រាវដល់កន្លែងចំនួនប្រាំមួយលើកចាប់ពីខែមីនា និងខែឧសភា ឆ្នាំ២០១៧ និងចន្លោះពី ខែឧសភា និងខែមិថុនា ឆ្នាំ ២០១៨ ហើយបានជួបជាមួយនឹងអង្គការសង្គមស៊ីវិលដែលធ្វើការលើករណីទាំងបីនេះ។ បន្ថែមលើនេះទៅ ទៀត ម.ស. ម.ក បានធ្វើការស្រាវជ្រាវឯកសារយ៉ាងស៊ីជម្រៅដើម្បីកំណត់រកបទដ្ឋានច្បាប់ដែលអាចអនុវត្តបានពិនិត្យតាមដានការវិវត្តន៍ផ្សេងៗពាក់ព័ន្ធនឹងករណីទំនាស់ ហើយនិងបានកំណត់រកចេនាសម្ព័ន្ធលម្អិតចំពោះក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងទំនាស់ទាំងនោះ។

## ការបង្កើតកម្រងសំណួរ

នៅឆ្នាំ ២០១៧ ម.ស.ម.ក បានរៀបចំកម្រងសំណួរដែលត្រូវប្រើសម្រាប់ការសម្ភាសអំឡុងពេលចុះស្រាវជ្រាវដល់កន្លែង ដោយគ្របដណ្តប់លើប្រធានបទចំនួនប្រាំមួយ៖ (ក) សាវតារ (ខ) ព័ត៌មាន (គ) ការពិគ្រោះយោបល់ និងទទួលព័ត៌មាន (ឃ) ការពិនិត្យដ៏ត្រឹមត្រូវសង្វាក់តម្លៃ និងវិនិយោគិន (ង) អនុលោមភាពផ្លូវច្បាប់ (ច) ការធានាឱ្យមានការគោរពសិទ្ធិមនុស្ស និង (ឆ) អំពីដំណោះស្រាយ។ សំណួរទាំងនោះត្រូវបានរៀបចំឡើងសម្រាប់សមាជិកសហគមន៍ អង្គការសង្គមស៊ីវិល តំណាងក្រុមហ៊ុន និងអាជ្ញាធរ។ នៅឆ្នាំ២០១៨ ម.ស.ម.ក បានបង្កើតកម្រងសំណួរតាមដាន៖ សម្រាប់អាជ្ញាធរ សហគមន៍ដែលរងផលប៉ះពាល់អង្គការសង្គមស៊ីវិល ដែលធ្វើការទៅលើករណីទាំងនោះ និងសម្រាប់ក្រុមហ៊ុន។ កម្រងសំណួរនីមួយៗត្រូវបានចងក្រងឡើង និងកែសម្រួលជាក់លាក់ទៅតាមករណីនីមួយៗ។ កម្រងសំណួរទាំងនោះគ្របដណ្តប់លើប្រធានបទចំនួន ១០ ដូចជា (ក) សិទ្ធិមានកម្មសិទ្ធិ (ខ) ការប្រើប្រាស់ដីធ្លីដែលមានទំនាស់ (គ) ទំនាក់ទំនងរវាងអាជ្ញាធរ/ក្រុមហ៊ុន/សហគមន៍ (ឃ) ការបង្ខំ/គំរាម/សម្លុតទៅលើសហគមន៍ (ង) ដំណើរការកំពុងបន្តនៃដំណោះស្រាយទំនាស់ (ច) ដំណើរការដោះស្រាយទំនាស់កំពុងបន្ត (ឆ) ផលប៉ះពាល់របស់ទំនាស់ (ជ) ឧបសគ្គដែលកើតមាន (ឈ) (សម្រាប់ក្រុមហ៊ុន) គោលនយោបាយផ្ទៃក្នុង (ញ) (សម្រាប់អាជ្ញាធរសាធារណៈ) ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ នៅពេលដែលការសម្ភាសធ្វើឡើងរួចរាល់ហើយ លទ្ធផលនៃបទសម្ភាសត្រូវបានអានឱ្យអ្នកផ្តល់បទសម្ភាសបានស្តាប់ឡើងវិញ ដែលជាការផ្តល់ឱកាសក្នុងការកែតម្រូវ ឬបំភ្លឺបន្ថែមចំពោះព័ត៌មានណាមួយ។

## ការចុះស្រាវជ្រាវដល់មូលដ្ឋាន

ចន្លោះពីថ្ងៃ ២៧-៣១ មីនា ឆ្នាំ២០១៧ ក្រុមការងារគម្រោងធុរកិច្ច និងសិទ្ធិមនុស្សរបស់ ម.ស.ម.ក បានធ្វើដំណើរទៅកាន់ខេត្តមណ្ឌលគិរី ហើយបានសម្ភាសប្រជាពលរដ្ឋ ២៣ នាក់ តំណាងក្រុមហ៊ុន សុកហ៊ិន ខេស៊ីឌី អង្គការសង្គមស៊ីវិលនៅមូលដ្ឋាន ក៏ដូចជាអាជ្ញាធរមូលដ្ឋាន និងថ្នាក់ខេត្តផងដែរ។ ចាប់ពីថ្ងៃទី ២៤-២៦ ខែមេសា ឆ្នាំ២០១៧ ក្រុមការងាររបស់ ម.ស.ម.ក បានធ្វើដំណើរទៅកាន់ខេត្តឧត្តរមានជ័យ។ ក្រុមការងារបានសម្ភាសជាមួយនឹងមនុស្ស ២៣ នាក់ ដែលរងផលប៉ះពាល់ពីទំនាស់ដីធ្លីនោះ ជាមួយអង្គការសង្គមស៊ីវិលមូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន និងថ្នាក់ខេត្ត។ ក្រុមការងារពុំបានជួបជាមួយនឹងតំណាងរបស់ក្រុមហ៊ុន មីតផ័រ ភូលឡើយ ពីព្រោះក្រុមហ៊ុននេះបានចាកចេញពីប្រទេសកម្ពុជាកាលពីឆ្នាំ២០១៥។ ចាប់ពីថ្ងៃទី ២៧ ខែមេសា ដល់ថ្ងៃទី ១ ខែឧសភា ឆ្នាំ២០១៧ ក្រុមការងាររបស់ ម.ស.ម.ក បានធ្វើដំណើរទៅខេត្តពោធិ៍សាត់ហើយបានសម្ភាសន៍ជាមួយនឹងប្រជាពលរដ្ឋរងផលប៉ះពាល់ចំនួន ១៦ គ្រួសារ អង្គការមិនមែនរដ្ឋាភិបាលមួយ និងអាជ្ញាធរ

សាធារណៈចំនួន ៥ រូប។ ថ្វីដ្បិតតែការដាក់លិខិត និងការហៅតាមទូរសព្ទ ដើម្បីស្នើសុំជួបជាមួយ នឹងក្រុមហ៊ុន មិនបានលទ្ធផលជាវិជ្ជមានក្តី ប៉ុន្តែក្រុមការងាររបស់ ម.ស.ម.ក បានចុះទៅដល់ទីតាំងរបស់ក្រុមហ៊ុន អឹម.ឌី.អេស នៅក្នុងឃុំថ្មដាតែម្តង។ ទោះជាយ៉ាងណាបុគ្គលដែលក្រុមការងារបានជួបបានបដិសេធផ្តល់ការសម្ភាស ដោយលើកហេតុផលថា គាត់ពុំអាចមានសិទ្ធិក្នុងការនិយាយស្តីក្នុងនាមជាតំណាងរបស់ក្រុមហ៊ុន អឹម.ឌី.អេស បានឡើយ។

នៅខែឧសភា និងមិថុនា ឆ្នាំ២០១៨ ម.ស.ម.ក បានចុះស្រាវជ្រាវទៅកាន់ទីតាំងទាំងបី។ ចន្លោះពីថ្ងៃទី៦ ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារបានចុះទៅខេត្តពោធិ៍សាត់ ហើយបានជួបជាមួយនឹងសមាជិកចំនួន ១០ នាក់ មកពីសហគមន៍ដែលរងផលប៉ះពាល់ អង្គការមិនមែនរដ្ឋាភិបាលមួយ និងអាជ្ញាធរខេត្តចំនួន ១៨រូប។ ចន្លោះពីថ្ងៃទី ៣ ដល់ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងាររបស់ ម.ស.ម.ក បានទៅកាន់ខេត្តឧត្តរមានជ័យ។ ក្រុមការងារបានជួបជាមួយនឹងបុគ្គលចំនួន ២៤ រូប មកពីសហគមន៍ដែលរងផលប៉ះពាល់ អង្គការមិនមែនរដ្ឋាភិបាលមួយ និងអាជ្ញាធរសាធារណៈចំនួន ១២ រូប។ ក្រុមការងារពុំបានជួបជាមួយ នឹងតំណាងរបស់ក្រុមហ៊ុន មីតជ័រ កូល ឡើយ ពីព្រោះក្រុមហ៊ុននេះបានចាកចេញពីប្រទេសកម្ពុជាកាលពីឆ្នាំ២០១៥។ បន្ថែមលើនេះទៅទៀត នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ តំណាង ម.ស.ម.ក និង អាក់សិនអេតកម្ពុជា បានចូលរួមនៅក្នុងអង្គប្រជុំមួយនៅសាលាខេត្ត ដែលមានការចូលរួមពីអាជ្ញាធរសាធារណៈចំនួន ១៤ រូប។ ចុងបញ្ចប់ចន្លោះពីថ្ងៃទី០៧ ដល់ទី០៩ ខែមិថុនា ឆ្នាំ២០១៨ ម.ស.ម.ក បានទៅកាន់ខេត្តមណ្ឌលគិរី ហើយបានជួបជាមួយនឹងប្រជាពលរដ្ឋ ១៥ នាក់ ដែលរងផលប៉ះពាល់ និងអាជ្ញាធរសាធារណៈចំនួន ៤ រូប ។ ចំណែកក្រុមហ៊ុន សុកហ៊្វិន ខេស៊ីឌី បានបដិសេធជួបជាមួយនឹង ម.ស.ម.ក ដោយសារដំណើរការសម្រុះសម្រួលជាសម្ងាត់កំពុងប្រព្រឹត្តទៅ។ អង្គការសង្គមស៊ីវិលដែល ម.ស.ម.ក ស្នើសុំជួបបានបដិសេធឆ្លើយតបសំណួរផងដែរ។ នៅខែកញ្ញា ឆ្នាំ២០១៨ ម.ស.ម.ក ក៏បានជួបជាមួយនឹងតំណាងការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា («អូ.អេច.ស៊ី.អេច.អរ») ដើម្បីពិភាក្សាលើករណីក្រុមហ៊ុន សុកហ៊្វិន ខេស៊ីឌី ផងដែរ។

ម.ស.ម.ក បានសម្រេចថា នឹងមិនបញ្ចេញព័ត៌មានអំពីឈ្មោះ ឬតួនាទីរបស់បុគ្គលដែលខ្លួនបានសម្ភាសឡើយ ដើម្បីចៀសវាងផលវិបាកអវិជ្ជមានណាមួយកើតឡើង។ ប្រសិនបើពុំមានការបញ្ជាក់អ្វីផ្សេងទេនោះ មានន័យថាព័ត៌មាននៅក្នុងរបាយការណ៍នេះគឺផ្អែកលើការសម្ភាសន៍របស់ ម.ស.ម.ក ទាំងស្រុង។

## ដែនកំណត់ និងបញ្ហាប្រឈម

ម.ស.ម.ក ជួបប្រទះនូវកត្តាប្រឈមមួយចំនួនក្នុងការសិក្សាស្រាវជ្រាវនេះ។ ទីមួយ ម.ស.ម.ក មិនអាចជួបនឹងភាគីពាក់ព័ន្ធសំខាន់ៗ។ ក្រៅពីក្រុមហ៊ុន សុកហ៊្វិន ខេស៊ីឌី ពុំមានក្រុមហ៊ុនណាមួយបានឆ្លើយតបដោយវិជ្ជមានចំពោះសំណើសុំជួបរបស់ ម.ស.ម.ក ឡើយ។ ស្រដៀងគ្នានេះដែរ អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់

ខេត្តមួយចំនួនបានបដិសេធជួបជាមួយនឹងក្រុមការងារគម្រោង។ ជាងនេះទៅទៀត ថ្វីដ្បិតមានការព្យាយាមម្តងហើយម្តងទៀតគ្រប់មធ្យោបាយទាំងអស់ក្តី ម.ស.ម.ក មិនអាចជួបជាមួយ នឹងតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នទទួលខុសត្រូវលើតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា និងលើ «ការគ្រប់គ្រងការសម្របសម្រួល និងទំនាក់ទំនងអង្គការមិនមែនរដ្ឋាភិបាល» បានឡើយ។[1] ទីពីរ នៅពេលសម្ភាសសហគមន៍ដែលរងផលប៉ះពាល់កាលពីខែឧសភា និងខែមិថុនា ឆ្នាំ២០១៨ កិច្ចប្រជុំរបស់ ម.ស.ម.ក ត្រូវបានតាមដាន និងរំខានដោយអាជ្ញាធរមូលដ្ឋាន ដែលបានចោទថា ម.ស.ម.ក ពុំមានការអនុញ្ញាតពីអភិបាលខេត្ត បើទោះបីជាការអនុញ្ញាតបែបនេះមិនមែនជាការតម្រូវដោយច្បាប់ក្តី[2] ហើយបើទោះបីជា ម.ស.ម.ក បានផ្ញើលិខិតផ្លូវការទៅកាន់អាជ្ញាធរពាក់ព័ន្ធ ដោយបានស្នើសុំជួបមុនពេលចុះបេសកកម្មដល់កន្លែងបែបនេះក្តី។ ជាចុងក្រោយនៅតាមទីកន្លែងខ្លះ អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ខេត្ត បានទូរសព្ទទៅតំណាងសហគមន៍ និងប្រាប់ពួកគេកុំឱ្យជួបជាមួយនឹង ម.ស.ម.ក។

ដូច្នេះ កំណត់ត្រាសង្ខេបបច្ចុប្បន្ននេះ ត្រូវបានបញ្ជាក់ជាទិដ្ឋភាពជាក់ស្តែងចំពោះការដែល ម.ស.ម.ក មិនអាចសុំមតិពីក្រុមហ៊ុនពីរក្នុងចំណោមក្រុមហ៊ុនទាំងបីដែលពាក់ព័ន្ធនឹងករណីសិក្សាទាំងបី និងទស្សនៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ឯកសារនេះ មិនបានបញ្ចូលទស្សនៈរបស់ពួកគេទៅលើបញ្ហាដែលបានពិភាក្សានេះឡើយ លុះត្រាតែទស្សនៈទាំងនោះមានជាសាធារណៈ ឧទាហរណ៍ ដូចជានៅក្នុងសារព័ត៌មានជាដើម។

---

[1] អនុក្រឹត្យលេខ ៦០ ស្តីពីការរៀបចំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ថ្ងៃទី ២៧ មេសា ២០១៦ មាត្រា ៤ (៧) ១០ (៣) http://www.cambodiainvestment.gov.kh/sub-decree-60-on-the-organization-and-functioning-of-the-cdc-05042016.html.

[2] "នៅខែតុលា ២០១៨ ក្រសួងមហាផ្ទៃបានចេញគោលការណ៍ណែនាំ ថា ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ធ្វើសកម្មភាពនៅក្នុងខេត្តមួយក្រៅពីទីកន្លែងដែលខ្លួនបានចុះបញ្ជី នោះត្រូវជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានឱ្យបាន ៥ ថ្ងៃជាមុន។ នៅតាមបណ្តាខេត្តមួយចំនួន គោលការណ៍ណែនាំនេះត្រូវបានបកស្រាយថាជាសេចក្តីបង្គាប់ ដែលមានន័យថា សកម្មភាពណាមួយត្រូវតែតម្រូវឱ្យមានការអនុម័តយល់ព្រមពីសំណាក់អាជ្ញាធរថ្នាក់ខេត្ត។ ការធ្វើដូច្នេះគឺផ្ទុយនឹងច្បាប់សិទ្ធិមនុស្ស ។ *សូមមើល* "ការពិនិត្យតាមដានច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលៈ កម្ពុជា" ICNL, មិថុនា ២០១៦ http://www.icnl.org/research/monitor/cambodia.html។

## សេចក្តីផ្តើម

ក្នុងរយៈកាលប៉ុន្មានទសវត្សរ៍ថ្មីៗនេះ កម្ពុជាបានឆ្លងកាត់ការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងលឿន។ នៅចន្លោះពីឆ្នាំ ២០០៧ និងឆ្នាំ ២០១៤ អត្រាភាពក្រីក្របានធ្លាក់ពី ៤៧,៨% មកនៅត្រឹម ១៣,៥%[3] ដែលជាការសម្រេចលើសទិសដៅកាត់បន្ថយភាពក្រីក្រ[4] ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួនទៅទៀត។ ចាប់តាំងពីឆ្នាំ ១៩៩០ អត្រាមរណភាពមាតាត្រូវបានកាត់បន្ថយបានពាក់កណ្តាល ការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាជាសកលជិតសម្រេចបានស្ទើរទាំងស្រុងហើយសម្រេចបាននូវវឌ្ឍនភាពច្រើនក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគ/ជំងឺអេដស៍ ដែលធ្វើឱ្យកម្ពុជាក្លាយជា «ប្រទេសនាំមុខក្នុងពិភពលោកក្នុងការកាត់បន្ថយភាពក្រីក្រ»។[5] យោងតាមធនាគារពិភពលោក[6] ប្រទេសកម្ពុជាសម្រេចបាននូវ «កំណើនសេដ្ឋកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ» ដោយក្នុងរយៈកាលជាង ២០ ឆ្នាំមកនេះ កំណើនសេដ្ឋកិច្ច ជាមធ្យមគឺមានកម្រិត ៧,៦%។ កំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានរំពឹងថានឹងបន្តកើនឡើងទៀត និងមានកំណើនក្នុងកម្រិត ៧% ក្នុងឆ្នាំ២០១៩ នេះ។[7]

ទោះយ៉ាងណា បញ្ហាទំនាស់ដីធ្លី នៅតែជាឧបសគ្គមួយក្នុងចំណោមឧបសគ្គដែលត្រូវបានលើកឡើងខ្លាំងជាងគេបំផុត ចំពោះការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា។[8] ក្នុងរយៈកាលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះមានមនុស្សជាច្រើនបានរងផលប៉ះពាល់អវិជ្ជមានពីទំនាស់ដីធ្លីទាំងនេះ។ គិតត្រឹមខែមីនា ឆ្នាំ២០១៤ ប្រជាពលរដ្ឋជាងកន្លះលាននាក់ ត្រូវបានរាយការណ៍ថាមានជាប់ពាក់ព័ន្ធក្នុងទំនាស់ដីធ្លី។[9] ចន្លោះពីឆ្នាំ១៩៩០ ដល់

---

[3] "កម្ពុជា៖ ការទ្រទ្រង់កំណើនរឹងមាំដើម្បីជាប្រយោជន៍សម្រាប់ទាំងអស់គ្នា" *ធនាគារពិភពលោក* ថ្ងៃទី ១៦ សីហា ២០១៧ http://www.worldbank.org/en/country/cambodia/publication/Cambodia-Systematic-Country-Diagnostics.

[4] "គោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា - CDC/CRDB", *រាជរដ្ឋាភិបាលកម្ពុជា* ខែមិថុនា ២០១៨ ទំព័រ viii, ទិសដៅរួមទី ១, http://www.cdc-crdb.gov.kh/cdc/cmdgs_en.pdf.

[5] "ពេលនេះ កម្ពុជាជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប៖ តើមានន័យយ៉ាងដូចម្តេច?", *លី សុវេត* ថ្ងៃទី ១១ មេសា ២០១៦ http://blogs.worldbank.org/eastasiapacific/cambodia-is-now-a-lower-middle-income-economy-what-does-this-mean.

[6] "កម្ពុជា រក្សាកំណើនរឹងមាំសម្រាប់អត្ថប្រយោជន៍ទាំងអស់គ្នាការវិភាគប្រទេសជាលក្ខណៈប្រព័ន្ធ" ធនាគារពិភពលោក ខែឧសភា ឆ្នាំ2017 ទំព័រ 100 https://openknowledge.worldbank.org/bitstream/handle/10986/27149/Cambodia-SCD-May-9-SEPCO-05242017.pdf?sequence=5&isAllowed=y ("របាយការណ៍ធនគារពិភពលោក ឆ្នាំ2017 ស្តីពីកម្ពុជា")។.

[7] " កម្ពុជា: សេដ្ឋកិច្ច", ធនាគារអភិវឌ្ឍន៍អាស៊ី, https://www.adb.org/countries/cambodia/economy តាមរយៈការប្រៀបធៀប, គម្រោងកំណើនសេដ្ឋកិច្ចនៅបារាំងចំនួន ១,៥% សម្រាប់ឆ្នាំ២០១៩ និង ២០២០ (http://www.oecd.org/economy/france-economic-forecast-summary.htm), កំណើនសេដ្ឋកិច្ចជប៉ុន ១% (http://www.oecd.org/eco/outlook/japan-economic-forecast-summary.htm) និងនៅកូរ៉េខាងត្បូង ចំនួន ៣% (http://www.oecd.org/eco/outlook/korea-economic-forecast-summary.htm).

[8] "*សូមមើលឧទាហរណ៍* កម្ពុជា៖ *រក្សាកំណើនរឹងមាំសម្រាប់អត្ថប្រយោជន៍ទាំងអស់គ្នាធនាគារពិភពលោក* ថ្ងៃទី ១៦ ខែសីហា ២០១៧ ទំព័រ៩៩ http://www.worldbank.org/en/country/cambodia/publication/Cambodia-Systematic-Country-Diagnostics; "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា", *Rhona Smith*, UN Doc A/HRC/39/73, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ កថាខ័ណ្ឌទី ៥៦, https://undocs.org/A/HRC/39/73.

[9] "ឆ្នាំ២០១៤ នាំមកនូវរលកថ្មីនៃជម្លោះដីធ្លីនៅកម្ពុជា", *អង្គការលីកាដូ* ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=342.

ឆ្នាំ២០១៤ គ្រាន់តែនៅក្នុងរាជធានីភ្នំពេញតែមួយកន្លែង មានប្រជាពលរដ្ឋជាង ២៩.៧០០ គ្រួសារត្រូវបានរាយការណ៍ថាត្រូវបានបណ្តេញចេញ ឬដកហូតពីលំនៅដ្ឋានរបស់ពួកគេ។[10] ក្នុងឆ្នាំ២០១៧ ការប៉ាន់ប្រមាណមួយបានបង្ហាញថាសហគមន៍ ជនជាតិដើមភាគតិចនៅកម្ពុជា បានបាត់បង់ដីធ្លីពីបរមេបុរាណរបស់ខ្លួនចំនួន ៣០%។ ក្នុងចំណោមអ្នករងផលប៉ះពាល់ពីទំនាស់ដីធ្លីទាំងនោះ គឺមានមនុស្សជាច្រើនជាក្រុមជនជាតិដើមភាគតិចដែលមានទំនាក់ទំនងយ៉ាងពិសេស ទាំងផ្នែកសង្គម វប្បធម៌ និងសេដ្ឋកិច្ច ជាមួយនឹងដីធ្លីពីបរមេបុរាណរបស់ពួកគាត់ ហើយពួកគេងាយរងគ្រោះខ្លាំងក្នុងការបាត់បង់ដីធ្លី។[11]

ការដោះស្រាយទំនាស់ដីធ្លីគឺជារបៀបវារៈកម្រិតចម្បងរបស់រដ្ឋាភិបាលកម្ពុជា នាយករដ្ឋមន្ត្រីបានអំពាវនាវជាញឹកញាប់ឱ្យមានការដោះស្រាយទំនាស់ដីធ្លីជាក់លាក់នានា។ នៅខែធ្នូ ឆ្នាំ២០១៧ ឧបនាយករដ្ឋមន្ត្រី ស ខេង បានសង្កត់ធ្ងន់លើតម្រូវការឱ្យមានការបែងចែកដីធ្លីប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព ហើយឱ្យពន្លឿនការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីធ្លីថែមទៀតផង។[12] ក្នុងពេលជាមួយគ្នានោះដែរ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា («អូ.អេច.ស៊ី.អេច.អរ») បានរៀបចំសេចក្តីព្រាងឯកសារពិភាក្សាពីកំណែទម្រង់សក្តានុពលលើដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។[13] នៅក្នុងខែតុលា ឆ្នាំ២០១៨ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ («ក្រសួងដែនដី») បានរាយការណ៍ថាបានទទួលបណ្តឹងចំនួន ៩.១៣១ បណ្តឹង ពាក់ព័ន្ធនឹងទំនាស់ដីធ្លី គិតត្រឹមខែសីហា ២០១៨ ហើយរហូតមកទល់នឹងបច្ចុប្បន្ន ទំនាស់ចំនួន ១.៤៥៩ ករណី នៅពុំទាន់បានដោះស្រាយរួចនៅឡើយ។[14] គិតត្រឹមខែឧសភា ឆ្នាំ ២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសថា បានផ្តល់ប័ណ្ណកម្មសិទ្ធីដីសមូហភាព ដល់សហគមន៍ជនជាតិដើមភាគតិចចំនួន ២៤ សហគមន៍ ដែលស្មើនឹងប័ណ្ណកម្មសិទ្ធិចំនួន ៦៦៩ ប័ណ្ណ សម្រាប់ប្រជាពលរដ្ឋចំនួន ២.៣៣៥ គ្រួសារ។[15]

---

[10] "ប្រវត្តិនៃការដកហូតទីលំនៅក្នុងរាជធានីភ្នំពេញ - សហគមន៍ដែលត្រូវបានបណ្តេញចេញពី ឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៤" *សមាគមធាងត្នោត* ('STT')ខែធ្នូ ឆ្នាំ ២០១៤, http://teangtnaut.org/wp-content/uploads/2014/12/FactFigures23_Evicted-Communities-PP-1990-2014_VsFinal.pdf.

[11] "របាយការណ៍ឆ្នាំ២០១៧ របស់ធនាគារពិភពលោកស្តីពីប្រទេសកម្ពុជា ទំព័រ ៩៩

[12] "សម្តេចក្រឡាហោម ស ខេង ផ្តល់អនុសាសន៍សំខាន់ប្រាំចំណុចនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រសួងដែនដី" *សារព័ត៌មាន Fresh News Asia*ខែធ្នូ ឆ្នាំ២០១៧ http://freshnewsasia.com/index.php/en/localnews/74450-2017-12-28-05-43-55.html(មានតែជាភាសាខ្មែរ)

[13] "របាយការណ៍របស់ការិយាល័យអង្គការសហប្រជាជាតិនៃឧត្តមស្នងការសិទ្ធិមនុស្សស្តីពីសិទ្ធិរបស់ប្រជាជនជនជាតិដើមភាគតិច", *OHCHR*, UN Doc A/HRC/39/37, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៧ កថាខ័ណ្ឌ ២៧, https://undocs.org/A/HRC/39/37.

[14] "ករណីចំនួន ៣.៩៦០ ត្រូវបានដោះស្រាយ; ២.៨៥៤ ត្រូវបានបដិសេធចោលនិង ៨៥៨ បណ្តឹង ត្រូវបានដក។ "របាយការណ៍៖ ជម្លោះដីធ្លីជាង ១.០០០ ករណីមិនទាន់បានដោះស្រាយ" *សារព័ត៌មានសំឡេងដើម្បីប្រជាធិបតេយ្យ*ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ https://www.vodhotnews.com/2018/10/25/83753/over-1000-cases-of-land-disputes-unsolved/(មានតែជាភាសាខ្មែរ)

[15] "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា៖ មតិពីសហរដ្ឋអាមេរិក", UN Doc A/HRC/39/73/Add.2, ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៨ ទំព័រ ២៣ https://undocs.org/A/HRC/39/73/ADD.2.https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=project_profile.php&id=3&pro=CTHP&pro_id=2&show=show.

ម.ស.ម.ក បានធ្វើការលើបញ្ហាដីធ្លី ក្នុងព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីខ្លួនត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០២។[16] ជាផ្នែកមួយនៃគម្រោងធុរកិច្ចនិងសិទ្ធិមនុស្សរបស់ខ្លួនក្នុងគោលបំណងបង្កើនការយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមាន នៃសកម្មភាពរបស់ក្រុមហ៊ុនមកលើសិទ្ធិរបស់ប្រជាពលរដ្ឋ និងកែលម្អការប្រតិបត្តិរបស់ក្រុមហ៊ុន[17] ម.ស.ម.ក បានសិក្សាស្រាវជ្រាវដើម្បីវាយតម្លៃលើស្ថានភាពទំនាស់ដីធ្លីក្នុងប្រទេសកម្ពុជា និងផលប៉ះពាល់នៃទំនាស់ដីធ្លីនេះមកលើសិទ្ធិមនុស្ស ដោយផ្តោតលើករណីទំនាស់ដីធ្លីចំនួនបី។ ម.ស.ម.ក បានរកឃើញបញ្ហារួមគ្នាចំពោះករណីទាំងបី ដែលបង្ហាញឱ្យឃើញពីវត្តមាននៃបញ្ហាប្រឈមប្រទាក់ក្រឡាគ្នាទាំងនេះដែលជាឧបសគ្គរាំងដល់ការគោរពសិទ្ធិមនុស្សពីសំណាក់ក្រុមហ៊ុននៅកម្ពុជា។

ដោយផ្អែកលើបញ្ហាទាំងនេះ ម.ស.ម.ក បានលើកឡើងនូវចំណុចចំនួនប្រាំពីរ ដែលក្នុងនោះរួមមានវិធានការជាក់ស្តែងដែលអាចយកទៅអនុវត្តដើម្បីទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយការរំលោភបំពានលើសិទ្ធិមនុស្សកើតចេញពីទំនាស់ដីធ្លីនៅកម្ពុជា។ ចំណុចទាំងនោះរួមមាន៖

របកគំហើញទី១៖ ត្រូវមានការពិចារណាឱ្យបានត្រឹមត្រូវលើសិទ្ធិមានកម្មសិទ្ធិ

របកគំហើញទី២៖ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវធ្វើឡើងមុនពេលចាប់ផ្តើមប្រតិបត្តិការ

របកគំហើញទី៣៖ មានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យមុនពេលមានការអភិវឌ្ឍណាមួយហើយត្រូវគោរពគោលការណ៍ការយល់ព្រមដោយពេញចិត្ត ដោយប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ

របកគំហើញទី៤៖ ការប្រើប្រាស់កងកម្លាំង និងការបំលាស់ទីថ្មីដោយគ្មានការស្ម័គ្រចិត្តត្រូវមានការហាមឃាត់ជាដាច់ខាត

របកគំហើញទី៥៖ ត្រូវអនុញ្ញាតឱ្យសហគមន៍ដែលរងផលប៉ះពាល់អាចតស៊ូមតិទាមទារសិទ្ធិរបស់ខ្លួនដោយសេរី

របកគំហើញទី៦៖ ត្រូវមានការខិតខំប្រឹងប្រែងដើម្បីធានាឱ្យមានដំណោះស្រាយទាន់ពេលវេលានិងមានប្រសិទ្ធភាពសម្រាប់ជនរងគ្រោះ

របកគំហើញទី៧៖ គួរសម្របសម្រួលឱ្យដំណើរការដោះស្រាយទំនាស់ដែលមានជម្រើសផ្សេងទៀតនិងប្រកបដោយភាពច្នៃប្រឌិត

---

[16]"*សូមមើល*"ការបណ្តុះបណ្តាលសហគមន៍ និងសវនាការ", ម.ស.ម.ក។ https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=project_profile.php&id=3&pro=CTHP&pro_id=2&show=show.

[17]"គម្រោងនេះ ដែលមានឈ្មោះថា "ពង្រឹងសមត្ថភាពដល់អង្គការសង្គមស៊ីវិលក្នុងការតស៊ូមតិដើម្បីឱ្យមានការគោរពសិទ្ធិមនុស្សពីសំណាក់ក្រុមហ៊ុនសាជីវកម្មនៅក្នុងវិស័យដីធ្លី" ដែលទទួលការគាំទ្រមូលនិធិពីអង្គការ អាក់សិនអេតណោជីរឡង់ច៍ នីនិងអនុវត្តរួមគ្នាដោយ ម.ស.ម.ក និងអង្គការអាក់សិនអេតកម្ពុជា។ សម្រាប់ព័ត៌មានលម្អិត*សូមមើល៖* https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=project_profile.php&id=3&pro=BHR2&pro_id=106&show=show&https://docs.google.com/viewerng/viewer?url=http://www.cchrcambodia.org/admin/projects/file/BHR_Project_Presentation+for_Eng_Aug_2016.pdf

កំណត់ត្រាសង្ខេបនេះបញ្ចប់ដោយមាន**អនុសាសន៍ចំនួន ១៥** សម្រាប់ឱ្យអាជ្ញាធរ និងក្រុមហ៊ុនឯកជនអនុវត្ត ដើម្បីទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយបញ្ហារំលោភសិទ្ធិពាក់ព័ន្ធនឹងទំនាស់ដីធ្លី។

## ទិដ្ឋភាពទូទៅនៃករណីទាំងបី




ករណីទាំងបីនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ការស្រាវជ្រាវរបស់ ម.ស.ម.ក៖

- ករណីទំនាស់ដីធ្លីរវាងក្រុមហ៊ុនស្ករស មីតផ៉រ ភូល និងប្រជាពលរដ្ឋនៅក្នុងសង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ («ករណី មីតផ៉រ ភូល»)
- ករណីទំនាស់ដីធ្លីក្រុមហ៊ុន សុកហ៊្វិន ខេស៊ីឌី ដែលពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិច និងក្រុមហ៊ុនចម្ការកៅស៊ូ សុកហ៊្វិន ខេស៊ីឌី ក្នុងឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី («ករណីសុកហ៊្វិន ខេស៊ីឌី») និងចុងក្រោយគឺ
- ទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋនិងក្រុមហ៊ុន អឹម.ឌី.អេស នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសថ្មដា អឹម.ឌី.អេស ស្ថិតក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ («ករណី អឹម.ឌី.អេស»)។

ពីរករណីពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ក្នុងនោះមួយករណីពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិច («ករណី សុកហ្វិន ខេស៊ីឌី») និងមួយទៀតពាក់ព័ន្ធនឹងកសិករ («ករណី មីតផ៉រ ភូល») ចំណែកឯករណីទីបីពាក់ព័ន្ធនឹងតំបន់សេដ្ឋកិច្ចពិសេស («ករណី អឹម.ឌី.អេស»)។ ក្រុមហ៊ុនផ្សេងៗគ្នាបានជាប់ពាក់ព័ន្ធនឹងករណីទាំងនេះ៖ ជាក្រុមហ៊ុនពហុជាតិរបស់អឺរ៉ុប («ក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី ») ជាក្រុមហ៊ុនថៃ («ក្រុមហ៊ុន មីតផ៉រ ភូល») និងក្រុមហ៊ុនខ្មែរ («ក្រុមហ៊ុនថ្មដា អឹម.ឌី.អេស ខូ.អិល.ធី.ឌី»)។

## ករណីក្រុមហ៊ុន មីតផ៉រ ភូល

ជាករណីដំបូងគេទាក់ទងនឹងទំនាស់ដីធ្លីជុំវិញសម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនបុត្រសម្ពន្ធរបស់ក្រុមហ៊ុន មិតផ៉រ ភូល ឧបប៉ូរ៉េសិន លីមីតធិត («ក្រុមហ៊ុន មិតផ៉រ ភូល») ជាក្រុមហ៊ុនស្ករសរបស់ប្រទេសថៃជាមួយនឹងប្រជាពលរដ្ឋនៅក្នុងភូមិចំនួន ៥[18] ក្នុងសង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ជាប់នឹងព្រំដែនជាមួយប្រទេសថៃ។ ជារួម ប្រជាពលរដ្ឋចំនួនប្រមាណ ៧១២ គ្រួសារ[19] បានរងផលប៉ះពាល់ដោយសារទំនាស់ដីធ្លីនេះ។[20] រហូតមកទល់សព្វថ្ងៃ យ៉ាងហោចណាស់មានប្រជាពលរដ្ឋចំនួន ៣៨៣ គ្រួសារ នៅតែកំពុងរង់ចាំដំណោះស្រាយ។

## សម្បទានដីសេដ្ឋកិច្ច

នៅខែមករា ឆ្នាំ២០០៨ សម្បទានដីសេដ្ឋកិច្ចចំនួនបី ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ («ក.ស.ក») ផ្តល់ទៅឱ្យក្រុមហ៊ុនបីផ្សេងៗគ្នា គឺ ក្រុមហ៊ុនអង្គរស៊ូហ្គើរ ក្រុមហ៊ុនទន្លេស៊ូហ្គើរ និងក្រុមហ៊ុន ខេនស៊ូហ្គើរវ៉ាលី[21] សម្រាប់ធ្វើជាចម្ការអំពៅ និងសាងសង់រោងចក្រចម្រាញ់ក្នុងរយៈពេល៧០ឆ្នាំ។[22] សម្បទានដីសេដ្ឋកិច្ចសម្រាប់ក្រុមហ៊ុនអង្គរស៊ូហ្គើរ និងខេនស៊ូហ្គើរ វ៉ាលី ស្ថិតនៅក្នុងក្រុងសំរោង ហើយសម្រាប់ក្រុមហ៊ុនទន្លេស៊ូហ្គើរ គឺស្ថិតក្នុងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ដែលមានផ្ទៃដីសរុបរួមគឺស្មើនឹង ១៩.៧៣៦ ហិកតា៖ ៦.៥២៣ ហិកតា សម្រាប់អង្គរស៊ូហ្គើរ ៦.៦១៨ ហិចតាសម្រាប់ទន្លេស៊ូហ្គើរ និង៦.៥៩៥ ហិចតាសម្រាប់កម្ពុជា

---

[18]"ខ្ទុម(ឬអាចសរសេរថា Ktum), បុស្ស (ឬអាចសរសេរថា Bos), អូរបាត់មាន់, តាម៉ាន(ឬអាចសរសេរថា Taman), Trapeang ត្រពាំងវែង(ឬអាចសរសេរថា Trapiang Veng).

[19]"១គ្រួសារ = ១ឈ្មោះក្នុងដីមួយឡូត៍ ដែលបានប្រើ/បាត់បង់

[20] "ប្រភព៖ អង្គការសមធម៌កម្ពុជា

[21]"សង្ខេបករណី៖ បណ្តឹងពីពលរដ្ឋកម្ពុជាចំពោះសាជីវកម្មស្ករសមីត្រផល" អង្គការ អន្តរជាតិការអភិវឌ្ឍដោយមានការចូលរួម(Inclusive Development International) ថ្ងៃទី ២ មេសា ២០១៨ ទំព័រទី ១https://www.inclusivedevelopment.net/wp-content/uploads/2018/03/Mitr-Phol-Class-Action-Case-Brief.pdf ('បណ្តឹងប្រឆាំងក្រុមហ៊ុនមីតផ៉រ ភូលថៃពី IDI ខែមេសា ២០១៨)

[22]"បណ្តឹងប្រឆាំងក្រុមហ៊ុនមីតផ៉រ ភូលថៃពី IDI ខែមេសា ឆ្នាំ២០១៨, ទំព័រទី ២

ខេនស៊ូហ្គើរ៉ាលី។[23] ជារួមសម្បទានដីសេដ្ឋកិច្ចទាំងបី ប៉ះពាល់ប្រជាពលរដ្ឋចំនួន ២៦ ភូមិ ក្នុងឃុំចំនួនបួន។[24] ក្រុមហ៊ុនទាំងបីបានដាក់ពាក្យសុំសម្បទានដីសេដ្ឋកិច្ចក្នុងពេលតែមួយ គឺនៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៧ ហើយទទួលបានការអនុម័តយល់ព្រមនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ ហើយបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនៅថ្ងៃតែមួយគឺ ថ្ងៃ២៤ ខែមករា ឆ្នាំ២០០៨។[25] កំណត់ត្រាសង្ខេបនេះ ផ្តោតលើទំនាស់ពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចសម្រាប់ក្រុមហ៊ុនអង្គរស៊ូហ្គើរ ដែលស្ថិតនៅសង្កាត់កូនក្រៀល។

ក្នុងពេលនោះ នាយកក្រុមហ៊ុន អង្គរស៊ូហ្គើរ មានឈ្មោះថា ថាត វ៉ាន់ណាកនគល[26] ដែលជាអនុប្រធានប្រតិបត្តិរបស់ក្រុមហ៊ុន មីតផ៉រ ភូល ផងដែរ។[27] ក្នុងឆ្នាំ២០០៩ មីតផ៉រ ភូល បានក្លាយជាភាគហ៊ុនិកតែមួយគត់របស់ក្រុមហ៊ុនអង្គរស៊ូហ្គើរ។[28]

សម្បទានដីសេដ្ឋកិច្ចបានចាប់ផ្តើមកំណត់ព្រំនៅក្នុង ខែឧសភា ឆ្នាំ២០០៧ គឺតាំងពីមុនពេលដែលសម្បទានដីសេដ្ឋកិច្ចនេះត្រូវបានផ្តល់ជាផ្លូវការទៅទៀត ហើយសកម្មភាពឈូសឆាយដីធ្លីបានចាប់ផ្តើមនៅខែមេសា ឆ្នាំ២០០៨។ ចន្លោះពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០០៩ ប្រជាពលរដ្ឋត្រូវបានបង្ខំឱ្យប្រគល់ដីរបស់ខ្លួនទៅឱ្យក្រុមហ៊ុនអង្គរស៊ូហ្គើរ ជាសម្បទានដីសេដ្ឋកិច្ច។ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៥ រាល់កិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ចទាំងបីត្រូវបានលុបចោល។[29]

## អំពីក្រុមហ៊ុន មិតផ៉រ ភូល ខបប៉ូរ៉េសិន លី មីត ធិត

មិតផ៉រ ភូល មានក្រុមហ៊ុនបុត្រសម្ពន្ធចំនួន ១៧ ក្នុងប្រទេសថៃ កម្ពុជា សហរដ្ឋអាមេរិក ឡាវ អូស្ត្រាលី សិង្ហបុរីនិងចិន។[30] មិតផ៉រ ភូល ប្រកាសថាខ្លួនជាក្រុមហ៊ុនផលិតស្ករសធំជាងគេបំផុតលេខបីក្នុងពិភពលោក។[31] ក្រុមហ៊ុនធ្វើប្រតិបត្តិការនៅក្នុងប្រទេសអូស្ត្រាលី កម្ពុជា ចិន ឡាវ និងវៀតណាម និងផ្គត់ផ្គង់ដល់ក្រុមហ៊ុនយីហោល្បីៗពិភពលោកនានាដូចជា កូកា-កូឡា ប៉ិបស៊ី ណេសត្លា និង Mars។[32] ក្រុមហ៊ុន មិតផ៉រ ភូល មាន

[23]"កម្ពុជា៖ រសជាតិល្វីងនៃស្ករអំពៅ ការចាកចេញដោយបង្ខំចិត្ត និងការដកហូតសិទ្ធិកាន់កាប់ដីធ្លីក្នុងខេត្តឧត្តរមានជ័យ" អង្គការ ActionAid Cambodia និង Oxfam ខែឧសភា ឆ្នាំ២០១៥ទំព័រ ១៥ តារាង ៣.១ http://www.actionaid.org/sites/files/actionaid/finalized_the_bitter_taste_of_sugar_displacement_and_dispossession_in_oddar_meancehy_2015_1.pdf (ខែឧសភា ឆ្នាំ២០១៥ របាយការណ៍ស្តីពី ស្ករសរសជាតិល្វីង)

[24]"ខែឧសភា ឆ្នាំ២០១៥ របាយការណ៍ស្តីពី ស្ករសរសជាតិល្វីង; ៣.៣ សហគមន៍រងផលប៉ះពាល់ ទំព័រទី ១៦

[25]"ខែឧសភា ឆ្នាំ២០១៥ របាយការណ៍ស្តីពី ស្ករសរសជាតិល្វីង; ៣.៤ ប្រវត្តិសម្បទានិក ទំព័រទី ១៧

[26]"ក្រុមហ៊ុនបើកទូលាយ, https://cambodiacorporates.globalwitness.org/search?type=ids&id=A5671,R12803,A4344.

[27]"បណ្តឹងប្រឆាំងក្រុមហ៊ុនមីត្រផុលថៃពី IDI ខែមេសា ២០១៨, ទំព័រទី ១

[28]"បណ្តឹងប្រឆាំងក្រុមហ៊ុនមីត្រផុលថៃពី IDI ខែមេសា ២០១៨, ទំព័រទី ២

[29]"បណ្តឹងប្រឆាំងក្រុមហ៊ុនមីតផ៉រ ភូលថៃពី IDI ខែមេសា ២០១៨, ទំព័រទី ១-៣

[30]"មូលដ្ឋានទិន្នន័យ Orbis, អំពីក្រុមហ៊ុន Mid-Siam Sugar Co. Ltd គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៧។ មានសម្រាប់តែអ្នកប្រើប្រាស់ដែលបានចុះឈ្មោះប៉ុណ្ណោះ។

[31]"គេហទំព័ររបស់ក្រុមហ៊ុនស្ករសមីត្រផុល https://www.mitrphol.com/mitphol-sugar.php

[32]"ប្រជាពលរដ្ឋកម្ពុជាដែលត្រូវបានបណ្តេញចេញទាំងបង្ខំបានដាក់ពាក់បណ្តឹងជាប្រវត្តិសាស្ត្រប្រឆាំងក្រុមហ៊ុនផលិតស្ករសធំជាងគេបំផុតនៅអាស៊ី" *IDI*ថ្ងៃទី ២ ខែមេសាឆ្នាំ២០១៨https://www.inclusivedevelopment.net/forcibly-displaced-cambodians-file-historic-lawsuit-against-asias-largest-sugar-producer/.

ក្រុមហ៊ុន មីដ-សៀម ស៊ូហ្គើរ ខូ.អែល.ធី.ឌី[33] ជាម្ចាស់ដោយគ្រប់គ្រងហ៊ុនរហូតដល់ទៅ ៩៩,៩៨% ហើយក្រុមហ៊ុន មីដ-សៀមស៊ូហ្គើរ ខូ.អែល.ធី.ឌី ជាសម្ពន្ធក្រុមហ៊ុនមួយ ដែលមានភាគហ៊ុននៅតាមបណ្ដាក្រុមហ៊ុនផ្សេងៗហើយត្រូវបានរាយការណ៍ថា ស្ថិតក្រោមការគ្រប់គ្រង និងកាន់កាប់ដោយក្រុមគ្រួសារត្រកូល វង់គូ សូលគិត[34] ដែលជាក្រុមគ្រួសារជនជាតិថៃ។

មិតផល់ កូល បានបដិសេធជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស ហើយបានលើកឡើងថាដំណើរការផ្ដល់សម្បទានដីសេដ្ឋកិច្ចគឺត្រូវបានធ្វើឡើង ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្ស («គោលការណ៍ណែនាំ»)។[35] ទោះជាយ៉ាងណា នៅក្នុងការផ្ដល់ចម្លើយកស្មិណសាក្សីផ្ទាល់មាត់ នៅចំពោះមុខគណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិប្រទេសថៃ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៥ តំណាងរបស់ មិតផល់ កូល បានទទួលស្គាល់ថា មានប្រជាពលរដ្ឋ «រងផលប៉ះពាល់» ហើយត្រូវបានរាយការណ៍ថាបានជួលក្រុមហ៊ុនមួយឱ្យធ្វើការអង្កេតលើការខូចខាតក្នុងតំបន់នោះ។[36]

## ករណីក្រុមហ៊ុន សុកហ៊ិន ខេស៊ីឌី

ករណីទីពីរពាក់ព័ន្ធនឹងទំនាស់ដីធ្លី ដែលប៉ះពាល់ប្រជាពលរដ្ឋ ៦ ភូមិ[37] នៅឃុំប៊ូស្រា[38] ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី នៅភាគឥសានប្រទេសកម្ពុជាប្រមាណជា ៣០ គីឡូម៉ែត្រពីព្រំដែនវៀតណាម និង ៣៨២ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ មណ្ឌលគិរី ជាខេត្តធំជាងគេបំផុតរបស់កម្ពុជាដែលសម្បូរទៅដោយធនធានធម្មជាតិរាប់បញ្ចូលទាំងដីមានជីជាតិ និងធនធានទឹកផងដែរ។[39] ប្រជាពលរដ្ឋប្រមាណជាង ៨០០ គ្រួសារបានរងការប៉ះពាល់[40] ដែលភាគច្រើនជាជនជាតិពូនង[41] ដែលជាសហគមន៍ជនជាតិភាគតិចមានការទទួលស្គាល់ជាផ្លូវការ

---

[33] "បណ្ដឹងប្រឆាំងក្រុមហ៊ុនមីតផល់ កូលថៃពី IDI ខែមេសា ឆ្នាំ២០១៨, ទំព័រទី ១; ខែឧសភា ឆ្នាំ២០១៥ របាយការណ៍ស្ដីពី ស្គរសេរសជាតិល្វឹងជូរចត់, ៣.៤ ប្រវត្តិសម្បទានិក ទំព័រទី ១៨; ចំណុចនេះត្រូវបានបញ្ជាក់ថាត្រឹមត្រូវតាមការស្វែងរកនៅលើមូលដ្ឋានទិន្នន័យ Orbis តាមរយៈការស្រាវជ្រាវដែលធ្វើឡើងដោយ SOMO

[34] "ខែឧសភា ឆ្នាំ២០១៥ របាយការណ៍ស្ដីពី ស្គរសេរសជាតិល្វឹងជូរចត់, ៣.៤ ប្រវត្តិសម្បទានិក ទំព័រទី ១៨

[35] "របាយការណ៍ស៊ើបអង្កេតលេខ 1003/2015", *គណៈកម្មការសិទ្ធិមនុស្សថៃ,* ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៥ ទំព័រ ១៣, https://www.inclusivedevelopment.net/wp-content/uploads/2016/09/Thai-Human-Rights-Commission-Report_Mitr-Phol_Unofficial-translation-.docx (ការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស)

[36] "របាយការណ៍ស៊ើបអង្កេតលេខ 1003/2015", *គណៈកម្មការសិទ្ធិមនុស្សថៃ,* ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៥ ទំព័រ ១៤, https://www.inclusivedevelopment.net/wp-content/uploads/2016/09/Thai-Human-Rights-Commission-Report_Mitr-Phol_Unofficial-translation-.docx (ការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស) សូមចូលមើទីនេះផងដែរ https://www.farmlandgrab.org/post/view/25763-thai-firm-sugar-farm-damage-assessment-is-almost-finished

[37] "ភូមិពូទឹត, ភូមិពូព្រាំង, ភូមិប៊ូស្រា, ភូមិឡាំមេះ, ភូមិពូចារ និងភូមិពូលុ

[38] "អាចប្រកបជា Bousra, Busra.

[39] "ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ព័ត៌មានស្ដីពីការវិនិយោគក្នុងទីក្រុង និងតាមបណ្ដាខេត្ត, ខេត្តមណ្ឌលគិរី ទំព័រ ៦៨ http://www.cambodiainvestment.gov.kh/wp-content/uploads/2014/03/Mondulkiri-Province_eng-1.pdf.

[40] "អាជីវកម្ម និងសិទ្ធិមនុស្សនៅកម្ពុជា បង្កើតបានជាសសរស្ដម្ភបី" *ម.ស.ម.ក* ខែវិច្ឆិកា ឆ្នាំ២០១០ កថាខ័ណ្ឌ ១៨៨ https://cchrcambodia.org/admin/media/report/report/english/2010-11-30-%20Full%20Report%20%20Business%20and%20Human%20Rights%20in%20Cambodia%20Constructing%20the%20Three%20Pillars.pdf.

[41] "អាចប្រកបថា Bunong, Bu Nong, Punong, Phnnong, Phnong.

ដូចជាដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ។ សព្វថ្ងៃ យ៉ាងហោចមានប្រជាពលរដ្ឋចំនួន ៦៤០ គ្រួសារ កំពុងជាប់ពាក់ព័ន្ធនៅក្នុងដំណើរការដោះស្រាយទំនាស់ដីធ្លីនេះ។

## សម្បទានដីសេដ្ឋកិច្ច

នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន ខូវដឺលី អភិវឌ្ឍន៍ ខូ.អិល.ធី.ឌី («ខេស៊ីឌី») ដែលជាក្រុមហ៊ុនសំណង់របស់កម្ពុជាបានចុះកិច្ចសន្យាស្តីពី «ការវិនិយោគកៅស៊ូ និងចម្ការកសិឧស្សាហកម្ម»។[42] សម្បទានដីសេដ្ឋកិច្ចទំហំ ២.៣៨៦ ហិកតា ត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុន ខេស៊ីឌី សម្រាប់ការដាំដំណាំកៅស៊ូ និងជាបន្ទាប់បន្សំគឺសម្រាប់ការផលិតដំណាំឧស្សាហកម្មផ្សេងទៀតសម្រាប់រយៈពេល ៧០ឆ្នាំ។[43] នាពេលនោះ ខេស៊ីឌី ស្ថិតក្រោមការគ្រប់គ្រងដោយលោក ខូវ ផល្លាបុត្រ ដែលត្រូវបានបង្ហាញថាជាជនជាតិចិននៅក្នុងកិច្ចសន្យានោះ[44] ប៉ុន្តែតាមរបាយការណ៍ គឺជាកូនប្រុសរបស់ឧកញ៉ាកូនកាត់ចិនកម្ពុជាលោក ខូវ ជឺលី។[45] ដីដែលជាកម្មវត្ថុនៃកិច្ចសន្យានេះក្រោយមកបានក្លាយទៅជាសម្បទាន វ៉ារ៉ាណាស៊ី។[46]

នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៩ សុកហ្វិន ខេស៊ីឌី ហាក់បានទិញយកកិច្ចសន្យារបស់ ខេស៊ីឌី សម្រាប់សម្បទានដីសេដ្ឋកិច្ច វ៉ារ៉ាណាស៊ី។[47] នៅដើមឆ្នាំ ២០១០ ក្រុមហ៊ុននេះបានចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការជួលឱ្យក្រុមហ៊ុន សេដ្ឋីកូឡា។[48] នៅឆ្នាំ២០១០ សុកហ្វិន ខេស៊ីឌី បានទិញភាគហ៊ុន១០០% របស់ក្រុមហ៊ុន សេដ្ឋីកូឡា ខូ.អិល.ធី.ឌី។[49] គិតត្រឹមពេលសរសេររបាយការណ៍នេះ ចម្ការសេដ្ឋីកូឡា និង វ៉ារ៉ាណាស៊ី ត្រូវបាន

---

[42] "កម្ពុជា - ដីឈូសឆាយសម្រាប់ដំណាំកៅស៊ូសិទ្ធិត្រូវបានរំលោភះផលប៉ះពាល់ពីចម្ការកៅស៊ូរបស់Socfin-KCD លើសហគមន៍ជនជាតិដើមភាគតិចក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគិរី",*FIDH*, ខែតុលា ឆ្នាំ ២០១១ ឧបសម្ពន្ធទី ២,https://www.fidh.org/IMG/pdf/report_cambodia_socfin-kcd_low_def.pdf ('របាយការណ៍របស់ FIDH').

[43] "មាត្រាទី ១ (១.១), ១ (១.២) និងទី ៤

[44] "របាយការណ៍ FIDH ឧបសម្ពន្ធទី ២ ទំព័រទី ១

[45] "របាយការណ៍ FIDH ទំព័រទី ២១

[46] "នៅខែមិថុនា ឆ្នាំ២០១២ ឈ្មោះក្រុមហ៊ុនសម្បទាន ខូចដូលីអភិវឌ្ឍន៍បានក្លាយជា Varanasi នៅខែមិថុនា ២០១២ *Open Development Cambodia*, សម្បទានដីសេដ្ឋកិច្ច Varanasi, https://opendevelopmentcambodia.net/profiles/economic-land-concessions/?feature_id=elc_gdp_158; *សូមមើល*របាយការណ៍ FIDH លេខយោង ៦៨, ទំព័រ ១៧

[47] "របាយការណ៍ FIDH ទំព័រ ១៩ លេខយោង ៧៦ ដែលនិយាយអំពីកិច្ចសន្យាសម្រាប់ Varanasi ដែលចុះហត្ថលេខានៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៩

[48] "របាយការណ៍ FIDH ទំព័រ ១៩ សំដៅលើកាលបរិច្ឆេទ ថ្ងៃទី២៣ ខែកុម្ភៈ កុម្ភៈ២០១០ ដូចមានបញ្ជាក់នៅក្នុងឯកសាររបស់ Socfin លេខយោង ៧៦ ប៉ុន្តែក្រោយមកកាលបរិច្ឆេទថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ ត្រូវបានលើកឡើងក្នុងផ្នែកក្រោយៗមកទៀតនៅក្នុងរបាយការណ៍នោះ; ទំព័រ ៣៤។ គេហទំព័ររបស់ Socfin មានព័ត៌មានផ្ទុយគ្នា - ទំព័រ Socfin-KCD និយាយថា សម្បទានទីពីរទទួលបានក្នុងឆ្នាំ២០១០ "Socfin-KCD និង Coviphama" គេហទំព័រសម្ពន្ធក្រុមហ៊ុន Socfin http://www.socfin.com/en/locations/companies/detail/socfin-kcd-coviphama ; សូមអានរបាយការណ៍FIDH ទំព័រ ១៩ខណៈដែលទំព័រ "ប្រវត្តិក្រុមហ៊ុន" របស់ សុកហ្វិន បាននិយាយថាសម្បទានទាំងពីរបានទទួលនៅឆ្នាំ២០០៧។សូមមើល "Socfin Group, History" ២០០៧http://www.socfin.com/en/socfin-group/history។របាយការណ៍ប្រចាំឆ្នាំរបស់ សុកហ្វិន បានបញ្ជាក់ថាក្រុមហ៊ុនSethikula ត្រូវបានទិញក្នុងឆ្នាំ២០១០ក្នុងទំហំទឹកប្រាក់១.៧លានអឺរ៉ូ;ទំព័រ២៦ http://paperjam.lu/sites/default/files/old-files/fichiers_contenus/rapports_annuels/2013/socfin_2010_fr.pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ)

[49] "របាយការណ៍ប្រចាំឆ្នាំរបស់ សុកហ្វិន សម្រាប់ឆ្នាំ ២០១០", ទំព័រ ២៦http://paperjam.lu/sites/default/files/old-files/fichiers_contenus/rapports_annuels/2013/socfin_2010_fr.pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ); *សូមមើលផងដែរ*"របាយការណ៍ប្រចាំឆ្នាំ របស់ Socfinasia សម្រាប់ឆ្នាំ ២០១៧", កំណត់សម្គាល់លេខ ៣០ ទំព័រ៨៩, http://www.socfin.com/frontend/files/userfiles/files/Asia%20RA%202017.pdf( មានតែជាភាសាបារាំងប៉ុណ្ណោះ).

ក្តោបក្តាប់ ១០០% ដោយក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី។[50] នៅលើគេហទំព័ររបស់ខ្លួន សម្ពន្ធក្រុមហ៊ុន សុកហ្វិន បានហៅចម្ការ វ៉ារ៉ាណាស៊ី និងសេដ្ឋីកូឡាថាជា «ចម្ការរបស់ សុកហ្វិន ខេស៊ីឌី»[51] ហើយមានផែនទីបង្ហាញពីដីសម្បទាននៅលើគេហទំព័ររបស់ខ្លួនផងដែរ។[52] ក្រុមហ៊ុនបានចាប់ផ្តើមឈូសឆាយដីនៅជិត ឃុំប៊ូស្រា ក្នុងខែមេសា ឆ្នាំ២០០៨ គឺមុនពេលដែលកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចត្រូវបានចុះហត្ថលេខា។[53]

## អំពីក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី

ក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី ខូ.អិល.ធី.ឌី («សុកហ្វិន ខេស៊ីឌី») គឺជាក្រុមហ៊ុនរួមទុនរវាងក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី និងក្រុមហ៊ុន សុកហ្វិនណាស៊ី[54] ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧។[55] នៅពេលនោះ សុកហ្វិនណាស៊ី កាន់កាប់ ៨០% នៃភាគហ៊ុនរួម ហើយ ខេស៊ីឌី កាន់កាប់ ២០%។[56] ចាប់តាំងពីថ្ងៃ ៣០ ខែកក្កដា ឆ្នាំ២០១៥ ក្រុមហ៊ុន សុកហ្វិនណាស៊ី អេស.អេ. («សុកហ្វិនណាស៊ី») កាន់កាប់ ១០០% នៃភាគហ៊ុនរបស់ សុកហ្វិន ខេស៊ីឌី ។[57]

ក្រុមហ៊ុន សេដ្ឋីកូឡា ខូ.អិល.ធី.ឌី និងក្រុមហ៊ុន វ៉ារ៉ាណាស៊ី ខូ.អិល.ធី.ឌី ក៏ជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងធ្វើចម្ការកៅស៊ូផងដែរ។ ក្រុមហ៊ុនទាំងពីរបានចុះបញ្ជីការដោយមានអាសយដ្ឋានដូចគ្នាក្នុងគេហទំព័រចុះបញ្ជីការអាជីវកម្ម របស់ព្រះរាជាណាចក្រកម្ពុជា

---

[50] "ទំព័ររបស់ សម្ពន្ធក្រុមហ៊ុន សុកហ្វិន ស្តីពីចម្ការ Sethikula; "ម្ចាស់ភាគហ៊ុន"៖http://www.socfin.com/en/sethikula; Varanasi: http://www.socfin.com/en/varanasi.

[51] "Socfin-KCD & Coviphama", *Socfin Group*, http://www.socfin.com/en/locations/companies/detail/socfin-kcd-coviphama.

[52] "ព្រំដីសម្បទានរបស់ចម្ការ KCD – កម្ពុជា", Socfin Group, http://www.socfin.com/frontend/files/userfiles/files/Socfin%20KCD%20-%20Map%20-%20KML%20file.pdf.

[53] "របាយការណ៍ FIDH ទំព័រ ៣៣

[54] "គេហទំព័ររបស់ក្រុមហ៊ុន Socfin-KCD's អំពីគេហទំព័ររបស់ Socfin Group៖http://www.socfin.com/en/socfin-kcd, បង្កើតនៅ៖ឆ្នាំ 2007; "របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន សុកហ្វិន សម្រាប់ឆ្នាំ ២០១២", ទំព័រ 4, http://www.socfin.com/frontend/files/userfiles/files/SOCFINASIA%20-%20RAPPORT%20ANNUEL%20(2012).pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ)។ របាយការណ៍ FIDH 19, Fn 76, ដែលសំដៅលើកិច្ចសន្យាសម្រាប់ទីក្រុងវ៉ារ៉ាណាស៊ីដែលត្រូវបានសំដៅលើការចុះហត្ថលេខានៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៩។

[55] "គេហទំព័ររបស់ក្រុមហ៊ុន Socfin-KCD's អំពីគេហទំព័ររបស់ Socfin Group៖http://www.socfin.com/en/socfin-kcd, បង្កើតនៅឆ្នាំ 2007; "របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន សុកហ្វិន សម្រាប់ឆ្នាំ ២០១២", ទំព័រ 4, http://www.socfin.com/frontend/files/userfiles/files/SOCFINASIA%20-%20RAPPORT%20ANNUEL%20(2012).pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ)។គេហទំព័ររបស់ក្រុមហ៊ុន Socfin-KCD's អំពីគេហទំព័ររបស់ Socfin Group៖ http://www.socfin.com/en/socfin-kcd, បង្កើតនៅ៖ឆ្នាំ 2007;

[56] "របាយការណ៍របស់ FIDH ទំព័រ 19, កថាខ័ណ្ឌចុងក្រោយ។

[57] "គេហទំព័ររបស់ក្រុមហ៊ុន Socfin-KCD អំពីគេហទំព័ររបស់ សុកហ្វិន "ម្ចាស់ភាគហ៊ុន"៖http://www.socfin.com/en/socfin-kcd; "របាយការណ៍របស់ក្រុមហ៊ុន Socfinasia ឆ្នាំ 2015", ទំព័រ 4, បញ្ចូលនៅថ្ងៃទី 30 ខែកក្កដា ឆ្នាំ 2015; *សូមមើលផងដែរនូវ* ទំព័រ២៥ "Faits marquants" (ការពិតដែលគួរឱ្យកត់សម្គាល់), http://www.socfin.com/frontend/files/userfiles/files/SOCFINASIA%20-%20RAPPORT%20ANNUEL%20(2015).pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ); "Socfin KCD, ការជូនដំណឹងពីការចូលរួម", *Socfin Group*, http://www.socfin.com/en/socfin-kcd; "រចនាសម្ពន្ធក្រុមហ៊ុន", *Socfin Group*, http://www.socfin.com/en/socfin-group/organisation-chart.

ហើយក្រុមហ៊ុនទាំងពីរនេះមានលោក Jef Charles Henri Boedt ដែលជាអ្នកគ្រប់គ្រងទូទៅ[58] នៃក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី ជាប្រធានក្រុមប្រឹក្សាភិបាលនាយក។ តាមរយៈការសម្បទានទាំងពីរនេះ ក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី បានគ្រប់គ្រងលើចម្ការកៅស៊ូច្រើនជាង ៧.០០០ ហិកតា។[59] រហូតមកដល់ពេលបច្ចុប្បន្នក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី ត្រូវបានរាយការណ៍ថា បានធ្វើចម្ការកៅស៊ូនៅលើផ្ទៃដីដែលមានទំនាស់ចំនួន ៣.៨៩៧ ហិកតា។ ចម្ការរបស់ក្រុមហ៊ុននេះបានចាប់ផ្តើមផ្តល់ផលនៅឆ្នាំ២០១៥ ហើយនៅក្នុងឆ្នាំ២០១៧ ក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី បានប្រកាសថាខ្លួនបានចាប់ផ្តើមសាងសង់រោងចក្រកែច្នៃកៅស៊ូ ដែលទំនងជានឹងចាប់ផ្តើមប្រតិបត្តិការនៅក្នុងឆ្នាំ២០១៨។[60]

សុកហ្វិនណាស៊ីគឺជាក្រុមហ៊ុនមេដែលបានចុះបញ្ជីនៅក្នុងប្រទេសលុចហ្សំបួរ ដោយមានគោលបំណងគ្រប់គ្រងផលប័ត្រនៃក្រុមហ៊ុនដែលមានប្រតិបត្តិការលើការធ្វើចម្ការដូងប្រេង និងចម្ការកៅស៊ូនៅតំបន់ អាស៊ីអាគ្នេយ៍ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ ៥៥.០០០ ហិកតា។[61] នៅក្នុងខែសីហា ឆ្នាំ២០១៣ សុកហ្វិន ណាស៊ី តាមរយៈក្រុមហ៊ុន ចម្ការ នត-ស៊ូមាត្រា អែល.ធី.ឌី («ភី.អឹន.អេស្ស អ៊ឹល ធី ឌី») ដែលជាបុត្រសម្ពន្ធរបស់ខ្លួន ក្រុមហ៊ុន សុកហ្វីនណាស៊ី បានទិញយកភាគហ៊ុន ៩០% របស់ក្រុមហ៊ុន ខូវីផាម៉ា ខូ អ៊ឹល ធី ឌី ដែលជាក្រុមហ៊ុនទទួលបន្ទុកលើសម្បទាន ដី (៥.៣៤៥ ហិកតា)។[62] រហូតមកដល់បច្ចុប្បន្នក្រុមហ៊ុន សុកហ្វីនណាស៊ី គ្រប់គ្រងលើក្រុមហ៊ុន ខូវីផាម៉ា[63] សេដ្ឋីកូឡា[64] និង វ៉ារ៉ាណាស៊ី។[65] ក្រុមហ៊ុន សុកហ្វីនណាស៊ី ត្រូវបានកាន់កាប់ដោយក្រុមហ៊ុន សុកហ្វីន[66]គ្រុប[67] ដែលមានមូលដ្ឋាននៅប្រទេសលុចហ្សំបួរ និងដែលមាន ភាគហ៊ុន ៥៧,៧៩% និង ក្រុមហ៊ុន

[58]"របាយការណ៍ចីរភាព ឆ្នាំ២០១៧", *Socfin Cambodia*ទំព័រ 6,
http://www.socfin.com/frontend/files/userfiles/files/SocfinCambodia%20Report%202017_Final.pdf

[59]"របាយការណ៍ចីរភាព ឆ្នាំ២០១៧", *Socfin Cambodia*ទំព័រ 6,
http://www.socfin.com/frontend/files/userfiles/files/SocfinCambodia%20Report%202017_Final.pdf

[60]"*ដដែលដូចខាងលើ សូមមើលផងដែរ* " Business insider៖ ក្រុមហ៊ុនកៅស៊ូពង្រីកកម្លាំងផលិត", កាសែតឌឹភ្នំពេញប៉ុស្តិ៍ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨, https://www.phnompenhpost.com/business/business-insider-rubber-firm-expands-processing-power; *សូមមើលផងដែរ*" ក្រុមហ៊ុន Socfin Cambodia បានពង្រឹងនីតិវិធីសុវត្ថិភាព", *SocfinCambodia*, ថ្ងៃទី០៣ខែតុលា ឆ្នាំ២០១៨,http://www.socfin.com/en/news/detail/socfin-cambodia-improved-the-safety-procedures.

[61]"http://www.socfin.com/en/investors/socfinasia.

[62]"Socfin KCD និង Coviphama", Socfin Group, http://www.socfin.com/en/locations/companies/detail/socfin-kcd-coviphama; ក្រុមហ៊ុន Coviphama Co Ltd ត្រូវបានទិញដោយក្រុមហ៊ុន PNS Ltd ដែលជាក្រុមហ៊ុនបុត្រសម្ពន្ធនៃ Socfinasia SA នៅក្នុងតម្លៃ៩០% នៅថ្ងៃទី១៣ខែកក្កដា ឆ្នាំ២០១៣ ស្មើនឹង១៣,៣ លានអឺរ៉ូសូមមើល របាយការណ៍ប្រចាំឆ្នាំ ២០១៧ របស់ Socfinasia, ទំព័រ 80, http://www.socfin.com/frontend/files/userfiles/files/SOCFIN%20RA%202017.pdf( មានតែជាភាសាបារាំងប៉ុណ្ណោះ)។ "របាយការណ៍ប្រចាំឆ្នាំ ២០១៣ របស់ Socfinasia", ទំព័រ 25,
http://www.socfin.com/frontend/files/userfiles/files/SOCFINASIA%20-%20RAPPORT%20ANNUEL%20(2013).pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ)។

[63]"គេហទំព័ររបស់ Socfin Group ស្តីពីចំការរបស់ក្រុមហ៊ុន Coviphama៖http://www.socfin.com/en/coviphama.

[64]"គេហទំព័ររបស់ Socfin Group ស្តីពីចំការរបស់ក្រុមហ៊ុន Sethikula៖http://www.socfin.com/en/sethikula.

[65]"គេហទំព័ររបស់ Socfin Group ស្តីពីចំការរបស់ក្រុមហ៊ុន Varanasi៖http://www.socfin.com/en/varanasi

[66]"Socfin ជាពាក្យកាត់មកពី "Société Financière des Caoutchoucs" (សាជីវកម្មហិរញ្ញវត្ថុសម្រាប់កៅស៊ូ)។

[67]"ក៏ត្រូវបានគេស្គាល់ផងដែរថាជា Socfin S.A និង Socfinal, "របាយការណ៍ប្រចាំឆ្នាំ ២០១០ របស់ សុកហ្វិន (ពីមុនត្រូវបានគេស្គាល់ថាជា Socfinal)" បញ្ចូលនៅថ្ងៃទី១០
ខែមករា ឆ្នាំ២០១១ទំព័រ 5, http://paperjam.lu/sites/default/files/old-files/fichiers_contenus/rapports_annuels/2013/socfin_2010_fr.pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ)។

Bolloré Participations S.A.[68] ដែលមានភាគហ៊ុន ២១,៧៥% នៃក្រុមហ៊ុន សុកហ្វីនណាស៊ី។[69] ម.ស.ម.ក មិនអាចកំណត់អត្តសញ្ញាណរបស់ម្ចាស់ភាគហ៊ុនដែលនៅសល់ចំនួន ២០,៤៥% បានទេ។

ក្រុមហ៊ុន សុកហ្វីន គ្រុប[70] គឺជាក្រុមហ៊ុនដែលមានជំនាញឯកទេសផ្នែកអភិវឌ្ឍន៍ និងគ្រប់គ្រងការដាំដុះដូងប្រេង និងកៅស៊ូដែលកំពុងគ្រប់គ្រងលើគម្រោងកសិឧស្សាហកម្មចំនួន១៥ ដែលភាគច្រើនគឺស្ថិតនៅក្នុងទ្វីបអាហ្វ្រិក។[71] ក្រុមហ៊ុននេះបានធ្វើប្រតិបត្តិការតាមរយៈបណ្ដាញ ដែលប្រទាក់ក្រឡាគ្នារបស់ក្រុមហ៊ុនមេដូចជាក្រុមហ៊ុន សុកហ្វីនណាស៊ី នៃក្រុមហ៊ុនដែលធ្វើប្រតិបត្តិការ និងបុត្រសម្ព័ន្ធ[72] ហើយដែលបានប្រកាសប្រាក់ចំណូលរបស់ខ្លួនចំនួន ៦២៥.៨ លានអឺរ៉ូ (ច្រើនជាង ៧២៤ លានដុល្លារអាមេរិក)។[73] ភាគហ៊ុន ៥៤,២៤% របស់ក្រុមហ៊ុន សុកហ្វីនគ្រុប ផ្ទាល់ត្រូវបានកាន់កាប់ដោយមហាសេដ្ឋីជនជាតិប៊ែលហ្សិកម្នាក់ឈ្មោះ Hubert Fabri និង ៣៨,៧៥% ត្រូវបានកាន់កាប់ដោយ Bolloré Participations។[74] ដូច្នេះ Hubert Fabri កាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន សុកហ្វីនណាស៊ី[75] ចំនួន ៣១% ខណៈ Bolloré Participations កាន់កាប់ភាគហ៊ុនចំនួន ៤៤%[76] ដែលធ្វើឱ្យក្រុមហ៊ុននេះក្លាយជាម្ចាស់ភាគហ៊ុនធំនៃក្រុមហ៊ុន សុកហ្វីនណាស៊ី ហេតុដូច្នេះហើយបានជាក្រុមហ៊ុន សុកហ្វីន ខឺឌីស៊ី ដូចដែលយើងបានលើកឡើងខាងលើត្រូវបានកាន់កាប់ ១០០% ដោយក្រុមហ៊ុន សុកហ្វីនណាស៊ី។ ក្រៅពីការកាន់កាប់ភាគហ៊ុនហិរញ្ញវត្ថុធំៗនៅក្នុងក្រុមហ៊ុន សុកហ្វីនណាស៊ី លោក Vincent Bolloré និងលោក Hubert Fabri សុទ្ធតែមានឈ្មោះនៅក្នុងបញ្ជីសមាជិកក្រុមប្រឹក្សានៃក្រុមហ៊ុនសុកហ្វីន ខេស៊ីឌី នៅក្នុងគេហទំព័រចុះបញ្ជីការពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ Luc Jacques J. Boedt បានចុះឈ្មោះជាប្រធានក្រុមប្រឹក្សាភិបាល។[77] គិតត្រឹមឆ្នាំ ២០១៨ លោក Hubert Fabri គឺជាប្រធាននៃក្រុមប្រឹក្សាភិបាល ('conseil d'administration') សម្រាប់ក្រុមហ៊ុន សុកហ្វីនសុកហ្វីនណាស៊ី និងជាសមាជិកក្រុមប្រឹក្សាភិបាល ('administrateur') របស់ក្រុមហ៊ុនសុកហ្វី ខេស៊ីឌី ។[78] Vincent Bolloré គឺជាសមាជិកនៃក្រុមប្រឹក្សា

---

[68] "S.A. ជាពាក្យកាត់មកពី "société anonyme", គឺជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតសាធារណៈដែលដាក់កម្រិតការទទួលខុសត្រូវរបស់ម្ចាស់ទៅលើសកម្មភាពក្រុមហ៊ុន។សម្រាប់ព័ត៌មានបន្ថែម *សូមមើល* https://www.investopedia.com/terms/s/socit-anonyme.asp.

[69] "របាយការណ៍ប្រចាំឆ្នាំ ២០១៧ របស់ Socfinasia", ទំព័រ 30, http://www.socfin.com/frontend/files/userfiles/files/Asia%20RA%202017.pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ) *សូមមើលផងដែរ* "ព័ត៌មានដែលត្រូវបានគ្រប់គ្រង", ការផ្សព្វផ្សាយពីហិរញ្ញវត្ថុរបស់ Socfinasia ឆ្នាំ២០១៧ http://www.socfin.com/en/investors/socfinasia/financial-publications.

[70] "ត្រូវបានគេស្គាល់ផងដែរថាជា Socfin S.A.

[71] "Socfin Group អំពីយើង http://www.socfin.com/en.

[72] "រចនាសម្ព័ន្ធក្រុមហ៊ុន Socfin, http://www.socfin.com/en/socfin-group/organisation-chart.

[73] "Socfin Group អំពីយើង http://www.socfin.com/en/socfin-group.

[74] "របាយការណ៍ប្រចាំឆ្នាំ២០១៧ របស់ក្រុមហ៊ុន សុកហ្វិន ", ទំព័រ 22, http://www.socfin.com/frontend/files/userfiles/files/SOCFIN%20RA%202017.pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ).

[75] "៥៤,២៤% នៃ ៥៧,៣៩%.

[76] "របាយការណ៍ប្រចាំឆ្នាំ២០១៧ របស់ក្រុមហ៊ុន សុកហ្វិន ", ទំព័រ 22, http://www.socfin.com/frontend/files/userfiles/files/SOCFIN%20RA%202017.pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ).

[77] "ការចុះបញ្ជីការអាជីវកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្រុហ៊ុន Socfin KCD Co. LTD, អាសយដ្ឋាន, នាយក, http://business.sithi.org/show_report_detail_land.php?id=68&lang=en; ទាញយកនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ពី https://www.businessregistration.moc.gov.kh/, *សូមមើល* សេវាកម្មអនឡាញ", "ស្វែងរកអង្គភាព", ឈ្មោះអង្គភាព៖ សុកហ្វិន; ចុះបញ្ជី៖ទាំងអស់។

[78] "របាយការណ៍ប្រចាំឆ្នាំសម្រាប់ឆ្នាំ ២០១៨ របស់ *Compagnie du Cambodge's*", ទំព័រ 25, http://www.compagnie-du-cambodge.com/DownloadHandler.ashx?url=/media/66204/rapport_annuel_cambodge_-_vamf_6_-_20180427.pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ).

ភិបាលរបស់ក្រុមហ៊ុន សុកហ្វីន ណាស៊ី និង សុកហ្វីន។[79] នៅក្នុងរបាយការណ៍ចីរភាពឆ្នាំ២០១៧ របស់ខ្លួន Hubert Fabri ត្រូវបានប្រកាសណែនាំខ្លួនថាជាប្រធាននៃ សុកហ្វីន អេស្ស.អេ (សុកហ្វីន គ្រុប)។[80]

Bolloré Participations គឺជាក្រុមហ៊ុនវិនិយោគមេដែលមានលោក Vincent Bolloré សេដ្ឋីជនជាតិបារាំងជានាយក ហើយក៏ជាអ្នកដែលកាន់កាប់ក្រុមហ៊ុន Bolloré group ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនធំៗបំផុតទាំង ៥០០ នៅលើពិភពលោក ហើយដែលបានរាយការណ៍ចំណូលសុទ្ធរបស់ខ្លួនចំនួន ២.០៨១ លាន អឺរ៉ូ សម្រាប់ឆ្នាំ២០១៧ (ប្រមាណជា ២.៣៧៣ លានដុល្លាអាមេរិក)។[81] ក្រុមហ៊ុននេះគ្រប់គ្រងលើផលប័ត្រភាគហ៊ុនដែលមានតម្លៃច្រើនជាង ៧,៤ លានអឺរ៉ូ (៨,៥ ពាន់លានដុល្លាអាមេរិក) គិតត្រឹមចុងឆ្នាំ ២០១៧។[82] លោក Vincent Bolloré ក៏មានឈ្មោះនៅក្នុងបញ្ជីមហាសេដ្ឋីពាន់លានរបស់ Forbes លំដាប់ ទី២០៧ ផងដែរ ដែលមានទ្រព្យប្រហាក់ប្រហែល នឹង ៧.៤ ពាន់លានដុល្លាអាមេរិកសម្រាប់ឆ្នាំ២០១៨។[83]

សុកហ្វីន អេស្ស.អេ ត្រូវបានរាយការណ៍ថាបានអនុវត្តតាមគោលនយោបាយគ្រប់គ្រងដែលមានការទទួលខុសត្រូវ[84] ហើយនៅក្នុងខែមករា ឆ្នាំ២០១៧ ក្រុមហ៊ុននេះបានប្តេជ្ញាចិត្តលើការគ្រប់គ្រងប្រកបដោយចីរភាពលើចម្ការកៅស៊ូរបស់ខ្លួននៅក្នុងខេត្តមណ្ឌលគីរី។[85] ទោះជាយ៉ាងណា ការចោទប្រកាន់ទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស ដែលរួមមានកង្វះខាតការពិគ្រោះយោបល់ជាមុន ការបណ្តេញចេញដោយបង្ខំ ការដណ្តើមយកដីធ្លី ការផ្តល់សំណងមិនយុត្តិធម៌ ការបំពុលបរិស្ថាន និងលក្ខខណ្ឌការងារនិងការរស់នៅមិនល្អនៅលើដីសម្បទានរបស់ខ្លួន ត្រូវបានធ្វើឡើងប្រឆាំងនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធជាច្រើនរបស់ក្រុមហ៊ុននេះនៅទូទាំងពិភពលោក។[86] នៅក្នុងឆ្នាំ ២០១១ របាយការណ៍របស់សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស («អេហ្វ.អាយ.ឌី.អេច»)

---

[79] "របាយការណ៍ប្រចាំឆ្នាំ ២០១៨ របស់ *Compagnie du Cambodge's*", ទំព័រ 26, http://www.compagnie-du-cambodge.com/DownloadHandler.ashx?url=/media/66204/rapport_annuel_cambodge_-_vamf_6_-_20180427.pdf (មានតែជាភាសាបារាំងប៉ុណ្ណោះ)

[80] "នៅក្នុងរបាយការណ៍និរន្តរភាពឆ្នាំ 2017 របស់ខ្លួន Socfin S.A. បានយោងទៅនីតិវិធីគ្រប់គ្រងបណ្តឹងសារទុកខាងក្រៅនៅកម្ពុជាដែលបានបង្ហាញជាផ្លូវការទៅកាន់សហគមន៍ និងអាជ្ញាធរ "របាយការណ៍ចីរភាព ឆ្នាំ2007 កសិកម្មតំបន់ត្រូពិចប្រកបដោយការទទួលខុសត្រូវ" សុកហ្វិន , ទំព័រ 6 "សារពីប្រធាន" http://www.socfin.com/frontend/files/userfiles/files/2017%20Socfin_Sustainability%20report_LR.pdf.

[81] "Bolloré Group, តួលេខសំខាន់ៗ, http://www.bollore.com/en-us/investors/key-figures.

[82] "Bolloré Group, មូលបត្រនៃម្ចាស់ភាគហ៊ុន, http://www.bollore.com/en-us/activities/portfolio-of-shareholdings.

[83] "#207 Vincent Bolloré និងគ្រួសារ", *Forbes*, https://www.forbes.com/profile/vincent-bollore/?list=billionaires#4298a6f16651.

[84] "គោលនយោបាយសម្រាប់ការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវរបស់ Socfin Group",*Socfin*,ថ្ងៃទី២២ខែមីនាឆ្នាំ២០១៧, http://www.socfin.com/frontend/files/userfiles/files/2017_03_22_Policy_responsible_management.pdf.

[85] "SOCFIN នៅក្នុងប្រទេសកម្ពុជាមានការប្តេជ្ញាចិត្តលើការគ្រប់គ្រងប្រកបដោយនិរន្តរភាពលើចំការកៅស៊ូរបស់ខ្លួននៅក្នុងខេត្តមណ្ឌលគីរី",សុកហ្វិន, ថ្ងៃទី 9 ខែមករា ឆ្នាំ 2017, http://www.socfin.com/en/news/detail/socfin-in-cambodia-commits-to-a-sustainable-management-of-its-rubber-plantations-in-mondulkiri

[86] "កសិករស្វែងរកការសាកសួរព័ត៌មានបន្ថែមទៅលើបញ្ហាចំរូងចំរាសនៃការព្រមព្រៀងរបស់ក្រុមហ៊ុនដូងប្រេង Sierra Leone",*VOA News*,ថ្ងៃទី០៥ខែមេសាឆ្នាំ២០១៧, https://www.voanews.com/a/farmers-seek-independent-inquiry-controversial-sierra-leone-palm-oil-deal/3798486.html; "ក្រុមហ៊ុនដូងប្រេងដែលកំពុងស្ថិតនៅចំណុចកណ្តាលនៃការតស៊ូដ៏ជូចត់លើសិទ្ធិដីធ្លីនៅក្នុងប្រទេសកាមេរ៉ូន",*The Guardian*, ថ្ងៃទី២៧ខែកក្កដាឆ្នាំ២០១៥, https://www.theguardian.com/sustainable-business/2015/jul/27/palm-oil-boom-cameroon-land-ownership-protest;"វិវាទជុំវិញបញ្ហាចំការរបស់ Socfin-Bolloré៖ការកាន់កាប់ថ្មីនៅក្នុងប្រទេសលីបេរីយ៉ា",*landgrab.org*, ថ្ងៃទី១៥ខែឧសភា ឆ្នាំ២០១៥, https://www.farmlandgrab.org/post/view/24908; "Bollore រិះគន់ទៅលើការប្រឆាំងតវ៉ាលើការទន្ទ្រានដីធ្លីនៅប្រទេសអាហ្វ្រិកអឺរ៉ុប",*Africa News*, ថ្ងៃទី០៣ ខែមិថុនាឆ្នាំ២០១៦, http://www.africanews.com/2016/06/03/bollore-criticized-at-anti-land-grabbing-protests-in-africa-europe/;ការស៊ើបអង្កេតលើការវិនិយោគរបស់ Bolloré Group និងដៃគូជនជាតិប៊ែលហ្សិកលោក Hubert Fabri, ព្រៃរបស់ប្រទេសអាហ្វ្រិកដែលរងការគំរាមកំហែង", *Greenpeace*, ខែកុម្ភៈ ឆ្នាំ២០១៦, ទំព័រ 8, https://www.greenpeace.org/africa/Global/africa/publications/forests/2016/AFRICA'S_FORESTS_UNDER_THREAT_1.pdf.

ស្តីពីទំនាស់ដីធ្លីនៅឃុំប៊ូស្រា ត្រូវបានប្រានចោលដោយក្រុមហ៊ុន សុកហ្វីនគ្រុប ដោយចាត់ទុកថាមានលក្ខណៈលម្អៀង មិនអាចទុកចិត្តបាន និងជាការបង្កូចកេរ្តិ៍ឈ្មោះ។[87] លោក Hubert Fabri បានចេញមុខជានាថាក្រុមហ៊ុន សុកហ្វីន បានគោរពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិក្នុងប្រតិបត្តិការរបស់ខ្លួននៅក្នុងខេត្តមណ្ឌលគីរី[88] ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ បានលើកពីគោលបំណងចង់ប្តឹងផ្តល់ពីបទបង្កូចកេរ្តិ៍ឈ្មោះប្រឆាំងនឹង អេហ្វ.អាយ.ឌី.អេច។[89] នៅក្នុងឆ្នាំ២០១៥ ក្រុមហ៊ុន សុកហ្វីន អេស្ស.អេ បានស្នើសុំប្រាក់កម្ចីចំនួន ១៥០លានអឺរ៉ូ[90] ពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ («អាយ អេហ្វ ស៊ី») ដែលជាស្ថាប័នហិរញ្ញវត្ថុមួយនៃ ក្រុមធនាគារពិភពលោក[91] ដែលជាស្ថាប័នផ្តល់ប្រាក់កម្ចីពាក់ព័ន្ធនឹងការអភិវឌ្ឍដល់តួអង្គ នៅក្នុងវិស័យឯកជននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។[92] នៅពេលមានការពិនិត្យទៅលើពាក្យស្នើសុំរបស់ក្រុមហ៊ុន សុកហ្វិន អេស្ស.អេ គេបានសម្គាល់ឃើញថាមាន «គម្លាតយ៉ាងធំ» រវាងការអនុវត្តរបស់ក្រុមហ៊ុន សុកហ្វីន អេស្ស.អេ និងបទដ្ឋានសង្គម និងបរិស្ថានអន្តរជាតិដែលត្រូវអនុវត្ត។[93]

## ករណីរបស់ក្រុមហ៊ុន អឹម ឌី អេស

ករណីចុងក្រោយពាក់ព័ន្ធនឹងទំនាស់ដីធ្លីនៅក្នុងឃុំថ្មដា[94] ស្រុកវាលវែល ខេត្តពោធិ៍សាត់ ជាប់នឹងព្រំដែនប្រទេសថៃ។ មានគ្រួសារយ៉ាងហោចណាស់ ៩៧គ្រួសារ មកពីភូមិចំនួនបីផ្សេងៗគ្នាដែលទទួលរងផលប៉ះពាល់ពីទំនាស់ដីធ្លីនេះ។[95] រហូតមកដល់ពេលបច្ចុប្បន្ននេះ មានគ្រួសារចំនួន ១៥គ្រួសារ ដែលកំពុងស្វែងរកដំណោះស្រាយ។

---

[87] "សិទ្ធិរបស់ សុកហ្វិន ក្នុងការឆ្លើយតបទៅនឹងរបាយការណ៍របស់ FIDH", *Socfin*, ថ្ងៃទី១០ខែ វិច្ឆិកាឆ្នាំ២០១១, https://www.fidh.org/IMG/pdf/droit_de_reponse_socfin_novembre_2011.pdf('ការឆ្លើយតបរបស់ Socfin ទៅនឹងរបាយការណ៍របស់ FIDH)។

[88] "អនុសញ្ញាជនអន្តោគ្រាម និងកុលសម្ពន្ធ" ឆ្នាំ 1989 (លេខ. 169), អង្គការពលកម្មអន្តរជាតិ ថ្ងៃទី២៧ខែមិថុនាឆ្នាំ១៩៩៩, https://www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:12100:0::NO::P12100_ILO_CODE:C169.

[89] "ការឆ្លើយតបរបស់ សុកហ្វិន ទៅនឹងរបាយការណ៍របស់ FIDH។

[90] "ម.ស.ម.ក ទទួលបានសេចក្តីសង្ខេបពីការត្រួតពិនិត្យលើសង្គម និងបរិស្ថានរបស់ IFC ក៏ដូចជាផែនការសកម្មភាពសង្គម និងបរិស្ថានដែលអាចរកបានពីគេហទំព័ររបស់ IFC ក្នុងឆ្នាំ ២០១៥ ទោះជាយ៉ាងណា មកដល់បច្ចុប្បន្នព័ត៌មានទាំងនោះមិនមាននៅលើគេហទំព័ររបស់ IFC ទៀតទេ។ឥណទានសាជីវកម្មរបស់ Socfin Corporate Loan, សេចក្តីសង្ខេបការពីការត្រួតពិនិត្យលើសង្គម និងបរិស្ថាន, *IFC*, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥, http://business.sithi.org/show_report_detail_land.php?id=69&ng=enឥណទានរបស់ក្រុមហ៊ុន Socfin (លេខ៖ ៣៥៩៣០) – ផែនការសកម្មភាពសង្គម និងបរិស្ថានសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥, http://business.sithi.org/show_report_detail_land.php?id=70&lang=en.

[91] "Socapalm Specific Instance – Bolloré និង Socfin Groups, សេចក្តីថ្លែងការណ៍ចេញពីចំណុចទំនាក់ទំនងជាតិបារាំង នៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១៦", ចំណុចទំនាក់ទំនងជាតិបារាំង, ទំព័រ 5-6, https://www.tresor.economie.gouv.fr/Ressources/File/426854; *សូមមើលផងដែរ* "ការស៊ើបអង្កេតលើការវិនិយោគរបស់ Bolloré Group និងដៃគូជនជាតិប៊ែលហ្ស៊ិករបស់ខ្លួន លោក Hubert Fabri, ព្រៃអាហ្វ្រិកដែលរងការគំរាមកំហែង", *Greenpeace*, ខែកុម្ភៈ ឆ្នាំ២០១៦ទំព័រ ៨ https://www.greenpeace.org/africa/Global/africa/publications/forests/2016/AFRICA'S_FORESTS_UNDER_THREAT_1.pdf.

[92] "អំពីយើង", *IFC*, https://www.ifc.org/wps/wcm/connect/corp_ext_content/ifc_external_corporate_site/about+ifc_new.

[93] "Socapalm Specific Instance – Bolloré និង Socfin Groups សេចក្តីថ្លែងការណ៍ចេញពីចំណុចទំនាក់ទំនងជាតិបារាំងនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦" *ចំណុចទំនាក់ទំនងជាតិបារាំង*ទំព័រ 5, https://www.tresor.economie.gouv.fr/Ressources/File/426854.

[94] "ភូមិចំនួន ៣មកពីឃុំនេះ៖ភូមិឯកភាព ភូមិកណ្តាលនិងភូមិសង្គមថ្មី។

[95] "សង្គមថ្មី កណ្តាល និងឯកភាព។ភូមិសង្គមថ្មី ភូមិកណ្តាល និងភូមិឯកភាព។ *សូមមើល* "របាយការណ៍សង្ខេបស្តីពីផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន MDS នៅក្នុងឃុំថ្មដា ស្រុកវាលវែងខេត្តពោធិសាត់", របាយការណ៍រួមគ្នា *អង្គការ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា,អង្គការសម្ព័ន្ធភាពការពារ*

## តំបន់សេដ្ឋកិច្ចពិសេស

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ រដ្ឋាភិបាលកម្ពុជា បានអនុម័តលើការបង្កើតតំបន់សេដ្ឋកិច្ចពិសេសថ្មដា អឹម.ឌី.អេស («អេស.អ៊ី.ហ្សិត») នៅក្នុងឃុំថ្មដា។[96] ហើយតំបន់សេដ្ឋកិច្ចពិសេសនេះត្រូវបានផ្តល់ឱ្យក្រុមហ៊ុនកម្ពុជាមួយឈ្មោះ ក្រុមហ៊ុន អឹម.ឌី.អេសថ្មដា អេស.អ៊ី.ហ្សិត ខូ.អិល.ធី.ឌី («អឹមឌីអេស»)។ តំបន់សេដ្ឋកិច្ចពិសេសនេះត្រូវបានរៀបចំឡើងដោយបញ្ចូលនូវៈ ទីផ្សារនាំចេញនាំចូលដើម្បីផ្លាស់ប្តូរទំនិញ ឃ្លាំងសម្រាប់ផលិតផលកសិកម្ម កាស៊ីណូ[97] ក្លឹបវាយកូនហ្គោល ក្លឹបហាត់ប្រាណ ចំណតយានយន្ត និងស្ថានីយ៍ប្រេងឥន្ធនៈ នៅលើផ្ទៃដី ២.២៦៥ហិកតា។[98] នៅក្នុងខែតុលា ឆ្នាំ២០១០ មុនពេលដែលតំបន់សេដ្ឋកិច្ចពិសេសទទួលបានការអនុញ្ញាត ក្រុមហ៊ុន អឹម ឌី អេស បានចាប់ផ្តើមឈូសឆាយដីដោយបានបំផ្លាញផ្ទះ និងទ្រព្យសម្បត្តិ និងឈូសឆាយលុបដីស្រែចម្ការផងដែរ។ ការឈូសឆាយបានបន្តរហូតដល់ឆ្នាំ២០១៤ ទោះបីជាមានការខិតខំប្រឹងប្រែងជាច្រើនពីសហគមន៍ដើម្បីស្វែងរកដំណោះស្រាយក៏ដោយ។ នៅក្នុងខែឧសភា ឆ្នាំ២០១៨ អាជ្ញាធរសាធារណៈបានប្រាប់ ម.ស.ម.កថា តំបន់សេដ្ឋកិច្ចពិសេសនោះត្រូវបានធ្វើរួចរាល់ ៦០-៧០% ហើយ និងថាពួកគេបានទទួលផែនការមេរបស់អាជ្ញាធរខេត្តសម្រាប់តំបន់សេដ្ឋកិច្ចពិសេស ហើយប៉ុស្តិ៍/ច្រកទ្វាររដ្ឋបាលនឹងត្រូវបានបង្កើតឡើងនៅព្រំប្រទល់កម្ពុជា/ថៃ ដើម្បីសម្រួលដល់ពាណិជ្ជកម្មផលិតផលកសិកម្ម ដោយប្រើប្រាស់បរិវេណនាំចេញ/នាំចូលនៃតំបន់សេដ្ឋកិច្ចពិសេស អឹមឌីអេស។ ពួកគេបានបន្ថែមទៀតថា នៅពេលដែលផ្លូវធ្វើដំណើរពីក្រុងពោធិ៍សាត់ទៅឃុំថ្មដា ដែលបច្ចុប្បន្នកំពុងសាងសង់ត្រូវបានបញ្ចប់នោះ ដំណើរការអភិវឌ្ឍរបស់តំបន់សេដ្ឋកិច្ចពិសេសនឹងមានសន្ទុះកើនឡើង។ អាជ្ញាធរបានធានាថា នឹងពន្លឿនដំណើរការដោះស្រាយទំនាស់ដើម្បីធានាថាដំណើរការទាំងមូលអាចធ្វើទៅបានដោយមិនមានការរារាំង។ សមាជិកសហគមន៍បានប្រាប់ ម.ស.ម.ក ថា គ្រឿងចក្ររបស់ អឹមឌីអេស សម្រាប់ធ្វើការឈូសឆាយដីទំនាស់ត្រូវបានគេឃើញបានដាក់ត្រឡប់មកវិញនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ ដោយអមមកជាមួយនូវទាហាន និងអាជ្ញាធរមូលដ្ឋានផងដែរ ហើយការងារសាងសង់បានចាប់ផ្តើមបន្តនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសតាំងពីពេលនោះមក។

---

*សិទ្ធិមនុស្សកម្ពុជា,មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍, អាដហុក, ម.ស.ម.ក, លីកាដូ ពោធិសាត់*ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧, ទំព័រ 2-4 (មានតែឯកសារក្រដាសពីអង្គការ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជានិងម.ស.ម.ក តែប៉ុណ្ណោះ).

[96]"ទីស្តីការគណៈរដ្ឋមន្ត្រី សេចក្តីជូនដំណឹងលេខ ១៣៣៤, ដែលក្រុមប្រឹក្សារដ្ឋមន្ត្រីបានអនុម័តលើ តំបន់សេដ្ឋកិច្ចពិសេស, ដែលបានចុះនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០,http://business.sithi.org/ressource_detail.php?ressource_id=29&lang=en; ទោះជាយ៉ាងណាក៏ដោយឯកសារផ្លូវការបានយោងទៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ 2010, *សូមមើល* "ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្កើត និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស" ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០១៣, ទំព័រ 2 លេខរៀងបញ្ចូលទី 23, http://www.customs.gov.kh/wp-content/uploads/2017/04/All-Regulations-related-to-SEZ-Eng.pdf.

[97]"គេហទំព័ររបស់ក្រុមហ៊ុន ទ្រី ភាព គ្រុប (Try Pheap Group)http://trypheapgroup.com/en/?page=7.

[98]"ក្រុមប្រឹក្សារដ្ឋមន្ត្រី សេចក្តីជូនដំណឹង លេខ១៣៣៤, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០, http://business.sithi.org/ressource_detail.php?ressource_id=29&lang=en.

## អំពី អឹម ឌី អេស

នាយករបស់ក្រុមហ៊ុន អឹម.ឌី.អេសថ្មដា អេស.អ៊ី.ហ្សិតខូ.អិល.ធី.ឌី គឺជាឧកញ៉ាជនជាតិខ្មែរឈ្មោះ លោក ទ្រី ភាព[99] ដែលមានក្រុមហ៊ុនឈ្មោះ ក្រុមហ៊ុន ទ្រី ភាព គ្រុប ខូ.អិល.ធី.ឌី («ក្រុមហ៊ុន ទ្រី ភាព គ្រុប») ដែលកំពុងគ្រប់គ្រងលើតំបន់សេដ្ឋកិច្ចពិសេស។[100] សម្បទានដីសេដ្ឋកិច្ច («សម្បទានដីសេដ្ឋកិច្ច») សម្រាប់កសិឧស្សាហកម្មចំនួនពីរនៅក្នុងតំបន់នេះដែលមានផ្ទៃដីសរុបចំនួន ៦.៣៥២ហិកតា ក៏ត្រូវបានផ្តល់ជូនឱ្យទៅក្រុមហ៊ុន អឹមឌីអេស នាំចេញនាំចូល[101] ដែលកាន់កាប់ដោយលោក ទ្រី ភាព[102] ផងដែរ។ ក្រុមហ៊ុន ទ្រី ភាព គ្រុប គឺជាក្រុមហ៊ុនកម្ពុជាដ៏ធំមួយដែលមានដំណើរការលើសកម្មភាពអាជីវកម្មជាច្រើនរួមមានកសិឧស្សាហកម្ម ទេសចរណ៍ អាជីវកម្មសណ្ឋាគារ សិប្បកម្ម ផែស្ងួត តំបន់សេដ្ឋកិច្ចពិសេស និងចែកចាយប្រេងឥន្ធនៈ។[103] លោក ទ្រី ភាព កាន់កាប់ក្រុមហ៊ុនយ៉ាងតិចចំនួន ២២ នៅក្នុងប្រទេសកម្ពុជា។[104]

---

[99] "ចុះបញ្ជិការអាជីវកម្មកម្ពុជា MDS Thmorda SEZ Co LTD, នាយក, http://business.sithi.org/show_report_detail_land.php?id=72&lang=en, ទទួលបាននៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨https://www.businessregistration.moc.gov.kh/ on ,"សេវាកម្មអនឡាញ", "ស្វែងរកអង្គភាព", ឈ្មោះអង្គភាព៖ MDS; ចុះ បញ្ជីទាំងអស់។

[100] "គេហទំព័រផ្លូវការរបស់ Try Pheap Group, "តំបន់សេដ្ឋកិច្ចពិសេស", Try Pheap Group Co., Ltd, ឆ្នាំ 2018, http://bit.ly/2Dangrz.

[101] "ព័ត៌មានអំពីការវិនិយោគរបស់សាលាក្រុង និងខេត្ត "ខេត្តពោធិសាត់", *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*, ខែមីនា ឆ្នាំ២០១៤, ទំព័រ 113, http://www.cambodiainvestment.gov.kh/wp-content/uploads/2014/03/Pursat-Province_eng.pdf.

[102] "*សូមមើល* ការចុះបញ្ជិការពាណិជ្ជកម្មកម្ពុជា (ក្រុមហ៊ុន MDS Import Export Co LTS, ព័ត៌មានទូទៅ), http://business.sithi.org/show_report_detail_land.php?id=73&lang=en និងនាយក, http://business.sithi.org/show_report_detail_land.php?id=74&lang=en, ទទួលបាននៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ពី https://www.businessregistration.moc.gov.kh/.

[103] "គេហទំព័រ Try Pheap Group's, "អាជីវកម្មរបស់យើង", http://trypheapgroup.com/en/?page=1#.

[104] "Open Corporate, ទ្រី ភាពត្រូវបានចុះឈ្មោះជានាយក ឬប្រធាននៃក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនចំនួន ២២ https://opencorporates.com/officers?q=Try+PHEAP. សម្រាប់ព័ត៌មានពីសាវតារសូមមើល 'The Cost of Luxury', អង្គការ *Global Witness*, ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ , https://www.globalwitness.org/en/campaigns/forests/cost-of-luxury/; ការកាប់ឈើមានតម្លៃ" *ឌឹភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៣, https://www.phnompenhpost.com/national/logging-mogul-blasted; "របាយការណ៍កោះហៅ ទ្រីភាព ដោយភ្នំពេញប៉ុស្តិ៍", *កងកម្លាំងការងារសិទ្ធិមនុស្សកម្ពុជា* ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣, http://chrtf.blogspot.com/2013/12/report-calls-out-try-pheap-by-phnom.html; "ដែលទទួលបានអត្ថប្រយោជន៍ពីការផុតរលត់នៃលទ្ធិប្រជាធិបតេយ្យ", *Global Witness*, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨, https://www.globalwitness.org/en/campaigns/cambodia/who-profits-death-cambodias-democracy/. មន្ត្រីរបស់ក្រុមហ៊ុន MDS និងទ្រីភាពបានបដិសេធជាប្រព័ន្ធលើរាល់ការរំលោភបំពាន ឬការប្រព្រឹត្តិខុសឆ្គង *សូមមើលឧ.* "ការកាប់ឈើមានតម្លៃ" *ឌឹភ្នំពេញប៉ុស្តិ៍* 29 Oct 2013, https://www.phnompenhpost.com/national/logging-mogul-blastedb

## របកគំហើញ និងការបកស្រាយ

### របកគំហើញទី១៖ សិទ្ធិមានកម្មសិទ្ធិ គួរត្រូវបានត្រួតពិនិត្យបញ្ជាក់ឲ្យត្រឹមត្រូវ

**សាវតារប្រវត្តិសាស្ត្រ**

នៅចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ក្នុងសម័យរបបខ្មែរក្រហម ប្រជាពលរដ្ឋមួយផ្នែកធំត្រូវបានជម្លៀស ឯកសាររដ្ឋបាលត្រូវបានខូចខាត ឬបាត់បង់ ហើយគោលការណ៍នៃម្ចាស់កម្មសិទ្ធិសមូហភាពត្រូវបានដាក់ឲ្យប្រើប្រាស់។ ប្រជាពលរដ្ឋបានភៀសខ្លួនចេញពីផ្ទះរបស់ពួកគេដែលបន្ទាប់មកត្រូវបានកាន់កាប់ដោយអ្នកដទៃ ដែលបានភៀសខ្លួនចេញពីផ្ទះរបស់ពួកគេដាដើម។

នៅចុងបញ្ចប់នៃរបបនេះ អ្នកខ្លះបន្តរស់នៅកន្លែងដែលពួកគេធ្លាប់នៅ អ្នកផ្សេងទៀតបានព្យាយាមត្រឡប់ទៅកន្លែងដែលពួកគេធ្លាប់រស់នៅមុនសង្គ្រាម។ ដោយសារតែនៅពេលនោះមិនទាន់មានឯកសារកម្មសិទ្ធិផ្លូវការមានតែតាមរយៈការបញ្ជាក់ប៉ុណ្ណោះដែលបង្កើតឲ្យមានជាកម្មសិទ្ធិបុគ្គលបាន។ អាជ្ញាធរមូលដ្ឋានដើរតួនាទីសំខាន់នៅក្នុងការទទួលស្គាល់នេះ ក៏ប៉ុន្តែពួកគេត្រូវអនុវត្តតាមការណែនាំរបស់អាជ្ញាធរជាន់ខ្ពស់ ដែលជាញឹកញាប់ គឺមានចំណាប់អារម្មណ៍ទៅលើដី ដែលត្រូវបានប្រើប្រាស់សម្រាប់គម្រោងអភិវឌ្ឍទុកឲ្យអាជ្ញាធរមូលដ្ឋានស្ថិតក្នុងស្ថានភាពមួយដ៏លំបាក ហើយអ្នកភូមិក៏ពុំមានសិទ្ធិលើកម្មសិទ្ធិដីជាផ្លូវការឡើយ។

នៅក្នុងឆ្នាំ២០១៧ ក្រុមធនាគារពិភពលោកបានរកឃើញថា «តំបន់ពាក់ព័ន្ធដែលមានបញ្ហានេះ គឺមានកង្វះខាតលើការចុះបញ្ជី និងកំណត់ដីធ្លីរបស់រដ្ឋឱ្យបានគ្រប់ជ្រុងជ្រោយ ដែលធ្វើឱ្យមានការសម្រេចចិត្តមិនមានប្រសិទ្ធិភាព និងតម្លាភាព ទៅលើការប្រើប្រាស់ទ្រព្យរបស់រដ្ឋ»។[105]ហើយក៏មានការកត់សម្គាល់បន្ថែមទៀតថាសម្បទានដីនិងរ៉ែត្រូវបានធ្វើឡើងដោយ «មិនមានព័ត៌មានត្រឹមត្រូវពីទីតាំង និងទំហំដី» និងដោយពុំមាន «ការពិចារណាឱ្យបានត្រឹមត្រូវលើដីជាក់ស្តែង ដែលប្រើប្រាស់នៅថ្នាក់មូលដ្ឋាន»[106] ហើយប្រជាពលរដ្ឋក្រីក្រជាច្រើនត្រូវបានទុកចោលដោយពុំមានសិទ្ធិក្នុងការកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាពឡើយ។[107]នៅក្នុងករណីទាំងបី ដែលត្រូវបានលើកមកពិភាក្សានៅទីនេះ ស្របពេល មានបណ្តឹងស្របច្បាប់លើដីធ្លីដែលពួកគេបានរស់នៅជាច្រើនទសវត្សរ៍។ ប្រជាពលរដ្ឋភាគច្រើន មិនមានប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការនោះទេ អ្វីដែលពួកគេមានគឺជាលិខិតពីអាជ្ញាធរមូលដ្ឋានដែលទទួលស្គាល់ពីការកាន់កាប់ដីធ្លីរបស់ពួកគេប៉ុណ្ណោះ។ ប្រជាពលរដ្ឋមួយចំនួនតូចមានប័ណ្ណកម្មសិទ្ធិដីផ្លូវការ ក៏នៅតែមិនអាចទប់ស្កាត់ ក្រុមហ៊ុននានា ឬអាជ្ញាធរដែលដកយកដីរបស់ពួកគេបានដែរ។ នៅក្នុងករណីរបស់ក្រុមហ៊ុន **មីតផ័រ ភូល** ជនរងគ្រោះបានរស់នៅលើ ឬប្រើប្រាស់ដីធ្លីទាំងនោះអស់យៈពេលជាច្រើនទសវត្សរ៍ ដែលពួកគេភាគច្រើនទទួលបានដីនោះ តាមរយៈការបែងចែកដីធ្លីពីរាជរដ្ឋាភិបាលកម្ពុជានៅចន្លោះឆ្នាំ១៩៩៥ និង២០០៥។[108] អ្នកផ្តល់បទសម្ភាសន៍ដែល ម.ស.ម.ក បានជួបសម្ភាសន៍បានលើកឡើងថា ពួកគេពុំមានប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការទេ ហើយក៏មិនបានដាក់ពាក្យស្នើសុំដែរ ដោយសារពួកគេមិនដឹងថាត្រូវធ្វើដោយរបៀបណា។ ពួកគេមានតែលិខិតពីចៅសង្កាត់បញ្ជាក់ថានេះជាកន្លែងដែលពួកគេរស់

[105]របាយការណ៍ធនាគារពិភពលោក ឆ្នាំ២០១៧ ស្តីពីកម្ពុជាទំព័រ១០០។

[106]"របាយការណ៍របស់ធនាគារពិភពលោកស្តីពីកម្ពុជា ឆ្នាំ ២០១៧ ទំព័រ១០០។

[107]"របាយការណ៍របស់ធនាគារពិភពលោកស្តីពីកម្ពុជា ឆ្នាំ ២០១៧ ទំព័រ៩៩។

[108]"ខែ មេសា ឆ្នាំ ២០១៨សកម្មភាពបណ្តឹងរបស់ក្រុមប្រជាជនថៃប្រឆាំងនឹងក្រុមហ៊ុន មីតផ័រ ភូល ទំព័រ១។

នៅ។ ទោះជាយ៉ាងណា ប្រជាពលរដ្ឋទាំងអស់នោះបានអះអាងថាពួកគេបានរស់នៅលើដីធ្លីមានទំនាស់ជាច្រើនទសវត្សរ៍មកហើយ។ អ្នកផ្សេងទៀតបានលើកឡើងថា ពួកគាត់បានកាន់កាប់មានទាំង «សលាកប័ត្រព័ត៌មាន» ដែលមានកត់ត្រាអំពីព្រំដី ទំហំដី និងឈ្មោះរបស់ម្ចាស់ដី ដែលបានផ្តល់ឱ្យពួកគេកាលពីខែកញ្ញា ឆ្នាំ២០១៧ បន្ទាប់ពីគណៈកម្មការសុរិយោដីបានកត់ត្រាឈ្មោះ និងដីរបស់ពួកគេ។ សលាកប័ត្រព័ត៌មានជាឯកសារបន្ថែមទៅលើកំណត់ត្រាអំពីអ្វីដែលគ្រួសាររងផលប៉ះពាល់បានប្រាប់អាជ្ញាធរ និងមិនមែនជាឯកសារផ្លូវការដែលទទួលស្គាល់ពីសិទ្ធិកាន់កាប់លើអចលនទ្រព្យរបស់ពួកគេទេ។ ដូចដែលបានពិភាក្សាខាងក្រោមក្នុងផ្នែកជាមួយគ្នានេះ សលាកប័ត្រព័ត៌មានទាំងអស់នោះ ត្រូវបានគេប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណគ្រួសារដែលត្រូវបានអាជ្ញាធរពិចារណាថាពួកគាត់ទទួលរងផលប៉ះពាល់ពីទំនាស់ដីធ្លី និងត្រូវបាន ដាក់ស្នើឡើងដើម្បីទទួលបានសម្បទានដីសង្គមកិច្ច («ស.ដ.ស.ក»)។

ក្នុង**ករណីរបស់ក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី** សហគមន៍ ពូនង បានរស់នៅលើដីធ្លីមានទំនាស់ជាច្រើនជំនាន់មកហើយ។ នៅក្នុងអំឡុងនៃសម័យខ្មែរក្រហម ប្រជាពលរដ្ឋនៃសហគមន៍ ពូនង ជាច្រើនត្រូវបានបង្ខំឱ្យភៀសខ្លួនចេញពីឃុំប៊ូស្រា តែពួកគេបានចាប់ផ្តើមត្រឡប់មកវិញនៅឆ្នាំ១៩៨១។ ពួកគេភាគច្រើនបានត្រឡប់មកនៅឆ្នាំ១៩៨៦ ដើម្បីបន្តការរស់នៅតាមបែបប្រពៃណីរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ សហគមន៍ជនជាតិដើមភាគតិច ពូនង មិនមានប័ណ្ណកម្មសិទ្ធិដីសមូហភាពទេ។ ពួកគេមានការចុះបញ្ជីជាជនជាតិដើមភាគតិច ក៏ដូចជានីតិបុគ្គលដែលជាតម្រូវការជាមុនចំនួនពីរដើម្បីស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។ យ៉ាងណាមិញ រហូតមកដល់ពេលនេះ ពួកគាត់មិនអាចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពបានឡើយ ដោយសារតែដីនេះត្រូវបានជួលទៅឱ្យក្រុម ហ៊ុន សុកហ៊ីន ខេស៊ីឌី ។

ក្នុង**ករណីរបស់ក្រុមហ៊ុន អឹម ឌី អេស** អ្នកភូមិដែលរងផលប៉ះពាល់ជាច្រើនបានដាក់ពាក្យទៅមន្ត្រីសុរិយោដីស្រុកដើម្បីស្នើសុំប័ណ្ណកម្មសិទ្ធិដី ទាក់ទងនឹងដីដែលបច្ចុប្បន្នស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលកិច្ចការនេះបានធ្វើឡើងពីឆ្នាំ១៩៩៩/២០០០ និងបានទទួលបង្កាន់ដៃពាក្យស្នើសុំ ប៉ុន្តែរហូតមកដល់ពេលនេះពួកគេនៅមិនទាន់ទទួលបានចម្លើយនៅឡើយទេ។ នៅក្នុងឆ្នាំ២០១២ និស្សិតស្ម័គ្រចិត្តរបស់នាយករដ្ឋមន្ត្រីបានមកវាស់វែងដីដោយអនុលោមតាមបទបញ្ជាលេខ ០០១ តែក្រុមហ៊ុន អឹម ឌី អេស បានហាមពួកគេវាស់វែងដីរបស់គ្រួសារចំនួន ២៣ ដោយលើកឡើងថាទីតាំងបែងចែកដីនោះ ជាកម្មវត្ថុនៃទំនាស់ដីធ្លីរវាងក្រុមហ៊ុន និងអ្នកភូមិ ហេតុដូច្នេះមិនអាចធ្វើការវាស់វែងបានទេ។ នៅខែមិថុនា ឆ្នាំ២០១៣ មន្ត្រីបរិស្ថានអមជាមួយអាជ្ញាធរមូលដ្ឋាន ប៉ូលិស និងអាវុធហត្ថ បានមកវាស់វែងដី។ បន្ទាប់ពីនោះមិនមានអ្វីកើតឡើងទៀតទេ។ នៅពេលដែលសហគមន៍ ទាក់ទងទៅកាន់អាជ្ញាធរមូលដ្ឋានដើម្បីសុំព័ត៌មានបន្ថែម ពួកគេបានទទួលការឆ្លើយតបថាអាជ្ញាធរមានការរវល់ខ្លាំង ហើយនឹងទាក់ទងត្រឡប់ទៅសហគមន៍វិញនៅពេលក្រោយ។

នៅក្នុងករណីទាំងបី អាជ្ញាធរមិនបានអនុវត្តនូវជំហានចាំបាច់នានាដើម្បីអះអាងថាតើសហគមន៍ដែលរងផលប៉ះពាល់មានសិទ្ធិស្របច្បាប់លើកម្មសិទ្ធិដែរឬទេ ទោះបីជាពួកគេមិនទាន់មានប័ណ្ណកម្មសិទ្ធិផ្លូវការកាន់

កាប់ដីក៏ដោយ។ សមាជិកសហគមន៍រងផលប៉ះពាល់ជាច្រើនបានដឹងយ៉ាងច្បាស់ថាពួកគេបាននៅលើដីនេះជាច្រើនទសវត្សរ៍មកហើយ ហើយសិទ្ធិកាន់កាប់ដីរបស់ពួកគេមិនដែលទទួលការជំទាស់ឡើយ ប៉ុន្តែដោយសារតែការទទួលស្គាល់ផ្លូវការលើកម្មសិទ្ធិដីធ្លី ត្រូវតែផ្អែកទៅលើអាជ្ញាធរមូលដ្ឋានដែលបានទទួលបញ្ជាពីអាជ្ញាធរជាន់ខ្ពស់ដើម្បីអនុវត្តគម្រោងសម្បទានសេដ្ឋកិច្ច ឬ តំបន់សេដ្ឋកិច្ចពិសេស ពួកគេទាំងនោះបានបង្ហាញថាពុំមានសមត្ថភាព ឬ គ្មានចេតនាក្នុងការជួយសម្រួលដល់សហគមន៍រងផលប៉ះពាល់ក្នុងការអះអាងអំពីសិទ្ធិមានកម្មសិទ្ធិរបស់ពួកគេឡើយ។ នៅក្នុងពេលជាមួយគ្នានេះផងដែរ អាជ្ញាធរជាច្រើនបានចោទថា អ្នកភូមិបានបង្កើតឯកសារកាន់កាប់ដីក្លែងក្លាយ ឬជាការពិតទៅអ្នកភូមិភាគច្រើនបានមករស់នៅទីនេះនៅពេលគម្រោងអភិវឌ្ឍន៍បានកំពុងអនុវត្តដើម្បីទទួល «អត្ថប្រយោជន៍» ពីទំនាស់ដីធ្លីហើយអះអាងថាពួកគេជាអ្នកភូមិដែលរស់នៅទីនោះយូរមកហើយ និងដើម្បីទទួលបានសំណងហិរញ្ញវត្ថុ។

## របកគំហើញទី ២៖ លក្ខខណ្ឌតម្រូវដើម្បីអនុវត្ត និងគោរពការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវដាក់ឱ្យអនុវត្ត និងតាមដាន

នៅក្នុងមាត្រា៤ នៃអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្តីពីសម្បទានដីសេដ្ឋកិច្ចបានបញ្ជាក់យ៉ាងច្បាស់ថាសម្បទានដីសេដ្ឋកិច្ចមួយអាចត្រូវបានផ្តល់ឱ្យបាន លុះត្រាតែការវាយតម្លៃហតុប៉ះពាល់បរិស្ថាន និងសង្គម[109] («ការវាយតម្លៃហតុប៉ះពាល់បរិស្ថាន និងសង្គម») ត្រូវបានធ្វើឡើងយ៉ាងពេញលេញ។ ការវាយតម្លៃហេតុប៉ះពាល់សង្គមគឺជាដំណើរការក្នុងការវិភាគតាមដាន និងគ្រប់គ្រងផលវិបាកទៅលើសង្គមទាំងចេតនានិងអចេតនា និងទាំងវិជ្ជមាន និងអវិជ្ជមាន នៃអន្តរាគមន៍ដែលបានគ្រោងទុក (គោលនយោបាយ កម្មវិធី ផែនការ គម្រោង) និងរាល់ដំណើរការផ្លាស់ប្តូរក្នុងសង្គមណាមួយដែលកើតមានឡើងដោយការអន្តរាគមន៍ទាំងនោះ។[110] ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គឺជាដំណើរការដែលចំណាយពេលវេលាច្រើន និងរួមបញ្ចូលនូវជំហានជាច្រើនដូចជា ការត្រួតពិនិត្យបឋមរហូតដល់ការសិក្សានៅថ្នាក់មូលដ្ឋាន និងការកាត់បន្ថយផលប៉ះពាល់។[111] កិច្ចការនេះចាំបាច់ត្រូវមានការពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធ ក៏ដូចជាការបង្កើតផែនការគ្រប់គ្រង បរិស្ថាន និង

---

109"សម្រាប់ព័ត៌មានបន្ថែមអំពីក្របខណ្ឌច្បាប់ដែលត្រូវអនុវត្ត *សូមមើលរបាយការណ៍របស់* FIDH, ផ្នែក៤.២ទំព័រ២៦និងទំព័របន្ទាប់។

110"សេចក្តីណែនាំគ្រប់ជ្រុងជ្រោយសម្រាប់ការវាយតម្លៃផលប៉ះពាល់សង្គម" *មជ្ឈមណ្ឌលសម្រាប់អភិបាលកិច្ចល្អ ឆ្នាំ*២០០៦កថាខណ្ឌ១.៨ http://unpan1.un.org/intradoc/groups/public/documents/cgg/unpan026197.pdf; *សូមមើលផងដែរ* "គោលការណ៍អន្តរជាតិសម្រាប់ការវាយតម្លៃផលប៉ះពាល់សង្គម ការវាយតម្លៃផលប៉ះពាល់ និងការវាយតម្លៃគម្រោង" *Frank Vanclay*, ខែមីនា ឆ្នាំ ២០០៣ ទំព័រ៥-១១, https://www.tandfonline.com/doi/pdf/10.3152/147154603781766491?needAccess=true&;"គោលការណ៍ណែនាំស្តីពីអាជីវកម្ម និងសិទ្ធិមនុស្ស", *ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំកម្ពុជា*, ឆ្នាំ ២០១១, គោលការណ៍ទី១៨, https://www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf ('UNGPs').

111"រាល់ជំហានដែលតម្រូវទាំងអស់សម្រាប់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម អាចរកមើលបាននៅក្នុង "ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម", *IFC*,ទំព័រ១, https://www.ifc.org/wps/wcm/connect/296ae980488551f5aa0cfa6a6515bb18/ESIA.pdf?MOD=AJPERES.

សង្គមផងដែរ។[112] ថ្វីបើច្បាប់មិនមានបញ្ចូលនូវលក្ខខណ្ឌតម្រូវដែលស្រដៀងគ្នាសម្រាប់ការអនុម័តលើតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា («ក.អ.ក») ដែលជាស្ថាប័នទទួលខុសត្រូវលើការបង្កើត និងធ្វើប្រតិបត្តិការលើតំបន់សេដ្ឋកិច្ចពិសេស[113] និងដែលត្រូវបានបង្កើតឡើងដោយមានទេសរដ្ឋមន្ត្រីមកពីនាយកដ្ឋានពាក់ព័ន្ធរបស់រដ្ឋាភិបាល និងដែលមាននាយករដ្ឋមន្ត្រីជាប្រធាន[114] គឺជាអង្គភាពសាធារណៈ ដែលដើរតួនាទីជំនួសរាជរដ្ឋាភិបាល ចាំបាច់ត្រូវតែគោរពសិទ្ធិមនុស្សដែលមានការទទួលស្គាល់ជាអន្តរជាតិ ដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន។[115] កិច្ចការនេះរួមមានកាតព្វកិច្ចក្នុងការការពារការរំលោភសិទ្ធិមនុស្ស ដែលតម្រូវឱ្យមានការវាយតម្លៃហតុប៉ះពាល់សង្គមដោយប្រុងប្រយ័ត្ន មុននឹងអនុម័តលើគម្រោងតំបន់សេដ្ឋកិច្ចពិសេសណាមួយ។

ក្នុង**ករណីរបស់ក្រុមហ៊ុន មីតផ័រ ភូល** ម.ស.ម.ក បានទទួលព័ត៌មានដែលគួរឱ្យទុកចិត្តបានថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវបានធ្វើឡើងដោយអាជ្ញាធរខេត្តនៅចន្លោះ ឆ្នាំ២០០៦ និងឆ្នាំ២០០៩ គឺមុនពេលដែលដីសម្បទានសេដ្ឋកិច្ចត្រូវបានអនុម័តទៅទៀត។ ទោះបីជាយ៉ាងណាក៏ដោយ យើងមិនអាចរកបានច្បាប់ចម្លងរបស់ឯកសារនេះបានឡើយ។ គួរកត់សម្គាល់ផងដែរថា តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើករណីនេះបានប្រាប់ ម.ស.ម.ក ថានៅក្នុងឯកសារនោះ ដីដែលមានទំនាស់ត្រូវបានគេចាត់ទុកថាជាដីរដ្ឋ និងតំបន់ព្រៃដែលពុំមានការប្រើប្រាស់។ នៅក្នុងឆ្នាំ២០១៨ ម.ស.ម.ក ត្រូវបានគេប្រាប់ថា មានតែការវាយតម្លៃហេតុប៉ះពាល់សង្គមមួយប៉ុណ្ណោះដែលត្រូវបានធ្វើឡើង ប៉ុន្តែពុំបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះទេ។ យ៉ាងណាក៏ដោយ ព្រោះតែលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលបានលើកឡើង

---

[112]"ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៤ មាត្រា១ http://ibccambodia.com/wp-content/uploads/2016/06/Law_on_investment_English.pdf; "តំបន់សេដ្ឋកិច្ចពិសេស និងការដេកយកអត្ថប្រយោជន៍ពីទន្លេមេគង្គ", *Focus on the Global South*, ខែកក្កដា ឆ្នាំ២០១៧ ទំព័រ១៦, កថាខណ្ឌទី២, https://focusweb.org/system/files/sezs_and_value_extraction_in_the_mekong_english.pdf.

[113]អនុក្រឹត្យលេខ ១៤៩, មាត្រា១០ (១), ១០ (៩), ១៣, ៣០, http://portal.mrcmekong.org/assets/documents/Cambodian-Law/-Sub-decree-on-Role-of-CDC-(2004).pdf.

[114]ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៤ មាត្រា១ http://ibccambodia.com/wp-content/uploads/2016/06/Law_on_investment_English.pdf; "តំបន់សេដ្ឋកិច្ចពិសេស និងការដេកយកអត្ថប្រយោជន៍ពីទន្លេមេគង្គ", *Focus on the Global South*, ខែកក្កដា ឆ្នាំ២០១៧ ទំព័រ១៦, កថាខណ្ឌទី២, https://focusweb.org/system/files/sezs_and_value_extraction_in_the_mekong_english.pdf

[115] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១,
http://sithi.org/admin/upload/law/2008_02_19_Constitution(EN)_including%20Amendment%20(1).pdf;
ការប្រើប្រាស់ដោយផ្ទាល់នូវច្បាប់ និងបទប្បញ្ញត្តិអន្តរជាតិទាំងនេះត្រូវបានទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ព្រះរាជាណាចក្រកម្ពុជា 'ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ' ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៨, សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧;
*សូមមើលផង*អនុក្រឹត្យលេខ ១៤៨ ស្តីពីការបង្កើត និងគ្រប់គ្រងនៃតំបន់សេដ្ឋកិច្ចពេសេស ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥
http://www.cambodiainvestment.gov.kh/sub-decree-148-ankr-bk-on-the-establishment-and-management-of-the-special-economic-zone-final_060314.html ('អនុក្រឹត្យលេខ១៤៨'), មាត្រា១១ ដែលបានចែងថាសិទ្ធិ និងការការពារដែលមាននៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាត្រូវប្រើប្រាស់នៅក្នុងក្របខណ្ឌ និងបានបញ្ជាក់ថាកម្មករមានសិទ្ធិទទួលបានការការពារនានាដូចដែលបានបញ្ជាក់នៅក្នុង ច្បាប់ការងារឆ្នាំ ១៩៩៧ និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។ មាត្រា១៥ នៃច្បាប់ស្តីពីការវិនិយោគឆ្នាំ១៩៩៧ បានសង្ខេបពី ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលអនុវត្តលើសកម្មភាពនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស ប្រសិនបើមិនបានបញ្ជាក់នៅក្នុងអនុក្រឹត្យ, http://ibccambodia.com/wp-content/uploads/2016/06/Law_on_investment_English.pdf.

នោះមិនអាចរកបានដោយទូលាយនិងបើកចំហនោះ ដូច្នេះមិនអាចបញ្ជាក់បានថាតើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ពិតជាបានកើតឡើងមែនឬទេ។ ប្រសិនបើជាការពិតក៏ដោយ ក៏ការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម/ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានតែឯងគឺមិនគ្រប់គ្រាន់ឡើយ ផ្ទុយទៅវិញត្រូវតែមានវិធានការជាក់ស្តែង ដើម្បីកាត់បន្ថយហានិភ័យនៅក្នុងនោះផងដែរ។ យោងតាមព័ត៌មានដែលអាចរកបានគឺពុំមានសកម្មភាពបែបនេះត្រូវបានធ្វើឡើងឡើយក្នុងកំឡុងពេល ១០ ឆ្នាំ មកនេះ។

សម្រាប់**ករណីក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី** វិញ ខេស៊ីឌី បានចាប់ផ្តើមឈូសឆាយដីធ្វើចម្ការនៅ ខែមេសា ឆ្នាំ២០០៨ មុនពេលមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ[116] ហើយមុននឹងសម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ជាផ្លូវការដល់ ខេស៊ីឌី ដែលបានភ្ជាប់កិច្ចសន្យាដោយតម្រូវឱ្យមានការរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមលើដី ដែលប្រើប្រាសនិងគម្រោងសម្បទាន ដោយមិនឱ្យយឺតជាងមួយឆ្នាំគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាឡើយ[117] និងដែលកំណត់សន្យាថាការអនុវត្តកិច្ចសន្យា អាចត្រូវផ្អាកមួយផ្នែកឬទាំងស្រុង ប្រសិនបើ ខេស៊ីឌី មិនអាចគោរព «លក្ខខណ្ឌណាមួយ» នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមឬប្រសិនបើ «កើតមានទំនាស់ជាមួយនឹងប្រជាពលរដ្ឋ [...] ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លីនៅផ្នែកណាមួយនៃដីសម្បទាន»។[118] ម.ស.ម.ក ក៏បានឮពីប្រភពជាច្រើនថាការវាយតម្លៃហេតុប៉ះ ពាល់បរិស្ថាននិងសង្គម គឺជាការពិតបើទោះបីជាកាលបរិច្ឆេទដែលបានធ្វើឡើងខុសៗគ្នាក៏ដោយ ហើយព័ត៌មានភាគច្រើនបង្ហាញថាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវបានធ្វើឡើងជាច្រើនឆ្នាំក្រោយពេល ដែលសម្បទានដីសេដ្ឋកិច្ចត្រូវបានអនុម័ត។

អាជ្ញាធរមូលដ្ឋានម្នាក់ដែល ម.ស.ម.ក បានជួបកាលពី ខែឧសភា ឆ្នាំ២០១៨ បាននិយាយថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានធ្វើឡើងដោយក្រសួងបរិស្ថាន ដែលធ្វើក្រោយពេលដែលសម្បទានដីសេដ្ឋកិច្ចត្រូវបានអនុម័ត។ ពុំមានការទទួលបានព័ត៌មានណាមួយពីលទ្ធផលនៃការវាយតម្លៃនោះទេ ហើយក៏ពុំបានទទួលច្បាប់ចម្លងនៃរបាយការណ៍អំពីលទ្ធផលនោះដែរ ប៉ុន្តែថាលទ្ធផលនោះគឺគ្រប់គ្រងដោយក្រសួងបរិស្ថាន។ អាជ្ញាធរខេត្តម្នាក់បានប្រាប់ ម.ស.ម.ក ថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមត្រូវបានធ្វើ ឡើងមុនពេលដែលសម្បទានដីសេដ្ឋកិច្ចត្រូវបានអនុម័ត ប៉ុន្តែមានតែផ្នែកខ្លះប៉ុណ្ណោះហើយក៏បានទទួលស្គាល់ ថាពួកគេមិនមែនជាអ្នកទទួលខុសត្រូវចំពោះការវាយតម្លៃនេះទេ។ អ្នកដែលត្រូវបានសម្ភាស បានបន្ថែមទៀតថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម នៅតែកំពុងដំណើរការពីព្រោះដំណើរការនេះ «ត្រូវការពេលវេលា» ហើយវាស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាននៅថ្នាក់ជាតិ។ ម.ស.ម.ក ក៏ត្រូវបានគេប្រាប់ផងដែរថាក្រុម

---

[116]"ផ្អែកលើបទសម្ភាសដែលអង្គការម.ស.ម.ក ធ្វើឡើងជាមួយមន្ត្រីថ្នាក់ខេត្តម្នាក់នៅឆ្នាំ២០១៧។

[117]"មាត្រា ២, សហាសញ្ញាទី ២ hyphen.

[118]"មាត្រា ១១

ហ៊ុន សុកហ្វីន ខេស៊ីឌី បានជួលទីប្រឹក្សាដើម្បីធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ក្នុងឆ្នាំ២០០៧-២០០៨។

នៅពេលដែល ម.ស.ម.ក ជួបអ្នកតំណាងរបស់ក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី ពួកគេបានអះអាងថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវបានធ្វើឡើងដោយអាជ្ញាធរ មុនពេលដែលសម្បទានដីសេដ្ឋកិច្ចត្រូវបានអនុម័ត ហើយប្រតិបត្តិការវាយតម្លៃទាំងអស់ស្ថិតនៅក្រោមក្របខណ្ឌការងារនេះ។ ទោះជាយ៉ាងណាក៏ដោយភស្តុតាងតែមួយគត់ អំពីការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមបង្ហាញថា វាត្រូវបានធ្វើឡើងក្រោយពេលដែលសម្បទានដីសេដ្ឋកិច្ចត្រូវបានអនុម័ត។ នៅឆ្នាំ២០១១ ក្រុមហ៊ុន សុកហ្វីន គ្រុប បានពិភាក្សាអំពីសម្បទានក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី នៅក្នុងប្រទេសកម្ពុជា ហើយបានអះអាងថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមមួយត្រូវបានធ្វើឡើងចាប់ពីខែកញ្ញា ឆ្នាំ២០០៩ ហើយប្តេជ្ញាចិត្តថា នឹងគោរពអនុសាសន៍ទាំងអស់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនេះ។[119]អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អេហ្វ.អាយ.ឌី.អេច រាយការណ៍ថាត្រូវបានក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី អនុញ្ញាតឱ្យពិនិត្យមើលឯកសារឡើងវិញ ប៉ុន្តែថាត្រូវបានធ្វើឡើងតែក្នុងឆ្នាំ២០១០ ប៉ុណ្ណោះ ឬ ពីរឆ្នាំក្រោយ ពេលដែលសម្បទានដីសេដ្ឋកិច្ចត្រូវបានអនុម័តដែលរំលោភលើច្បាប់ប្រទេសកម្ពុជា។[120] លើសពីនេះទៅទៀត របាយការណ៍ស្តីពីនិរន្តរភាព ឆ្នាំ២០១៧ របស់ក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី មិនមានយោងទៅការវាយតម្លៃហេតុប៉ះពាល់សង្គមសម្រាប់សម្បទានរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាទេតែមានយោងទៅលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។[121] នៅឆ្នាំ២០១១ ក្រុមហ៊ុនសុកហ្វីនគ្រុប បានថ្លែងថាប្រតិបត្តិការឈូសឆាយដីត្រូវបានផ្អាករហូតទាល់តែដំណោះស្រាយត្រូវបានចរចាជាមួយប្រជាពលរដ្ឋក្នុងតំបន់[122] ដែលផ្ទុយទៅនឹងសកម្មភាពរបស់ខ្លួន៖ មិនត្រឹមតែក្រុមហ៊ុននៅតែបន្តឈូស ឆាយដីរបស់សហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែការអភិវឌ្ឍសម្បទានដីសេដ្ឋកិច្ចនៅតែបន្ត ដែលជាដំណាក់កាលចុងក្រោយរបស់ខ្លួនដោយមានការផលិតកៅស៊ូ ហើយរោងចក្រកែច្នៃក៏កំពុងសាងសង់ផងដែរ។[123]

ក្នុង**ករណីរបស់ក្រុមហ៊ុន អឹមឌីអេស** មន្ត្រីខេត្តពោធិ៍សាត់បានប្រាប់ ម.ស.ម.ក ថាគាត់គ្រាន់តែ «សន្មត់» ថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមត្រូវបានធ្វើ បើមិនដូច្នេះទេ តំបន់សេដ្ឋកិច្ចពិសេសមិនអាចបង្កើត

---

[119]"ការឆ្លើយតបរបស់ សុកហ្វិន ទៅនឹងរបាយការណ៍របស់ FIDH, ទំព័រទី ៣

[120]"របាយការណ៍ FIDH, ទំព័រទី ៦, ១៩

[121]"របាយការណ៍ស្តីពីចីរភាព ឆ្នាំ២០១៧", *សុកហ្វិន កម្ពុជា*, ទំព័រទី ៨, http://www.socfin.com/frontend/files/userfiles/files/SocfinCambodia%20Report%202017_Final.pdf

[122]"សិទ្ធិរបស់Socfin ក្នុងការឆ្លើយតបទៅនឹងរបាយការណ៍របស់FIDH"ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១១, ទំព័រទី ៣, https://www.fidh.org/IMG/pdf/droit_de_reponse_socfin_novembre_2011.pdf.

[123]"របាយការណ៍ស្តីពីចីរភាព ឆ្នាំ២០១៧", *សុកហ្វិន កម្ពុជា*, ទំព័រទី ៦, http://www.socfin.com/frontend/files/userfiles/files/SocfinCambodia%20Report%202017_Final.pdf; "Business insider៖ក្រុមហ៊ុនកៅស៊ូពង្រីកអានុភាពនៃការកែច្នៃ", *ភ្នំពេញប៉ុស្តិ៍*, ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨,https://www.phnompenhpost.com/business/business-insider-rubber-firm-expands-processing-power.

ឡើងទេ ប៉ុន្តែមន្ត្រីម្នាក់ទៀតបានប្រាប់ថាការវាយតម្លៃមួយត្រូវបានធ្វើឡើង ហើយបានប្រគល់ទៅឱ្យក្រសួងបរិស្ថានមួយច្បាប់។ ទាំង ម.ស.ម.ក និងសហគមន៍ដែលរងផលប៉ះពាល់មិនធ្លាប់បានឃើញលទ្ធផលនៃការវាយតម្លៃនោះទេ។

ក្នុងករណីទាំងបី ពុំមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមណាមួយដែលបានបញ្ចប់មុនពេលដែលសម្បទានដីសេដ្ឋកិច្ច ឬតំបន់សេដ្ឋកិច្ចពិសេសត្រូវបានអនុម័តឡើយ ហើយសមាជិកសហគមន៍ទាំងអស់ដែល ម.ស.ម.ក បានធ្វើការសម្ភាសន៍ បានអះអាងថាពួកគេមិនត្រូវបានពិគ្រោះយោបល់ឱ្យបានត្រឹមត្រូវឡើយ ដូចមានរៀបរាប់បន្ថែមនៅក្នុងរបកគំហើញទី៣ខាងក្រោម។ មានការបង្ហាញថែមទៀតថា បុរេលក្ខខណ្ឌសម្រាប់ការបង្កើតគម្រោងមិនត្រូវបានគោរពនោះទេ ហើយអាជ្ញាធរមូលដ្ឋានច្រើនតែដាក់កំហិតលើការអនុវត្តបទបញ្ជាថ្នាក់លើរបស់ពួកគេជាជាងធានាថារាល់ជំហានចាំបាច់ត្រូវបានគោរព។ ទោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានគេរាយការណ៍ថាបានអនុវត្តក្តី ម.ស.ម.ក មិនអាចស្វែងរកព័ត៌មានដែលបង្ហាញថា ផែនការសកម្មភាពត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធនឹងការតាមដានការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនោះឡើយ។

## របកគំហើញទី ៣៖ ត្រូវរៀបចំការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍រងផលប៉ះពាល់

ក្នុងករណីទាំងបីនេះមានចំណុចសំខាន់ពីរ៖ ទីមួយគឺអ្នកភូមិរងផលប៉ះពាល់ភាគច្រើនបានប្រាប់ ម.ស.ម.ក ថាពួកគាត់មិនបានដឹងពីគម្រោងអភិវឌ្ឍន៍ទេ រហូតទាល់តែពួកគាត់បានឃើញគេវាស់វែង/រឹបអូស/ឈូសឆាយដីរបស់ខ្លួន។ ទីពីរ គឺនៅពេលដែលពួកគាត់ប្រជុំគ្នា មុននឹងមានការបំផ្លិចបំផ្លាញ/ការរឹបអូសទ្រព្យសម្បត្តិ ពួកគាត់គ្រាន់តែបានទទួលព័ត៌មានក្នុងការជួបប្រជុំនោះតែប៉ុណ្ណោះ ដោយក្រុមអាជ្ញាធរ ឬក្រុមហ៊ុនជូនដំណឹងដល់សហគមន៍រងផលប៉ះពាល់អំពីគម្រោង និងស្នើផ្តល់សំណងហើយមិនមានការសួរនាំពីមតិយោបល់របស់បុគ្គលម្នាក់ៗឡើយ។ និយាយម្យ៉ាងទៀតបានថា មិនមានការពិគ្រោះយោបល់សមរម្យណាមួយ ដែលមតិយោបល់របស់សហគមន៍រងផលប៉ះពាល់ត្រូវបានសួរនាំ និងពិចារណាឡើយ។ អ្នកភូមិរងផលប៉ះពាល់ត្រូវបានគេប្រាប់យ៉ាងសាមញ្ញថា ពួកគាត់ត្រូវតែប្រគល់ដីធ្លីរបស់ខ្លួនឱ្យទៅគេប៉ុណ្ណោះ។

ក្នុង**ករណីក្រុមហ៊ុន មីតផល ភូល** មន្ត្រីសាធារណៈម្នាក់បានប្រាប់ ម.ស.ម.ក ថាការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ដែលត្រូវរៀបចំនៅថ្នាក់ខេត្ត។ ភាគីពាក់ព័ន្ធទាំងអស់បានរាយការណ៍ថាបានចូលរួមក្នុងដំណើរការនោះ ហើយអាជ្ញាធរថា «តែងតែទទួលយកមតិរបស់ប្រជាពលរដ្ឋជានិច្ច»។ ទោះយ៉ាងណាក៏ដោយតំណាងអង្គការមិនមែនរដ្ឋាភិបាលបានប្រាប់ ម.ស.ម.ក ថា ទោះបីមានកិច្ចប្រជុំនៅក្នុងឆ្នាំ២០០៩ក៏ដោយ ក៏គ្រាន់តែជាការពិភាក្សាជាជាងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ដោយមានការសួរនាំពីមតិយោបល់របស់អ្នកភូមិតែប៉ុណ្ណោះ។ សហគមន៍រងផលប៉ះពាល់បានបញ្ជាក់ថា ពួកគាត់មិនត្រូវបានសួរនាំឱ្យផ្តល់

មតិយោបល់ ឬគំនិតរបស់ពួកគាត់ជាទូទៅឡើយ ហើយកម្រណាស់ដែលពួកគាត់ត្រូវបានអនុញ្ញាតិឱ្យសួរនាំតែ ក៏មិនត្រូវបានគេយកចិត្តទុកដាក់ដែរ។ លើសពីនេះទៅទៀត អ្នកភូមិបានរាយការណ៍ថា ពួកគាត់ត្រូវបានអាជ្ញាធរ និងក្រុមហ៊ុនប្រាប់ថា មិនថាពួកគាត់ចុះ ឬមិនចុះហត្ថលេខាលើលិខិតស្នាមដែលចាំបាច់ទាំងនោះ ឬ យ៉ាងណាទេ ក៏ដីធ្លីរបស់ពួកគាត់នឹងត្រូវតែប្រគល់ឱ្យគេ។ អ្នកភូមិជាច្រើនបានប្រាប់ ម.ស.ម.ក ថាពួកគាត់ត្រូវបានគេគំរាមនឹងជួបផលវិបាកជាច្រើន ប្រសិនបើមិនព្រមប្រគល់ដីធ្លីរបស់ខ្លួនឱ្យទៅគេ ដោយអះអាងថាពួកគាត់ត្រូវបានគេគំរាមថា នឹងត្រូវចាប់ដាក់ពន្ធនាគារប្រសិនបើពួកគាត់មិនចាកចេញពីដីរបស់ខ្លួនទេនោះ។

ក្នុង**ករណីក្រុមហ៊ុន សុកហ៊្វីន ខេស៊ីឌី** មានលក្ខណៈជាការពិគ្រោះយោបល់ខ្លះៗប៉ុន្តែ ម.ស.ម.ក ត្រូវបានគេប្រាប់មកថាបរិយាកាសបង្ខិតបង្ខំ ដែលកើតឡើងមិនអនុញ្ញាតឱ្យសមាជិកសហគមន៍រងផលប៉ះពាល់ធ្វើការសម្រេចចិត្តណាមួយជាមួយដោយផ្អែកលើគោលការណ៍ការយល់ព្រមជាមុនឡើយ។ អ្នកខ្លះបានអះអាងថាត្រូវបានតំណាងក្រុមហ៊ុន សុកហ៊្វីន ខេស៊ីឌី ប្រាប់ថាមិនថាការសម្រេចចិត្តរបស់ពួកគាត់យ៉ាងណានោះទេ ក៏ដីធ្លីរបស់ពួកគាត់នឹងត្រូវដកហូតដែរ។ អ្នកភូមិជាច្រើនបាននិយាយថា ពួកគាត់ត្រូវបានបង្ខំឱ្យចុះហត្ថលេខាលើលិខិតស្នាមឱ្យប្រគល់ដីធ្លីរបស់ពួកគាត់បន្ទាប់ពីប្រាប់ថា ប្រសិនបើពួកគាត់មិនចុះហត្ថលេខាទេនោះពួកគាត់នឹងមិនទទួលបានសំណងអ្វីឡើយ។ អ្នកភូមិម្នាក់បានរាយការណ៍ថា គាត់ត្រូវបានគេបង្ខំឱ្យចុះហត្ថលេខាលើលិខិតស្នាមដែលគាត់មិនបានដឹងពីខ្លឹមសាររបស់វាសោះឡើយ។ អ្នកភូមិដទៃទៀតបានរាយការណ៍ថាពួកគាត់ពិតជាបានពិគ្រោះយោបល់អាចបង្ហាញពីការទាមទាររបស់ពួកគាត់ ហើយបានទទួលការសន្យាថា នឹងមានឱកាសដាំដើមកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច ឬនឹងមានដីថ្មីដែលដោះដូរ ប៉ុន្តែពួកគាត់ប្រាប់ថា សំណើរបស់ពួកគាត់មិនត្រូវបានអនុវត្តតាមឡើយ។ លើសពីនេះទៀត អ្នកដែលត្រូវបានសម្ភាសមួយចំនួនបានរាយការណ៍ថាតំណាងក្រុមហ៊ុន សុកហ៊្វីន ខេស៊ីឌី ឬអាជ្ញាធរមូលដ្ឋានបានគំរាមពួកគាត់ឱ្យប្រគល់ដីធ្លីរបស់ខ្លួន។ មនុស្សម្នាក់បានរាយការណ៍ថា នាងត្រូវបានគេប្រាប់ថា នឹងត្រូវជាប់ពន្ធនាគារប្រសិនបើនាងមិនព្រមប្រគល់ដីធ្លីរបស់ខ្លួនទេនោះ។ តែផ្ទុយទៅវិញអាជ្ញាធរខេត្តបានប្រាប់ ម.ស.ម.ក ថាមានការពិគ្រោះយោបល់ជាច្រើនដែលសហគមន៍ត្រូវបានគេជូនដំណឹងអំពីការវិវត្តនៃគម្រោងនេះហើយថា អាជ្ញាធរក៏បានលើកទឹកចិត្តដល់សហគមន៍ដើម្បីលើកឡើងពីការព្រួយបារម្ភ និងសំណើរបស់ខ្លួននៅពេលពួកគាត់ជួបជាមួយអាជ្ញាធរ។

ដូចគ្នានេះដែរ អ្នកតំណាងក្រុមហ៊ុន សុកហ៊្វីន ខេស៊ីឌី បានប្រាប់ ម.ស.ម.ក ថាលោកបានរៀបចំកិច្ចប្រជុំមួយនៅថ្នាក់ឃុំ និងបានជូនដំណឹងដល់ពួកគាត់អំពីផែនការហើយលោកបានពិភាក្សាអំពីស្ថានភាពជាមួយអ្នកតំណាងមកពីភូមិចំនួនប្រាំពីរ។ លោកបានបន្ថែមថា ចាប់តាំងពីចាប់ផ្តើមគម្រោងមក ការប្រជុំជាទៀងទាត់ត្រូវបានរៀបចំឡើងជាមួយអាជ្ញាធរឃុំ និងរដ្ឋបាលមូលដ្ឋាន ហើយក៏មានការជួលអ្នកប្រឹក្សាយោបល់ម្នាក់ដើម្បីធ្វើការប្រឹក្សាជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍ផងដែរ។ ប៉ុន្តែ អាជ្ញាធរមូលដ្ឋានបានប្រាប់ ម.ស.ម.ក ថាពួកគាត់បានដឹងអំពីគម្រោងនេះ នៅពេលដែលមានគ្រឿងចក្រមកដល់ដើម្បីធ្វើការកំណត់ព្រំ ប្រទល់សម្បទានដីសេដ្ឋកិច្ច។ ក្រុមហ៊ុន សុកហ៊្វីន អេស្ស.អេ ដែលជាក្រុមហ៊ុនមេរបស់ ក្រុមហ៊ុន សុកហ៊្វីន ខេស៊ីឌី បានបដិសេធ

រាល់ការចោទប្រកាន់ទាំងឡាយ ហើយបានអះអាងថា ក្រុមហ៊ុនគោរពទាំងច្បាប់ អន្តរជាតិ និងច្បាប់ក្នុងប្រទេសកម្ពុជា។[124] ជាពិសេស គេបានដែរអះអាងថា ក្រុមអ្នកជំនាញមួយក្រុមត្រូវ បានបង្កើតឡើងនិងទទួលខុសត្រូវលើទំនាក់ទំនងរបស់ក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី ជាមួយសមាជិកសហគមន៍ដែលរងផលប៉ះពាល់ ហើយធ្វើរបាយការណ៍ប្រចាំខែ ស្តីពីស្ថានភាពរបស់សហគមន៍ និងពីសកម្មភាពរបស់ក្រុមហ៊ុន។[125]

គួរកត់សំគាល់ផងដែរថា ទាក់ទងទៅនឹងសំណើប្រាក់កម្ចីរបស់ក្រុមហ៊ុន សុកហ្វីន អេស្ស.អេ ទៅកាន់ អាយ.អេហ្វ.ស៊ី ដែលបានលើកឡើងខាងលើ[126] អាយ.អេហ្វ.ស៊ី ជាបឋមបានយល់ព្រមផ្តល់ប្រាក់កម្ចីដោយផ្អែកទៅលើការគោរពរបស់ក្រុមហ៊ុន សុកហ្វីន អេស្ស.អេ ចំពោះសិទ្ធិជនជាតិដើមភាគតិច រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ។ ប៉ុន្តែជាពិសេសស្ថានប័ននេះបានស្នើឱ្យក្រុមហ៊ុន សុកហ្វីន អេស្ស.អេ «ចូលរួមជាមួយអង្គការពាក់ព័ន្ធនានា និងចូលក្នុងការចរចាជាមួយជនជាតិដើមភាគតិចរងផលប៉ះពាល់ និងយល់ព្រមលើផែនការសកម្មភាពដើម្បីធានាថា ផលប៉ះពាល់នៃដីសម្បទានត្រូវបានបញ្ជាក់ច្បាស់លាស់ ហើយគម្លាតនៃដំណើរការសំណងត្រូវបានដោះស្រាយអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ អាយ.អេហ្វ.ស៊ី» ត្រឹមខែតុលា ឆ្នាំ២០១៧ ដើម្បីចូលទៅក្នុងដំណើរការ អាយ.អេហ្វ.ស៊ី និងដើម្បីធ្វើសវនកម្មដោយភាគីទីបីក្នុងការធានា «ការស្តារជីវភាពឡើងវិញ»។[127] ក្រុមហ៊ុន សុកហ្វីន អេស្ស.អេ ត្រូវបានតម្រូវឱ្យរាយការណ៍ពីលទ្ធផលជូន អាយ.អេហ្វ.ស៊ី។ ទោះជា ម.ស.ម.ក មិនអាចស្វែងរកព័ត៌មានណាមួយទាក់ទងនឹងស្ថានភាពនៃប្រាក់កម្ចីនោះ មិនមានរបាយ ការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់ណាមួយរបស់ក្រុមហ៊ុន សុកហ្វីន អេស្ស.អេ និយាយទាក់ទងទៅនឹងប្រាក់កម្ចីនេះឡើយ ហើយសំណើសុំប្រាក់កម្ចីនេះមិនមាននៅលើវេបសាយត៍របស់ អាយ.អេហ្វ.ស៊ី ទេ ដែលប្រហែលជាមានន័យថាកម្ចីនេះមិនដែលត្រូវបានអនុម័តឡើយ។

ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស** សមាជិកសហគមន៍រងផលប៉ះពាល់ដែល ម.ស.ម.ក បានសម្ភាសនៅឆ្នាំ២០១៧ បាននិយាយថា ពួកគាត់មិនមានកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន ឬអាជ្ញាធរឡើយ នៅពេលដែលដីធ្លីរបស់ពួកគាត់ត្រូវបានគេរឹបអូស ហើយភាគច្រើនបាននិយាយថាពួកគាត់មិនទទួលបានការពិគ្រោះយោបល់មុនពេលដែលដីធ្លីរបស់ពួកគាត់ត្រូវបានឈូសឆាយឡើយ។ អ្នកភូមិជាច្រើនបានអះអាងថាអាជ្ញាធរស្រុកបានប្រាប់ពួកគាត់ថា ពួកគាត់ត្រូវតែចុះហត្ថលេខាប្រគល់ដីធ្លីរបស់ពួកគាត់ទៅឱ្យក្រុមហ៊ុន ទោះបីជាពួកគាត់យល់ព្រមឬមិនយល់ព្រមក៏ដោយ។ ទោះជាយ៉ាងណាអាជ្ញាធរមូលដ្ឋានបានប្រាប់ ម.ស.ម.ក ថា មានកិច្ចប្រជុំជាច្រើន

---

[124]"ការឆ្លើយតបរបស់ក្រុមហ៊ុន សុកហ្វិន ចំពោះរបាយការណ៍FIDHទំព័រ ២

[125]"ការឆ្លើយតបរបស់ក្រុមហ៊ុន សុកហ្វិន ចំពោះរបាយការណ៍ FIDH ទំព័រ ៣

[126]"*សូមមើល supra*, ទិដ្ឋភាពទូទៅអំពីក្រុមហ៊ុន Socfin-KCD ទំព័រ ៩-១២; *សូមមើល*សេចក្តីសង្ខេបអំពីការពិនិត្យឡើងវិញលើបរិស្ថាននិងសង្គមនៃកម្ចីរបស់ក្រុមហ៊ុន សុកហ្វិន "*IFC*, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥, http://business.sithi.org/show_report_detail_land.php?id=69&ng=en; "កម្ចីរបស់ក្រុមហ៊ុន Socfin (លេខ ៣៥៩៣០) – ផែនការសកម្មភាពបរិស្ថាន និងសង្គម", *IFC*ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥, http://business.sithi.org/show_report_detail_land.php?id=70&lang=en.

[127]"កម្ចីសាជីវកម្ម (លេខ ៣៥៩៣០)– ផែនការសកម្មភាពបរិស្ថាននិងសង្គម", *IFC*, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥, បទដ្ឋានប្រតិបត្តិទី ៧៖ ជនអន្តោប្រវេសន៍... 

ជាមួយសហគមន៍រងផលប៉ះពាល់នៅ ឆ្នាំ២០១០ ដែលបានបង្ហាញផែនទីនៃតំបន់សេដ្ឋកិច្ចពិសេសប៉ុន្តែទោះជាយ៉ាងណា «មិនមានកិច្ចព្រមព្រៀង»ណាមួយត្រូវបានសម្រេចឡើយ។ អាជ្ញាធរមូលដ្ឋានផ្សេងទៀតបានប្រាប់ ម.ស.ម.កថាមិនមានការសួរនាំពីមតិយោបល់របស់សហគមន៍រងផលប៉ះពាល់ទេ ហើយពួកគាត់ជាអាជ្ញាធរទើបបានដឹងអំពីតំបន់សេដ្ឋកិច្ចពិសេសនេះ នៅពេលមានអ្នកមកវាស់វែងដីរបស់ពួកគាត់ប៉ុណ្ណោះ។ នៅឆ្នាំ២០១៥ អាជ្ញាធរស្រុក និងអាជ្ញាធរខេត្តបានអញ្ជើញ សមាជិកសហគមន៍រងផលប៉ះពាល់ឱ្យចូលរួមក្នុងដំណើរការដោះស្រាយវិវាទតាមរយៈការដោះដូរដីធ្លី។ ទោះបីជាសហគមន៍មិនយល់ស្របក៏ដោយ ក៏ ពួកគាត់ត្រូវបានគេប្រាប់ថាពួកគាត់ត្រូវតែផ្តិតមេដៃលើឯកសារទាក់ទងនឹងការដោះដូរដីធ្លីនោះ។

សរុបមកអ្វីដែលកើតឡើង គឺថាអាជ្ញាធរហាក់ដូចជាកំណត់ន័យ «ការពិគ្រោះយោបល់» ថាជាការប្រជុំសាមញ្ញមួយក្នុងពេលដែលពួកគាត់ បានជូនដំណឹងទៅសហគមន៍រងផលប៉ះពាល់អំពីអ្វី នឹងកើតឡើងដែលជាការពិភាក្សាតែម្ខាង មិនមែនជាការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ដែលមតិយោបល់របស់សហគមន៍ត្រូវបានសួរនាំកង្វល់របស់ពួកគាត់ត្រូវបានលើកឡើង ហើយដំណោះស្រាយត្រូវបានពិភាក្សា។ ក្នុងករណីទាំងបីនេះការព្រមព្រៀងត្រូវបានកើតឡើងក្នុងបរិយាកាសបង្ខិតបង្ខំ និងជួនកាលមានការគំរាមកំហែងដោយផ្ទាល់។ លើសពីនេះទៀត មិនមែនព័ត៌មានទាំងអស់ត្រូវបានផ្តល់ជូនដល់សហគមន៍រងផលប៉ះពាល់នោះទេ ដោយហេតុនេះអាចរារាំងពួកគាត់ពីការផ្តល់ព័ត៌មានសព្វគ្រប់ដល់ពួកគាត់មុននឹងមានការយល់ព្រម។

## របកគំហើញទី ៤៖ ការប្រើកម្លាំង និងការបំលាស់ទីលំនៅថ្មីដោយបង្ខំ ត្រូវហាមឃាត់ជាដាច់ខាត

ក្នុងករណីទាំងបីនេះ ជនរងគ្រោះទាំងអស់បានរាយការណ៍ថា ពួកគាត់មិនបានដឹងពីសម្បទានដីសេដ្ឋកិច្ច ឬតំបន់សេដ្ឋកិច្ចពិសេស មុនពេលក្រុមហ៊ុនចុះទៅកំណត់ព្រំដែនលើដីទាំងនោះទេ។ បន្ថែមពីលើនេះពួកគាត់មិនមានសិទ្ធិប្រើប្រាស់ឯកសារសំខាន់ៗនោះទេ។ ជាងនេះទៀត ក្នុងករណីទាំងបីនេះ ប្រជាពលរដ្ឋត្រូវបានគេបណ្តេញចេញពីដីរបស់ខ្លួនដោយបង្ខំ។ ជារឿយៗអាជ្ញាធរមូលដ្ឋាន និងជួនកាលកងកម្លាំងនគរបាលបានអមដំណើរតំណាងក្រុមហ៊ុន នៅពេលដែលប្រជាពលរដ្ឋត្រូវបានបណ្តេញដោយបង្ខំ។ ប៉ុន្តែអាជ្ញាធរដែល ម.ស.ម.ក បានសម្ភាស បានបដិសេធថា អ្នកភូមិមិនត្រូវបានបណ្តេញចេញដោយបង្ខំនោះទេ។

ក្នុង**ករណីក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី និងក្រុមហ៊ុន មីតផ័រ ភូល** សហគមន៍រងផលប៉ះពាល់មិនបានដឹងអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលត្រូវបានអះអាងនោះទេ ហើយបើមានមែន ក៏ពួកគាត់ក៏មិនបានទទួលរបាយការណ៍ថតចម្លង ឬរបាយការណ៍អនុវត្តណាមួយនោះដែរ។ ឧទាហរណ៍ ក្នុង**ករណីក្រុមហ៊ុន អឹម ឌីអេស** មិនមានសមាជិកសហគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាលណាមួយអាចរកបានឯកសារផ្លូវការទាក់ទងនឹងការអនុម័តតំបន់សេដ្ឋកិច្ចពិសេសឡើយរហូតដល់ខែឧសភា ឆ្នាំ២០១៨ ដែល ម.ស. ម.ក បានរក

ឃើញសេចក្តីជូនដំណឹងរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៣៣៤។[128] រហូតមកដល់បច្ចុប្បន្ននេះ អនុក្រឹត្យដែលគេគិតថាត្រូវបានអនុម័តសម្រាប់តំបន់សេដ្ឋកិច្ចពិសេសមិនអាចរកឃើញឡើយ។

ក្នុង**ករណីក្រុមហ៊ុន មីតផ៉ រូល** ស្ត្រីម្នាក់បានឃើញផ្ទះរបស់ខ្លួនត្រូវបានគេដុតបំផ្លាញ និងរងរបួសនៅពេលត្រូវបានគេបណ្តេញចេញដោយបង្ខំ ហើយបន្ទាប់មកត្រូវបានគំរាមចាប់ដាក់ពន្ធនាគារ ប្រសិនបើគាត់តវ៉ា ហើយម្នាក់ទៀតត្រូវបានគេប្រាប់ថា ប្រសិនបើនាងមិនចាកចេញពីផ្ទះ និងដីរបស់ខ្លួនទេ នាងនិងគ្រួសាររបស់នាងនឹងត្រូវជាប់ពន្ធនាគារ។ អ្នកដែលមិនព្រមទទួលយកការដោះដូរដី ត្រូវបានគេបណ្តេញចេញដោយបង្ខំ ដោយមិនមានការជូនដំណឹងជាមុនឡើយ។ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគាត់ទាំងអស់ត្រូវបានកម្ទេចចោល។ មនុស្សជាច្រើនមើលឃើញផ្ទះរបស់ពួកគាត់ត្រូវបានគេដុតបំផ្លាញ និងបាត់បង់ដីធ្លីនិងដីស្រែរបស់ខ្លួន។ នៅខែមេសា ឆ្នាំ២០០៨ ភូមិអូរបាត់មាន់ ទាំងមូលត្រូវបានកម្ទេចចោលដែលជាផ្នែកមួយនៃការឈូសឆាយដីសម្រាប់សម្បទានដីសេដ្ឋកិច្ច។ ផ្ទះចំនួន ១៥៤ខ្នង ត្រូវបានកម្ទេចដោយបុគ្គលិកក្រុមហ៊ុន ខណៈដែលអាជ្ញាធរមូលដ្ឋានក៏មានវត្តមាននៅទីនោះដែរ។[129] នៅខែតុលា ឆ្នាំ២០០៩ ផ្ទះប្រហែល ១០០ខ្នង ត្រូវបានដុតបំផ្លាញដោយនគរបាល កងរាជអាវុធហត្ថ និងកម្មករដែលត្រូវបានជួលមកប្រហែល១៥០ នាក់។[130] អ្នកភូមិមួយចំនួនដែលបានតវ៉ាប្រឆាំងនឹងការរឹបអូសយកដីនេះត្រូវបានចាប់ដាក់ពន្ធនាគារ រួមមានទាំងអ្នកដឹកនាំសហគមន៍ពីរនាក់ដែលត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ និងពីរនាក់ទៀត ត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលជាង ៦ខែ ពីបទរំលោភច្បាប់នៃប្រទេសកម្ពុជា។[131]

នៅក្នុងឆ្នាំ២០០៨ ក្នុង**ករណីក្រុមហ៊ុន សុកហ៊្វីន ខេស៊ីឌី** អ្នកភូមិរងផលប៉ះពាល់បានឃើញគ្រឿងចក្រមកកម្ទេចផ្ទះនិងទ្រព្យសម្បត្តិរបស់ពួកគាត់ដោយមិនមានការជូនដំណឹងជាមុន ហើយអ្នកដែលតវ៉ាត្រូវបានគេរាយការណ៍ថា បានរងការគំរាមកំហែងដោយការចាប់ដាក់ពន្ធនាគារ។ សមាជិកសហគមន៍រងផលប៉ះពាល់បានប្រាប់ ម.ស.ម.ក ថាផ្ទះរបស់អ្នកដែលមិនចង់ចាកចេញពីដីរបស់ពួកគាត់ត្រូវបានដុតបំផ្លាញចោលដោយអាជ្ញាធរ។

ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស** ក្រុមហ៊ុនបានឈូសឆាយផ្ទះ និងចម្ការរបស់ ១១គ្រួសារ នៅខែវិច្ឆិកា ឆ្នាំ២០១៤។ នៅពេលកំពុងធ្វើការឈូសឆាយ មានក្រុមកងកម្លាំងប្រដាប់អាវុធនៅចាំការពារខណៈដែលអាជ្ញាធរមូលដ្ឋាននិងអាជ្ញាធរខេត្តក៏មានវត្តមាននៅកន្លែងកើតហេតុផងដែរ។ ស្ត្រីម្នាក់ដែលប៉ុនប៉ងបញ្ឈប់គ្រឿងចក្រឈូសឆាយមិនឱ្យឈូសដីរបស់ខ្លួនត្រូវបានគេរុញទៅមុខគ្រឿងចក្រឈូសឆាយ ហើយគំរាមថានឹងកប់ក្នុងដី។

[128]"ក្រុមប្រឹក្សារដ្ឋមន្ត្រី, សេចក្តីជូនដំណឹង លេខ ១៣៣៤, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០, http://business.sithi.org/ressource_detail.php?ressource_id=29&lang=en.

[129]"បណ្តឹងតាងនាមឱ្យក្រុម IDI ថៃប្តឹងក្រុមហ៊ុនមីត្រផូលខែមេសា ឆ្នាំ២០១៨ ទំព័រ ២

[130]"បណ្តឹងតាងនាមឱ្យក្រុមIDI ថៃប្តឹងក្រុមហ៊ុនមីត្រផូលខែមេសាឆ្នាំ២០១៨, ទំព័រ២

[131]"បណ្តឹងតាងនាមឱ្យក្រុមIDI ថៃប្តឹងក្រុមហ៊ុនមីត្រផូលខែមេសាឆ្នាំ២០១៨, ទំព័រ ៣

បុគ្គលម្នាក់ដែលបានថតរូបក្នុងឆ្នាំ២០១០ ត្រូវបានកងរាជអាវុធហត្ថរុញច្រាន ហើយមានមន្ត្រីបរិស្ថានម្នាក់បានរារាំងគាត់មិនឱ្យចូលទៅដីរបស់គាត់។

សកម្មភាពដែលទាក់ទងនឹងការបណ្តេញចេញដោយបង្ខំរួមបញ្ចូលមានទាំងការដុតបំផ្លាញផ្ទះសម្បែង ការឈូសឆាយផ្ទះ និងដីធ្លីដោយមិនមានការជូនដំណឹងជាមុន ការគំរាមកំហែងបទព្រហ្មទណ្ឌការប្រើអាវុធនិងអំពើហិង្សាលើរាងកាយ និងមានសេចក្តីរបាយការណ៍អំពីកិច្ចសហការរបស់អាជ្ញាធរ និងក្រុមហ៊ុនចំពោះសកម្មភាពទាំងនោះផងដែរ។

## របកគំហើញទី ៥ ៖ សហគមន៍ត្រូវតែទទួលបានការអនុញ្ញាតឱ្យតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគាត់ និងត្រូវទទួលបានការការពារឱ្យបានសមស្រប

ទោះបីជាមានក្របខ័ណ្ឌច្បាប់ដ៏រឹងមាំដែលការពារសេរីភាពនៃការបញ្ចេញមតិការប្រមូលផ្តុំ និងការចូលរួមនៅក្នុងប្រទេសកម្ពុជា[132] ក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែង ជនរងគ្រោះនៃវិវាទដីធ្លីដែលបានព្យាយាមតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគាត់ទាំងនៅមុនពេល នៅអំឡុងពេល ឬក្រោយពេលសម្បទានដីសេដ្ឋកិច្ច ឬតំបន់សេដ្ឋកិច្ចពិសេសត្រូវបានអនុម័តនោះ បានប្រឈមនឹងបញ្ហារាប់មិនអស់ មានចាប់ពីការបំភិតបំភ័យរហូតដល់ការគំរាមកំហែង អំពើហិង្សាលើរាងកាយនិងការដាក់ពន្ធនាគារទៀតផង។[133] នៅក្នុងប្រទេសកម្ពុជា បុគ្គលម្នាក់ ឬ ច្រើននាក់ត្រូវបានជ្រើសរើសដោយសហគមន៍រងផលប៉ះពាល់ ឱ្យធ្វើជាអ្នកទំនាក់ទំនងជាមួយអាជ្ញាធរ និងក្រុមហ៊ុន។ ពួកគាត់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាអ្នកការពារសិទ្ធិមនុស្ស(«អ្នកការពារសិទ្ធិមនុស្ស»)ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយសារពួកគាត់តស៊ូមតិដើម្បីការពារសិទ្ធិរបស់អ្នកដទៃ។

### ៥.១. ជនរងគ្រោះរាយការណ៍ពីការបន្តប្រឈមនឹងការបំភិតបំភ័យ គំរាមកំហែង និងអំពើហិង្សា

ក្នុងករណីទាំងបីនេះបុគ្គលរងផលប៉ះពាល់បានប្រាប់ ម.ស.ម.ក ថានៅពេលដែលពួកគាត់ព្យាយាមតវ៉ាប្រឆាំងនឹងការរំលោភបំពានសិទ្ធិរបស់ខ្លួន ឬដើម្បីស្វែងរកដំណោះស្រាយពួកគាត់ត្រូវបានគំរាមដោយអាជ្ញាធរ និងអ្នកតំណាងក្រុមហ៊ុន។

[132] "របាយការណ៍ប្រចាំឆ្នាំទីមួយនៃការឃ្លាំមើលសេរីភាពនៅកម្ពុជា" *អង្គការម.ស.ម.ក អង្គការអាដហុក អង្គការ Solidarity Center & ICNL*ចុះខែសីហា ឆ្នាំ២០១៧, ទំព័រទី ៣https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf.

[133] "*សូមមើល*, ជាទូទៅ, "របាយការណ៍ប្រចាំឆ្នាំទីពីរនៃការឃ្លាំមើលសេរីភាពនៅកម្ពុជា" *អង្គការម.ស.ម.ក អង្គការអាដហុក អង្គការ Solidarity Center & ICNL*ចុះខែកញ្ញា ឆ្នាំ២០១៨, ទំព័រទី ៣-១១, https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

ក្នុង**ករណីក្រុមហ៊ុន មីតផល ភូល** អ្នកភូមិរងផលប៉ះពាល់មួយចំនួនបានប្រាប់ ម.ស.ម.ក ថា ពួកគាត់ត្រូវ បានគេប្រាប់ថា ពួកគាត់នឹងត្រូវចាប់ដាក់ពន្ធនាគារ ប្រសិនបើពួកគាត់មិនចាកចេញពីដីរបស់ខ្លួន ឬនៅបន្តតវ៉ាលើសម្បទានដីសេដ្ឋកិច្ច។ ដំណាក់កាលដំបូងក្នុងវិវាទនេះ សមាជិកសហគមន៍ម្នាក់ត្រូវបានក្រុមកម្លាំងប្រដាប់អាវុធចម្រុះរត់ដេញតាម និងគំរាមរកបាញ់ ខណៈដែលសមាជិកម្នាក់ទៀតត្រូវបានគេប្រាប់ថា សមាជិកសហគមន៍ នឹងត្រូវគេបាញ់ ប្រសិនបើនាងនៅបន្តតវ៉ាប្រឆាំងនឹងក្រុមហ៊ុនទៀត។ បុគ្គលមួយចំនួនបានរាយការណ៍មក ម.ស.ម.ក ថា ត្រូវបានគេប្រាប់ថា ផ្ទះរបស់ពួកគាត់នឹងត្រូវដុតបំផ្លាញចោលប្រសិនបើពួកគាត់នៅបន្តធ្វើការតវ៉ា។ ទោះបីករណីទាំងនោះត្រូវបានរាយការណ៍ទៅអាជ្ញាធរក៏ដោយក៏មិនមានវិធានការអ្វីបន្ថែមត្រូវបានធ្វើឡើងនោះដែរ ផ្ទុយទៅវិញអ្នកដែលទៅរកអាជ្ញាធរមូលដ្ឋានត្រូវបានគំរាមចាប់ដាក់ពន្ធនាគារ។ នៅខែមីនា ឆ្នាំ២០១៧ សហគមន៍រងផលប៉ះពាល់បានចូលរួមក្នុងសន្និសីទសារព័ត៌មានមួយ ដែលមានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីការរំលោភសិទ្ធិមនុស្ស ដែលពាក់ព័ន្ធនឹងក្រុមហ៊ុនស្ករនានា។[134] បន្ទាប់ពីសន្និសីទនេះធ្វើរួចអាជ្ញាធរបានចោទប្រកាន់ក្រុមអ្នករៀបចំពីបទធ្វើឱ្យ «ខូចខាតកេរ្តិ៍ឈ្មោះសណ្តាប់ធ្នាប់សង្គម សន្តិភាព សាមគ្គីភាព និងការផ្សះផ្សាររបស់ប្រទេសកម្ពុជា» និងគំរាមចាត់វិធានការទៅតាមផ្លូវច្បាប់ចំពោះអ្នកដែលបានចូលរួមទាំងឡាយដែលមិនមែនជាជនរងគ្រោះដោយសារសម្បទានដីសេដ្ឋកិច្ច។[135]

## តើនរណាជាអ្នកការពារសិទ្ធិមនុស្ស?

អ្នកការពារសិទ្ធិមនុស្ស" គឺពិពណ៌នាពីបុគ្គលម្នាក់ ឬជាមួយអ្នកដទៃ ដែលធ្វើសកម្មភាពដើម្បីលើកកម្ពស់ឬដើម្បីការពារសិទ្ធិមនុស្ស។ អ្នកការពារសិទ្ធិមនុស្សត្រូវបានកំណត់ជាពិសេសលើអ្វីដែលពួកគេធ្វើ។ តាមរយៈការពិពណ៌នាអំពីសកម្មភាពរបស់ពួកគេ និងអំពីបរិបទមួយចំនួន ដែលពួកគេធ្វើ ដែលឃ្លានេះអាចពន្យល់ពីអត្ថន័យរបស់ពាក្យនេះបានល្អបំផុត។

ដើម្បីធ្វើជាអ្នកការពារសិទ្ធិមនុស្សបាន មនុស្សម្នាក់អាចធ្វើសកម្មភាពដើម្បីដោះស្រាយសិទ្ធិមនុស្ស (ឬសិទ្ធិ) ក្នុងនាមបុគ្គលឬក្រុមណាមួយ។ អ្នកការពារសិទ្ធិមនុស្សស្វែងរកការលើកកម្ពស់និងការការពារសិទ្ធិពលរដ្ឋនិងនយោបាយ ក៏ដូចជាការលើកកម្ពស់ ការការពារ និងការសម្រេចបាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

*UN OHCHR, https://bit.ly/2NEIb7p*

នៅខែមេសា ឆ្នាំ២០១៧ អាជ្ញាធរបានរារាំងសមាជិកសហគមន៍ចូលរួមវគ្គបណ្តុះបណ្តាលលើសិទ្ធិដីធ្លី ហើយបានកោះហៅពួកគាត់ទៅប៉ុស្តិ៍នគរបាលដោយចោទប្រកាន់ពីបទ «ប្រមូលផ្តុំ» និង «ញុះញង់» ប្រជាពលរដ្ឋឱ្យ «ប្រឆាំងនឹងអាជ្ញាធរ»។ សមាជិកសហគមន៍ដទៃទៀត ដែលសកម្មក្នុងការតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគាត់ក៏ត្រូវបានរារាំងធ្វើសកម្មភាពមួយចំនួន ដោយត្រូវបានប្រាប់ឱ្យ «បញ្ឈប់ការប្រមូលផ្តុំ» ប្រជាពលរដ្ឋដទៃទៀត និងគំរាមចាប់ខ្លួនដែលសកម្មភាពនេះនៅតែបន្តកើតមានរហូតដល់ពេលដែលកំពុងសម្ភាសន៍នេះ។ នៅក្នុងខែឧសភា ឆ្នាំ២០១៨ អភិបាលខេត្តបានលុបចោលកិច្ចប្រជុំមួយដែលនឹងពិភាក្សាអំពីសម្បទានដីសង្គមកិច្ច ដោយបានចោទថា មានមនុស្សមួយចំនួនបានញុះញង់ប្រជាពលរដ្ឋឱ្យធ្វើបាតុកម្មប្រឆាំងនឹងអភិបាលខេត្ត និង

---

[134]"សន្និសីទស្តីពី "សេដាតិល្វីងជូរចត់នៃដំណាំអំពៅនៅប្រទេសកម្ពុជា៖ការចាកចេញដោយបង្ខំ និងការដកហូតសិទ្ធិកាន់កាប់ដីធ្លីនៅខេត្តឧត្តរមានជ័យ"

[135]"សន្និសីទស្តីពីឧស្សាហកម្មដំណាំអំពៅធ្វើឱ្យខូចកេរ្តិ៍ឈ្មោះប្រទេសកម្ពុជា", *Freshnews asia (ភាសាអង់គ្លេស)*, ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧, http://en.freshnewsasia.com/index.php/en/3957-conference-on-sugarcane-industry-hurts-cambodia-s-reputation.html.

ញុះញង់សមាជិកសហគមន៍ដទៃទៀតមិនឱ្យទទួលយកដីដោះដូរដែលស្នើឡើង។ លើសពីនេះទៀត សមាជិកសហគមន៍មួយចំនួនត្រូវបានចាប់ដាក់ពន្ធនាគារ និងត្រូវបានគេចោទប្រកាន់ពីបទកាប់ឈើខុសច្បាប់នៅពេលដែលពួកគាត់ព្យាយាមប្រឆាំងនឹងសម្បទានដីសេដ្ឋកិច្ច។ ជាពិសេស អ្នកដឹកនាំសហគមន៍ពីរនាក់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំពីបទ «កាប់ផ្កាព្រៃរដ្ឋ» ខណៈដែលអ្នកដឹកនាំពីរនាក់ទៀតត្រូវបានដោះលែងបន្ទាប់ពីបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលជាង ៦ ខែ។[136]

ជាចុងក្រោយ បញ្ហាប្រឈមចម្បងមួយដែលបានលើកឡើងដោយសមាជិកសហគមន៍រងផលប៉ះពាល់ដោយវិវាទដីធ្លីជាមួយក្រុមហ៊ុន មីតផ័រ ភូល គឺថា អាជ្ញាធរនឹងអាចរារាំងពួកគាត់ក្នុងការជួបជុំនិងពិភាក្សាអំពីវិវាទដីធ្លី ឬនឹងរំខានកិច្ចប្រជុំ និងគំរាមចាប់ពួកគាត់ដាក់ពន្ធនាគារ។ គួរកត់សំគាល់ផងដែរថា មនុស្សទាំងអស់ដែលត្រូវបាន ម.ស.ម.ក សម្ភាសនៅខែមិថុនា ឆ្នាំ២០១៨ បានរាយការណ៍ថាត្រូវបាន «ឃ្លាំមើល» ពីសំណាក់អាជ្ញាធរ។

ក្នុង**ករណីក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី** សមាជិកសហគមន៍ជាច្រើនបានរាយការណ៍ថាត្រូវបានគំរាមដោយអាជ្ញាធរ និងតំណាងក្រុមហ៊ុន **សុកហ៊ីន ខេស៊ីឌី** ហើយអ្នកខ្លះបានអះអាងថា ពួកគាត់ត្រូវបានគេគំរាមថានឹងចាប់ដាក់ពន្ធនាគារ ប្រសិនបើពួកគាត់នៅតែបន្តតវ៉ា។ ស្ត្រីម្នាក់បានប្រាប់ ម.ស.ម.ក ថា គេភ្ជង់កាំភ្លើងដាក់គាត់ក្នុងអំឡុងពេលធ្វើការតវ៉ា ខណៈដែលអ្នកផ្សេងទៀតបានរាយការណ៍ថា ត្រូវបានឃាត់ខ្លួន និងឃុំខ្លួននៅប៉ុស្តិ៍នគរបាលដោយសារតែការប្រឆាំងនឹងសម្បទានដីសេដ្ឋកិច្ច។ ក្នុងឆ្នាំ២០០៨ ស្ត្រីម្នាក់ត្រូវបានឃាត់ខ្លួនដោយនគរបាលមូលដ្ឋានបន្ទាប់ពីបានតវ៉ាប្រឆាំងនឹងការឈូសឆាយដីរបស់គាត់ ហើយត្រូវបានចោទថា រំលោភលើដីរបស់ក្រុមហ៊ុន។ ទោះជាមិនមានការប្ដឹងក៏ដោយ ក៏គាត់ត្រូវបានគេព្រមានថា «កុំប្រព្រឹត្តបែបនេះទៀត»។ នៅចន្លោះឆ្នាំ២០១៣ និងឆ្នាំ២០១៥ អ្នកភូមិរងផលប៉ះពាល់ត្រូវបានរារាំងរៀបចំពិធីប្រពៃណីដើម្បីប្រារព្ធទិវាជនជាតិដើមភាគតិចអន្តរជាតិពិភពលោក។[137] ម.ស.ម.ក បានទទួលសេចក្ដីរាយការណ៍បន្ថែមថាសមាជិកសហគមន៍មួយចំនួន ត្រូវបានគេគំរាមតាមរយៈវិធានការផ្លូវច្បាប់ប្រសិនបើពួកគាត់បន្តតវ៉ាទៀតនោះ។ ចាប់តាំងពីឆ្នាំ២០១៧ មក អ្នកដែលពាក់ព័ន្ធនឹងវិវាទដីធ្លីជាមួយក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី ហើយអ្នកដែលត្រូវបាន ម.ស.ម.ក សម្ភាស បានលើកឡើងថាពួកគាត់មិនបានប្រឈមមុខនឹងការបំភិតបំភ័យ ឬការគំរាមកំហែងទាក់ទងនឹងវិវាទដីធ្លីនោះទៀតទេ។

ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស** សមាជិកសហគមន៍ម្នាក់ដែលប៉ុនប៉ងថតរូបនៅពេល ដែលគ្រឿងចក្រឈូសឆាយ បានមកដល់ដីគាត់ក្នុងឆ្នាំ២០១០ ត្រូវបានកងរាជអាវុធហត្ថរុញច្រាន ហើយម្នាក់ទៀតត្រូវគេចាប់ដាក់ខ្នោះជាបណ្ដោះអាសន្ននិងទទួលការគំរាម។ ស្ត្រីជាអតីតអនុភូមិត្រូវបានដកចេញពីតំណែងរបស់ខ្លួនដោយ

[136]"បណ្ដឹង IDI ទៅកាន់តុលាកាថៃ ខែមេសា ឆ្នាំ២០១៨, ទំព័រទី ៣

[137]"ជនជាតិភាគតិចថា ដកអភិបាលចេញ", *ខ្មែរថាមស៍*,ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៥, https://www.khmertimeskh.com/news/16540/get-rid-of-governor--ethnic-minority-says/.

សារគាត់បានប្រទាំងជាមួយនឹងអាជ្ញាធរលើការរំលោភយកដីធ្លី ហើយត្រូវចោទប្រកាន់ពីបទបំផ្លាញព្រៃឈើនៅក្នុងឆ្នាំ២០១៣។ មនុស្សជាច្រើន ត្រូវបានគេគំរាមចាប់ខ្លួន ប្រសិនបើពួកគាត់បន្តដាំដំណាំលើដីរបស់ពួកគាត់ ឬបន្តធ្វើការតវ៉ានោះ។ នៅក្នុងឆ្នាំ២០១៤ ក្រុមអ្នកតវ៉ាត្រូវបានកងរាជអាវុធហត្ថរារាំងមិនឱ្យចូលទៅកាន់ដីរបស់ពួកគាត់។ នៅពេលសមាជិកសហគមន៍រងផលប៉ះពាល់ដោយករណីក្រុមហ៊ុន អឹមឌីអេស ព្យាយាមដាក់ញត្តិទៅការិយាល័យរបស់នាយករដ្ឋមន្ត្រី ប៉ុន្តែកងយោធពលខេមរភូមិន្ទ បានប៉ុនប៉ងដេញពួកគាត់ចេញដោយបង្ខំដោយប្រាប់ពួកគាត់ថា ប្រសិនបើពួកគាត់មិនចាកចេញទេ ពួកគាត់នឹងត្រូវ «ចាប់បញ្ជូនខ្លួន»។ សមាជិកសហគមន៍មួយចំនួនបានរាយការណ៍ថាត្រូវបានគេតាមដាន។ នៅខែមេសា ឆ្នាំ២០១៨ សមាជិកសហគមន៍សកម្មបំផុតម្នាក់បានរាយការណ៍ថា គ្រាប់មីនមួយគ្រាប់ត្រូវបានគេដាក់នៅលើដីធ្លីរបស់នាងដែលនៅជិតផ្ទះដែលជាការប៉ុនប៉ងបំភិតបំភ័យគាត់។ ខណៈពេលដែលគាត់បានរាយការណ៍ពីហេតុការណ៍នេះទៅអាជ្ញាធរ និងទៅស៊ីម៉ាក មន្ត្រីទាំងនោះបាននិយាយថាពួកគេនឹងបញ្ជូនមនុស្សទៅដោះគ្រាប់មីននោះចេញ ប៉ុន្តែ នៅខែកក្កដា ឆ្នាំ២០១៨ គ្រាប់មីននេះនៅមិនទាន់បានយកចេញនោះទេ ដែលរារាំងនាងក្នុងប្រើប្រាស់ដីរបស់ខ្លួនបាន។

ប្រព័ន្ធតុលាការ ក៏ត្រូវបានយល់ឃើញថាបានប្រើប្រាស់ដើម្បីធ្វើឱ្យការងាររបស់អ្នកការពារសិទ្ធិមនុស្សចុះខ្សោយផងដែរ។ នៅខែតុលា ឆ្នាំ២០១០ នគរបាលបានគំរាមចាប់ខ្លួនអ្នកភូមិដែលបានតវ៉ាការឈូសឆាដីរបស់ក្រុមហ៊ុន អឹមឌីអេស ចំណែកអ្នកផ្សេងទៀតត្រូវបានចាប់ខ្លួនមួយខែក្រោយមក។ ក្នុងឆ្នាំ២០១៤ សមាជិកសហគមន៍ម្នាក់ត្រូវបានឃាត់ខ្លួន និងឃុំឃាំងរយៈពេល ៤ថ្ងៃ នៅឆ្នាំ២០១៤។ ក្នុងឆ្នាំ២០១៣ សកម្មជនចំនួនបីនាក់ ត្រូវបានចោទប្រកាន់ពីបទកាប់គាស់រុករានដីព្រៃធ្លារដុតដើម្បីធ្វើជាកម្មសិទ្ធិ ដែលគេរាយការណ៍ថាបានប្រមូលឈើពីព្រៃក្នុងតំបន់សេដ្ឋកិច្ចពិសេស។ ពួកគាត់បានរាយការណ៍ថា កំពុងធ្វើការលើដីដែលពួកគាត់បានប្រើប្រាស់តាំងពីឆ្នាំ១៩៩៧ មក ហើយពួកគាត់បានបន្តប្រើប្រាស់ដីនោះ បើទោះជាតំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើងហើយក្តី។ ខណៈដែលសមាជិកសហគមន៍ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការចាប់តាំងពីពេលនោះមក សមាជិកម្នាក់ត្រូវបានកោះហៅទៅតុលាការម្តងទៀតកាលពីដើមឆ្នាំ២០១៨។ សវនាការរបស់គាត់ត្រូវបានពន្យារពេលដោយសារពុំមានមេធាវីតំណាង។ នៅពេលនេះមិនមានការវិវត្តថ្មីលើករណីនេះទេ។ អ្នកភូមិក្នុងករណីក្រុមហ៊ុន អឹមឌីអេស ក៏បានរាយការណ៍មក ម.ស.ម.ក ថា កំពុងស្ថិតក្រោមការឃ្លាំមើលជាប្រចាំ។

នៅខែកញ្ញាឆ្នាំ២០១៨ ខណៈពេលនៅលើដីក្នុងតំបន់សេដ្ឋកិច្ចពិសេស តំណាងក្រុមហ៊ុន អឹមឌីអេស ត្រូវបានគេរាយការណ៍ថាបានបញ្ឈប់ការឈូសឆាយដីដើម្បីពិភាក្សា និងចរចាជាមួយអ្នកភូមិហើយបានស្នើសុំទិញដីពីគ្រួសារមួយនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលមានវិវាទជាមួយនឹងទឹកប្រាក់ ១៩០.០០០ ដុល្លារសហរដ្ឋអាមេរិក។[138] អ្នកសារព័ត៌មានបានផ្សព្វផ្សាយវីដេអូដែលបង្ហាញថា គណៈកម្មការធិការថ្នាក់ខេត្តជំទាស់នឹងដំណោះស្រាយវិវាទនេះដោយពន្យល់ថា ដំណោះស្រាយវិវាទនេះ ត្រូវសម្រេចដោយគណៈកម្មាការធិការខេត្ត

[138] គ្រួសារនេះមិនស្ថិតក្នុងចំណោមគ្រួសារដែលនៅសល់ទាំង ១៥ ដែលកំពុងតស៊ូមតិដើម្បីស្វែងរកដំណោះស្រាយឡើយ។

មិនមែនរវាងក្រុមហ៊ុននិងក្រុមគ្រួសារឡើយ។[139] នៅថ្ងៃដដែល អ្នកយកព័ត៌មានពីរនាក់ដែលបានរាយការណ៍ពីករណីនេះត្រូវបាននគរបាលមូលដ្ឋានចាប់ខ្លួននៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ហើយត្រូវបានចោទប្រកាន់ពីបទញុះញង់ និងផ្សព្វផ្សាយព័ត៌មានមិនពិត បន្ទាប់ពីមានបណ្ដឹងតវ៉ាពីក្រុមហ៊ុន អឹមឌីអេស។[140] ប៉ុន្តែពួកគាត់ត្រូវបានដោះលែងវិញនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨។[141]

ការគំរាមកំហែង ការបៀតបៀនតាមផ្លូវតុលាការ និងការបំភិតបំភ័យត្រូវបានអះអាងថាកើតឡើងក្នុងករណីទាំងបីចាប់តាំងពីដំណាក់កាលដំបូងនៃវិវាទរហូតដល់ពេលនេះ។ នេះជាការរំលោភទាំងច្បាប់នៃប្រទេសកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយរារាំងជនរងគ្រោះពីការប្រើប្រាស់សិទ្ធិដែលពួកគាត់មាន។ ការឃ្លាំមើលដដែលៗមិនមែនគ្រាន់តែបំភិតបំភ័យសមាជិកសហគមន៍ទេ តែក៏ប៉ះពាល់អវិជ្ជមានដល់សេរីភាពដើរហើរលទ្ធភាពក្នុងការជួបជុំ និងពិភាក្សាអំពីវិវាទដីធ្លីរបស់ពួកគាត់ ក៏ដូចជាលទ្ធភាពរបស់ពួកគាត់ក្នុងការស្វែងរកដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្សផងដែរ។ នេះគឺជាសញ្ញាអវិជ្ជមានដល់បុគ្គលផ្សេងទៀត ដែលសិទ្ធិរបស់ពួកគាត់ត្រូវបានប៉ះពាល់ដោយវិវាទដីធ្លី ដែលអាចមានការស្ទាក់ស្ទើរក្នុងការតស៊ូមតិរកដំណោះស្រាយដោយយុត្តិធម៌លើបញ្ហានេះ ដោយសារការភ័យខ្លាចនៃផលវិបាកវិជ្ជមាន។

## ៥.២. ការបំភិតបំភ័យ និងការគំរាមកំហែងចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលជួយដល់ជនរងគ្រោះ

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលគាំទ្រជនរងគ្រោះដោយវិវាទដីធ្លី តាមរយៈការពង្រឹងជំនាញតស៊ូមតិការបណ្ដុះបណ្ដាលស្ដីពីការអប់រំសិទ្ធិមនុស្សឬជំនួយផ្នែកច្បាប់ ក៏ត្រូវបានគេបំភិតបំភ័យតាមដាននិងបៀតបៀនផងដែរ ដែលបានរំលោភបំពានលើសេរីភាពបញ្ចេញមតិ និងសេរីភាពនៃការចូលរួមរបស់ពួកគាត់។

ក្នុង**ករណីក្រុមហ៊ុន មីតផ័រ ភូល** សមាជិកអង្គការមិនមែនរដ្ឋាភិបាលក៏ត្រូវបានអាជ្ញាធរបៀតបៀនទាក់ទងនឹងការងាររបស់ពួកគាត់ជាមួយនឹងអ្នកដែលត្រូវបានបណ្ដេញចេញពីដីធ្លី។[142] អ្នកខ្លះបានរាយការណ៍ប្រាប់ ម.ស.ម.ក ថាត្រូវបានគេតាមដាននៅពេលចូលទៅទីតាំងវិវាទ។ ក្នុងឆ្នាំ២០១៤ តំណាងអង្គការធ្វើការខាងសិទ្ធិដីធ្លី ត្រូវបានរារាំងជាបន្តបន្ទាប់ក្នុងធ្វើការសម្ភាសទាក់ទងនឹងវិវាទដីធ្លី ដោយមានបុគ្គលិកមួយចំនួនត្រូវ

---

[139] "វីដេអូនេះត្រូវបានផ្សព្វផ្សាយនៅលើទំព័រហ្វេសប៊ុករបស់ TNM ប៉ុន្តែ ក្រោយមកត្រូវបានលុបចេញ។

[140] "អ្នកសារព័ត៌មានត្រូវចាប់ខ្លួនពីបទផ្សាយ 'ព័ត៌មានមិនពិត'", *ភ្នំពេញប៉ុស្តិ៍*, ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨, https://www.phnompenhpost.com/national/journos-held-fake-news; "អ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីបទញុះញង់លើការរាយការណ៍អំពីវិវាទដីធ្លី", *ខ្មែរថាមស៍*, ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨, https://www.khmertimeskh.com/50534495/journalists-accused-of-incitement-over-land-dispute-reporting/; "ឧកញ៉ា ទ្រី ភាព ប្រឈមនឹងអ្នកសារព័ត៌មានពីរនាក់ដែលត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយពត៌មានមិនពិត និងបង្ខូចកេរ្តិ៍ឈ្មោះ ហើយអ្នកសារព័ត៌មានទាំងពីរនាក់ត្រូវបានចាប់ខ្លួន", *ហ្វ្រេសញូវស៍*, http://freshnewsasia.com/index.php/en/localnews/99542-2018-09-19-07-54-29.html (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។

[141] "វាមិនច្បាស់លាស់ទេថាការចោទប្រកាន់នេះត្រូវទម្លាក់ចោល ឬមានការពិន័យជាប្រាក់ ឬនឹងមានការកាត់ក្ដីណាមួយ។

[142] "ក្រុមសិទ្ធិមនុស្សអះអាងការរំខាននៅតែបន្តមាននៅខេត្តឧត្តរមានជ័យ", *ដឹខេមបូឌៀដេលី*, ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤, https://www.cambodiadaily.com/news/rights-group-claims-continued-harassment-in-oddar-meanchey-69650/.

បានឃាត់ឲ្យទៅប៉ុស្តិ៍នគរបាល និងឃុំឃាំងមួយយប់។[143] គួរកត់សម្គាល់ថា ក្នុង**ករណីក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី** គ្មានអង្គការមិនមែនរដ្ឋាភិបាលណាមួយបានរាយការណ៍ថាត្រូវបានគេកំណត់ជាគោលដៅនោះទេ ប៉ុន្តែនៅខែមិថុនា ឆ្នាំ២០១៨ នៅពេលដែល ម.ស.ម.ក ជួបជាមួយនឹងសមាជិកសហគមន៍រងផលប៉ះពាល់ដោយវិវាទនេះ អាជ្ញាធរមូលដ្ឋានរួមមានទាំងនគរបាលផងបានមកតាមដានការសម្ភាស និងព្យាយាមរំខានការប្រជុំដោយចោទប្រកាន់ថា មិនមានការអនុញ្ញាតិជាមុន បើទោះបីជាច្បាប់មិនតម្រូវឱ្យមានក៏ដោយ។ ក្នុង**ករណីក្រុមហ៊ុនអឹមឌីអេស** បុគ្គលិករបស់ ម.ស.ម.ក និងអ្នកផលិតខ្សែភាពយន្តឯកសារដែលជួលដោយអង្គការ អាក់សិនអេតកម្ពុជា ត្រូវបានឃាត់មិនឱ្យចាកចេញពីភូមិសង្គមថ្មី នៅពេលស៊ើបអង្កេតពីការបណ្តេញចេញដោយបង្ខំ។[144] នៅក្នុងឆ្នាំ២០១៧ អាជ្ញាធរខេត្តពោធិ៍សាត់បានប្រាប់ ម.ស.ម.ក ថា អង្គការមិនមែនរដ្ឋាភិបាលកំពុងរារាំងក្នុងការដោះស្រាយវិវាទដីធ្លី ដោយចោទប្រកាន់អង្គការទាំងនោះថា ជាអ្នកផ្សព្វផ្សាយព័ត៌មានមិនពិត និងជាអ្នកបង្កើតការរំពឹងទុកហួសប្រមាណ។ នៅខែឧសភា ឆ្នាំ២០១៨ នៅពេលដែល ម.ស.ម.ក សម្ភាសសមាជិកសហគមន៍ អាជ្ញាធរមូលដ្ឋាន និងនគរបាលបានរំខានកិច្ចប្រជុំនោះដោយចោទថា ម.ស.ម.ក មិនមានឯកសារក្រដាសស្នាមបញ្ជាក់។ នៅទីបំផុត ម.ស.ម.ក អាចបន្តការសម្ភាសបាន ដោយសារតែការ រារាំងនោះមិនអាចកំហិតបានចំពោះសិទ្ធិក្នុងការប្រមូលផ្តុំនិងសេរីភាពនៃការបញ្ចេញមតិ។ នៅពេលដែល ម.ស. ម.ក ជួបជាមួយនឹងអាជ្ញាធរស្រុកនៅ ខែឧសភា ឆ្នាំ២០១៨ ពួកគាត់បានបញ្ជាក់ថា ម.ស.ម.ក និងអ្នកដឹកនាំសហគមន៍កំពុងព្យាយាមបង្កើតក្រុមដោះស្រាយដីធ្លីដែលអាជ្ញាធរនឹងមិនអាចទទួលយកបានឡើយ។

## របកគំហើញទី ៦ ៖ ត្រូវធានាថាជនរងគ្រោះទទួលបានដំណោះស្រាយទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ក្នុងករណីមានការរំលោភបំពានសិទ្ធិមនុស្ស ជនរងគ្រោះត្រូវមានសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ ដំណោះស្រាយនោះមិនត្រឹមតែត្រូវសងសំណងចំពោះការបាត់បង់ធូន់ធួរ ដូចជា (ដី ផ្ទះ ទ្រព្យសម្បត្តិ ផលិតផលដំណាំជាដើម) ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវសងសំណងចំពោះការបាត់បង់បន្ទាប់បន្សំផ្សេងទៀត ដូចជា ការបាត់បង់ប្រាក់ចំណូល ការចំណាយពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីតាំង សំណងទៅលើសុខភាពផ្លូវចិត្តជាដើម។ ក្នុងករណីបណ្តេញចេញដោយបង្ខំ ច្បាប់អន្តរជាតិបានចែងថា ដំណោះស្រាយមានប្រសិទ្ធភាពចំពោះការបណ្តេញចេញដោយបង្ខំ គួររួមបញ្ចូលសំណង់ត្រឡប់មកវិញ ការតាំងទីលំនៅឡើងវិញ ការស្តារនីតិសម្បទា

---

[143] "អាជ្ញាធរខេត្តឧត្តរមានជ័យនៅតែបន្តប្រព្រឹត្តអំពើខុសច្បាប់លើបុគ្គលិកអង្គការសមធម៌កម្ពុជា" *អង្គការលីកាដូ*,ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=360.

[144] "ពោធិ៍សាត់ "ការស្រែកគំរាមលើបុគ្គលិកអង្គការម.ស.ម.ក" (Pursat yells 'cut' on CCHR)",*ភ្នំពេញប៉ុស្តិ៍, ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦,* https://www.phnompenhpost.com/national/pursat-yells-cut-cchr;"សង្គមស៊ីវិលថ្កោលទោសពីការបៀតបៀន និងការរារាំងបុគ្គលិក និងក្រុមអ្នកផលិតវីដេអូនៅខេត្តពោធិ៍សាត់"*អង្គការម.ស.ម.ក,* ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៦ ,https://docs.google.com/viewerng/viewer?url=http://www.cchrcambodia.org/media/files/press_release/645_212jschaoosafcippe_en.pdf.

និងសំណង។[145] គោលការណ៍ ២៥ ដល់ ៣១ នៃគោលការណ៍ណែនាំ របស់អង្គការសហប្រជាជាតិ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស («គោលការណ៍ណែនាំ») ចែងជាពិសេសចំពោះកាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់ដំណោះស្រាយមានប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សដោយសារធុរកិច្ច។ អ្វីដែលសំខាន់នោះ គឺជាដំណើរការដោះស្រាយឥតលម្អៀងនិងប្រកបដោយភាពយុត្តិធម៌[146] និងមានប្រសិទ្ធភាពខ្ពស់ពោលគឺដំណោះស្រាយនោះគឺត្រូវផ្តល់សំណងចំពោះការរំលោភបំពានជាក់ស្តែងណាមួយជាជាង ការដែលគ្រាន់តែអនុវត្តនីតិវិធីដែលគ្មានលទ្ធផល។ លើសពីនេះទៅទៀត ដំណើរការដោះស្រាយនេះត្រូវអាចប្រើបាន មានន័យថាបុគ្គលគ្រប់រូបត្រូវតែយល់ដឹងពីដំណើរការនេះនិងត្រូវតែអាចប្រើប្រាស់បាន ដោយមិនមានការរាំងស្ទះមិនសមស្របណាមួយកើតឡើងឡើយ។[147] ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពនោះ គឺចាំបាច់ត្រូវតែបញ្ឈប់ការរំលោភបំពានដែលមានជាបន្តបន្ទាប់នោះ។[148] ដូចគ្នានេះដែរ ជនល្មើសការរំលោភបំពានសិទ្ធិមនុស្សនឹងត្រូវនាំយកទៅកាត់ទោសដោយរដ្ឋអំណាច។[149] យោងតាមគោលការណ៍ណែនាំ ក្រុមហ៊ុនអាជីវកម្មក៏ត្រូវចូលរួមយ៉ាងសកម្មក្នុងការធានាថាបុគ្គលគ្រប់រូប ដែលសិទ្ធិរបស់ខ្លួនបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារប្រតិបត្តិការក្រុមហ៊ុនអាចទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។[150]

ការស្រាវជ្រាវរបស់ ម.ស.ម.ក បានបង្ហាញថាដំណើរការដោះស្រាយវិវាទធ្វើឡើងទៅតាមករណីមួយៗជាជាងធ្វើឡើងជាលក្ខណៈប្រព័ន្ធ និងបន្ទាប់ពីមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងការខូចខាតមិនអាចជួសជុលបានកើតឡើងរួចប៉ុណ្ណោះ។ ទោះបីជាមានការខិតខំប្រឹងប្រែងច្រើនយ៉ាងណាក្តី សម្រាប់ករណីទាំងបីនេះ ដំណោះស្រាយនៅមិនទាន់បានបញ្ចប់នៅឡើយហើយកំពុងបន្តធ្វើ ហើយករណីនីមួយៗស្ថិតនៅដំណាក់កាលខុសៗគ្នាក្តី។ ជាពិសេស មានការគិតគូរតិចតួចបំផុត ទៅលើដំណោះស្រាយនៃការរំលោភបំពានសិទ្ធិមនុស្សដែលបានកើតមានឡើងនោះ។ ក្រៅពីនេះ ដំណោះស្រាយវិវាទដីធ្លីផ្តោតសំខាន់លើការបាត់បង់ទ្រព្យសម្បត្តិរបស់សហគមន៍ ទោះបីជាកាតព្វកិច្ចអន្តរជាតិតម្រូវកម្ពុជាថា បើមានការរំលោភបំពានសិទ្ធិមនុស្ស ត្រូវផ្តល់ដំណោះស្រាយមានប្រសិទ្ធភាពក៏ដោយ។ ទោះជាមានដំណោះស្រាយក៏ដោយអ្នកផ្តល់បទសម្ភាសន៍ភាគច្រើន

---

[145] "គោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋានស្តីពីការបណ្តេញចេញ និងការប្តូរទីលំនៅដោយយោងលើការអភិវឌ្ឍ" *របស់អ្នកកាយការណ៍ពិសេសស្តីពីលំនៅដ្ឋានសមរម្យ* A/HRC/4/18, កថាខណ្ឌ ៥៩, https://www.ohchr.org/Documents/Issues/Housing/Guidelines_en.pdf( "គោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋានអំពីការបណ្តេញចេញ និងការប្តូរទីលំនៅដោយយោងលើការអភិវឌ្ឍនៃអង្គការសហប្រជាជាតិ")។

[146] "គោលការណ៍ណែនាំអង្គការសហប្រជាជាតិ ទំព័រ25។

[147] "គោលការណ៍ណែនាំអង្គការសហប្រជាជាតិ **ទំព័រ** 26។

[148] "មតិយោបល់ទូទៅ លេខ 31 លក្ខណៈនៃកាតព្វកិច្ចផ្លូវច្បាប់ទូទៅដែលដាក់លើភាគីជារដ្ឋចំពោះអនុសញ្ញា" *គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ* ខែឧសភា ឆ្នាំ2004 កថាខណ្ឌ 15 ("មតិយោបល់ទូទៅ លេខ 31 របស់ UN HRC")
http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d%2FPPRiCAqhKb7yhsjYoiCfMKoIRv2FVaVzRkMjTnjRO%2Bfud3cPVrcM9YR0iW6Txaxgp3f9kUFpWoq%2FhW%2FTpKi2tPhZsbEJw%2FGeZRASjdFuuJQRnbJEaUhby31WiQPl2mLFDe6ZSwMMvmQGVHA%3D%3D.

[149] "មតិយោបល់ទូទៅ លេខ 31 របស់ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា កថាខណ្ឌ 18។

[150] "គោលការណ៍ណែនាំអង្គការសហប្រជាជាតិ **ទំព័រ** 19។

បានឆ្លើយថាពួកគេ គ្មានជម្រើសផ្សេងក្រៅតែពីការទទួលយកដំណោះស្រាយនោះឡើយ។ ពួកគេបានរៀបរាប់ថា ដំណោះស្រាយទាំងនោះគឺមិនគ្រប់គ្រាន់ឡើយ។

ក្នុងករណីទាំងបី ក្រុមអាជ្ញាធរដែល ម.ស.ម.ក បានសម្ភាសន៍បានឆ្លើយថា វិវាទដីធ្លីនេះមិនទាន់បានដោះស្រាយនៅឡើយទេដោយសារខ្វះការសហការពីសហគមន៍រងផលប៉ះពាល់ មានន័យថាសហគមន៍មានការ «លំបាក» ខ្លាំងណាស់ដោយសារពួកគេមិនទទួលយកដំណោះស្រាយដែលបានលើកឡើងនោះ។ លើសពីនេះទៅទៀត អាជ្ញាធរមួយចំនួនបានប្រាប់ ម.ស.ម.ក ថាមិនមានការរំលោភបំពានសិទ្ធិមនុស្សណាមួយឡើយ ហើយក៏ថាមិនមានការបណ្តេញប្រជាពលរដ្ឋណាម្នាក់ចេញដោយបង្ខំឡើយ។ ដូចតាមរយៈកិច្ចសម្ភាសន៍នេះ ដោយសារតំបន់សេដ្ឋកិច្ចពិសេស ឬសម្បទានដីសេដ្ឋកិច្ចដែលទទួលបានសិទ្ធិអនុញ្ញាតពីរដ្ឋាភិបាល ដូច្នេះត្រូវគោរពនិងគ្រប់យ៉ាងទាំងអស់ដែលអនុវត្តគឺត្រឹមត្រូវតាមច្បាប់។ ជំហររបស់ពួកគេ គឺថាដោយសារក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណពីរាជរដ្ឋាភិបាល ដូច្នេះពុំមានការរំលោភបំពានច្បាប់ណាមួយឡើយ។ ម្យ៉ាងវិញទៀត សមាជិកសហគមន៍ស្ទើរតែទាំងអស់ដែលផ្តល់បទសម្ភាសន៍បានប្រាប់ ម.ស.ម.ក ថាតាមទស្សនៈរបស់ពួកគាត់ ឧបសគ្គចម្បងក្នុងការដោះស្រាយវិវាទនេះ គឺខ្វះការខិតខំប្រឹងប្រែងពីសំណាក់ក្រុមអាជ្ញាធរ ដែលហាក់មិនបានគិតគូរសមស្របណាមួយទៅលើស្ថានភាពរបស់ពួកគេ និងអ្នកជួយរកផលប្រយោជន៍ឱ្យក្រុមហ៊ុនដែលរំលោភលើដីរបស់សហគមន៍រងផលប៉ះពាល់ទាំងនោះ។

## ៦.១. វិវាទដីធ្លីបន្តអូសបន្លាយរ៉ឺយ៉ូវ និងមានផលប៉ះពាល់យ៉ាងខ្លាំង

វិវាទដីធ្លីដែលអូសបន្លាយរយៈពេលពី ៨ ទៅ ១០ឆ្នាំ បានបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរដល់គ្រួសាររងផលប៉ះពាល់ជាង ១.៦០០ គ្រួសារ។ ចំពោះអ្នកដែល ម.ស.ម.ក បានសម្ភាសន៍ បានទទួលរងការខូចខាតឈានដល់ការខាតបង់យ៉ាងធ្ងន់ធ្ងរ និងបង្កផលប៉ះពាល់ដល់ផ្លូវចិត្ត និងស្មារតី របស់ពួកគាត់ផងដែរ។ ទោះបីក្រុមអាជ្ញាធរនៅគ្រប់លំដាប់ថ្នាក់ធ្វើការខិតខំប្រឹងប្រែងយ៉ាងណាក្តី ក៏លទ្ធផលនៃការទទួលបានពីដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់ករណីទាំងបីនេះនៅតែមានកម្រិតតិចតួចនៅឡើយ។

ក្នុង**ករណីក្រុមហ៊ុន មីតផ័រ ភូល** ប្រជាពលរដ្ឋប្រហែល ៧១២គ្រួសារ[151] បានទទួលរងផលប៉ះពាល់ដោយសារវិវាទដីធ្លី[152] ដែលបានកើតឡើងតាំងពីឆ្នាំ២០០៨ មកម្ល៉េះ។ បច្ចុប្បន្ននៅសល់ប្រជាពលរដ្ឋចំនួន ៣៨៣គ្រួសារ ដែលនៅតែមិនទាន់ទទួលបានដំណោះស្រាយនៅឡើយ។[153] ក្នុង**ករណីក្រុមហ៊ុន សុកហ៊ីន**

[151] 1 គ្រួសារ = ឈ្មោះ 1 ក្នុងដីមួយកន្លែងដែលបានប្រើ/បាត់បង់។

[152] ប្រភព៖ អង្គការសមធម៌កម្ពុជា (Equitable Cambodia)។

[153] យោងតាមបញ្ជីដែលចងក្រងដោយអង្គការសមធម៌កម្ពុជានៅពេលស្រាវជ្រាវដល់ទីកន្លែង និងដោយមានការសហការពីសហគមន៍រងផលប៉ះពាល់។

**ខេស៊ីឌី** ប្រជាពលរដ្ឋប្រមាណចំនួន៨០០គ្រួសារ ក្នុងភូមិចំនួនប្រាំពីរបានរងផលប៉ះពាល់[154] ចាប់តាំងពីឆ្នាំ ២០០៨ មកម្ល៉េះ។ ម.ស.ម.ក មិនអាចកំណត់អត្តសញ្ញាណជាក់លាក់ពីចំនួនអ្នកដែលនៅកំពុងរង់ចាំដំណោះស្រាយបានទេ។ ប៉ុន្តែ បច្ចុប្បន្នអ្នកភូមិរងផលប៉ះពាល់ចំនួន៦៤០នាក់ បានចូលរួមក្នុងដំណើរការដោះស្រាយវិវាទនេះ។ ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស** ប្រជាពលរដ្ឋយ៉ាងហោចណាស់៩៧ គ្រួសារ មកពីភូមិចំនួនបីផ្សេង គ្នា បានទទួលរងផលប៉ះពាល់ដោយសារបញ្ហាដីធ្លីនេះ[155] ចាប់តាំងពីចុងឆ្នាំ២០១០ មកម្ល៉េះ។ ក្នុងពេលកំពុងសរសេរអត្ថបទនេះ ប្រជាពលរដ្ឋចំនួន១៥ គ្រួសារ នៅកំពុងរង់ចាំដំណោះស្រាយនៅឡើយ ពោលគឺជិតមួយទសវត្សរ៍ទៅហើយ ក្រោយពីចាប់ផ្តើមវិវាទដីធ្លីនេះ។

ក្នុងករណីទាំងបីនេះ ក្រៅតែពីការបណ្តេញចេញដោយបង្ខំ ការបាត់បង់ផ្ទះសម្បែង និងទ្រព្យសម្បត្តិជនរងគ្រោះទាំងអស់ដែល ម.ស.ម.ក បានសម្ភាសន៍ បានរាយការណ៍ថា ពួកគាត់កំពុងតែប្រឈមនឹងភាពក្រីក្រកាន់តែខ្លាំងឡើងៗ ដែលបណ្តាលមកពីការបាត់បង់ប្រាក់ចំណូលដោយសារការបាត់បង់ដីកសិកម្មរបស់ពួកគាត់។ ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស និងក្រុមហ៊ុន មីតផ៉រ ភូល** អ្នកភូមិបានប្រាប់ ម.ស.ម.ក ថា ពួកគាត់ចាំបាច់ត្រូវខ្ចីប្រាក់ពីគេដើម្បីរស់ ដូច្នេះហើយទើបបានជាមានការជាប់បំណុល ហើយអ្នកខ្លះត្រូវលក់ផ្ទះនិងទ្រព្យសម្បត្តិដើម្បីសងបំណុលទៀតផង។ អ្នកភូមិជាច្រើន បានឱ្យកូនរបស់ខ្លួនឈប់រៀនដោយសាររឿងនេះផងដែរ។ ក្នុង**ករណីក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី** ជនរងគ្រោះបានប្រាប់ពីការបាត់បង់សិទ្ធិទទួលបានធនធានធម្មជាតិដូចជាប្រភពទឹក សត្វ និងតំបន់នេសាទសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគាត់។ ពួកគាត់ក៏បានប្រាប់ថា សុខភាពក៏កាន់តែយ៉ាប់យឺតជាងមុនដែរ ដែលពួកគេជឿថា ដោយសារជាតិគីមីចេញពីចម្ការកៅស៊ូ និងរោងចក្រដែលមាននៅក្នុងទឹកបឹង។ ក្នុងករណីទាំងបីនេះ អ្នកដែលផ្តល់បទសម្ភាសន៍បានជួបនឹងបញ្ហាផ្លូវចិត្តមួយចំនួន ដូចជាការបាក់ទឹកចិត្ត និងអារម្មណ៍តានតឹង ហើយក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស និងក្រុមហ៊ុន មីតផ៉រ ភូល** ពួកគាត់ក៏បានរាយការណ៍ អំពីការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដែលបានកើតឡើង ដោយសារតែពីរឿងនេះផងដែរ។ ក្នុងករណីទាំងពីរនេះ ជនរងគ្រោះក៏បានប្រាប់ថា សមាជិកគ្រួសារ និងកូនៗរបស់ពួកគាត់ ច្រើនបានធ្វើចំណាកស្រុកចេញពីតំបន់នោះដោយសារតែវិវាទដីធ្លីនេះផងដែរ។

---

[154]"អាជីវកម្ម និងសិទ្ធិមនុស្សនៅកម្ពុជា មានសសរស្តម្ភចំនួនបី" *អង្គការ ម.ស.ម.ក* ខែវិច្ឆិកា ឆ្នាំ2010 កថាខណ្ឌ 188 https://cchrcambodia.org/admin/media/report/report/english/2010-11-30-%20Full%20Report%20%20Business%20and%20Human%20Rights%20in%20Cambodia%20Constructing%20the%20Three%20Pillars.pdf.

[155]"អង្គការសង្គមថ្មី កណ្តាល និងអង្គការឯកភាព *សូមមើល* "របាយការណ៍សង្ខេបអំពីផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន អឹមឌីអេស ក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់" របាយការណ៍រួម *អង្គការ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ អាដហុក, ម.ស.ម.ក, លីកាដូខេត្តពោធិ៍សាត់*, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ ទំព័រ២-៤ (តែមានឯកសារក្រដាសប៉ុណ្ណោះនៅអង្គការវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា,និងអង្គការម.ស.ម.ក)។

## ៦.២. ការប្រើប្រាស់យន្តការជាច្រើនដើម្បីដោះស្រាយវិវាទដីធ្លី

អាជ្ញាធរហាក់បានធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការដោះស្រាយវិវាទដីធ្លី។ ប៉ុន្តែ មនុស្សជាច្រើនដែល ម.ស.ម.ក បានសម្ភាសន៍ បានប្រាប់ថាគ្មាននរណាម្នាក់ពេញចិត្តនឹងដំណោះស្រាយវិវាទដីធ្លីនេះទេ។ ក្នុងករណីទាំងបីនេះ ការដោះស្រាយនៅតែកំពុងដំណើរការ ហើយករណីនីមួយៗ ស្ថិតនៅដំណាក់កាលខុសគ្នាក្តី។

ដំណើរការដោះស្រាយជាច្រើន ត្រូវបានអនុវត្តអស់រយៈពេលជាច្រើនឆ្នាំមកហើយ ពេលខ្លះការអនុវត្តដំណោះស្រាយច្រើនប្រព្រឹត្តទៅក្នុងពេលតែមួយផងដែរ។ ភាគីទាំងអស់ចូលរួមជាមួយសហគមន៍រងផលប៉ះពាល់ ឬ តំណាងសហគមន៍ទាំងនោះ រួមមានក្រុមអាជ្ញាធរមូលដ្ឋាន និងតំណាងក្រុមហ៊ុន។ ភាគីខ្លះចូលរួមជាមួយអាជ្ញាធរ ថ្នាក់ខេត្ត ថ្នាក់ជាតិ ឬអង្គការអន្តរជាតិដូចជា អង្គការសហប្រជាជាតិ ឬបណ្តាញអន្តរជាតិនានា។ ក្នុងករណីទាំងអស់ សហគមន៍ដែលរងផលប៉ះពាល់បានរកក្រុមអាជ្ញាធរនៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ តាមរយៈការដាក់ញត្តិ លិខិតសុំអន្តរាគមន៍ និងពាក្យបណ្តឹងជាដើម ជាពិសេសគឺដាក់ទៅកាន់នាយករដ្ឋមន្ត្រី ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងរដ្ឋសភាជាតិ។

យន្តការផ្សេងទៀតដែលបានប្រើដូចជា ការជួបប្រជុំជាមួយពហុភាគីដែលពាក់ព័ន្ធ និងការតស៊ូមតិអន្តរជាតិ។ **ករណីក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី** នៅឆ្នាំ២០១៥ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានរៀបការជួបប្រជុំជាមួយពហុភាគីពាក់ព័ន្ធពីរដង ក្នុងមួយឆ្នាំ ដែលរួមមានទាំងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើករណីនេះ ដែលមានគោលបំណងជំរុញឱ្យមាន តម្លាភាពតាមរយៈការចែករំលែកព័ត៌មាន និងលើកកម្ពស់ការសម្របសម្រួលសកម្មភាពតាមរយៈតួអង្គផ្សេងៗគ្នា។ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិកក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី អំពីធុរកិច្ច និងសិទ្ធិមនុស្ស និងអំពីសិទ្ធិជនជាតិដើមភាគតិច ព្រមទាំងបានជួយពួកគេក្នុងការរៀបចំគោលការណ៍ស្តីពីការគ្រប់គ្រងទទួលបណ្តឹងជំទាស់ពីខាងក្រៅផងដែរ។[156] **ក្នុងករណីក្រុមហ៊ុន មីតផល ភូល** មានការដាក់ពាក្យបណ្តឹងប្តឹងក្រុមហ៊ុននេះទៅកាន់បណ្តាញអន្តរជាតិនៃអ្នកផលិតស្ករដែលមានឈ្មោះថា គំនិតផ្តួចផ្តើមស្ករល្អប្រសើរជាងមុន (បច្ចុប្បន្នហៅថាប៊ុនស៊ូក្រូ) នៅឆ្នាំ២០១១ និងបានដាក់ពាក្យបណ្តឹងជាថ្មីម្តងទៀត នៅឆ្នាំ២០១៦[157] បន្ទាប់ពីក្រុមហ៊ុន មីតផល ភូល ត្រូវបាន

---

[156] "នៅក្នុងរបាយការណ៍ស្តីពីចីរភាពឆ្នាំ២០១៧ របស់ខ្លួន, Socfin S.A. សំដៅដល់នីតិវិធីស្តីពីការគ្រប់គ្រងការឈើចាប់ខាងក្រៅនៅកម្ពុជាដែលត្រូវបានធ្វើបទបង្ហាញជាផ្លូវការដល់សហគមន៍ និងក្រុមអាជ្ញាធរនៅមូលដ្ឋាន និងរួមមានសេចក្តីសង្ខេបជាភាសាខ្មែរ "របាយការណ៍ស្តីពីចីរភាពឆ្នាំ២០០៧ កសិកម្មត្រូពិចប្រកបដោយការទទួលខុសត្រូវ" *Socfin*, ទំព័រ 27, http://www.socfin.com/frontend/files/userfiles/files/2017%20Socfin_Sustainability%20report_LR.pdf.

[157] "ពាក្យបណ្តឹងប្តឹងទៅកាន់អង្គការ Better Sugar Cane Initiative ការឆ្លើយតបៈ ក្រុមហ៊ុន មីតផល ភូល អង្គការសមធម៌កម្ពុជា អង្គការអភិវឌ្ឍន៍ដោយមានការចូលរួមអន្តរជាតិ *អង្គការលីកាដូ* ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦, https://www.inclusivedevelopment.net/wp-content/uploads/2016/02/Amended-Complaint-to-Bunsucro-re-Mitr-Phol-Group-05-February-2016.pdf.

អនុញ្ញាតិឱ្យចូលក្នុងបណ្ដាញនោះវិញ។ ទោះបីមានការខិតខំប្រឹងប្រែងជាច្រើន ក្នុងការតាមដានពីអង្គការមិនមែនរដ្ឋាភិបាលក៏ដោយក៏បណ្ដាញនេះគ្រាន់តែបានចាត់វិធានការតិចតួចប៉ុណ្ណោះមកទល់បច្ចុប្បន្ននេះ។ នៅឆ្នាំ ២០១៣ សហគមន៍ក៏បានដាក់ពាក្យបណ្ដឹងទៅកាន់គណៈកម្មការសិទ្ធិមនុស្សប្រទេសថៃដែលបានសន្និដ្ឋាននៅក្នុងឆ្នាំ២០១៥ ថា ការរំលោភបំពានសិទ្ធិមនុស្សជាប្រព័ន្ធ បានកើតមានឡើងនៅក្នុងចន្លោះឆ្នាំ២០០៨ និង ២០០៩។[158] គួរឱ្យសោកស្ដាយ ដែលពុំមានការចាត់វិធានការដាក់លាក់ណាមួយ ត្រូវបានធ្វើឡើងពាក់ព័ន្ធ នឹងបញ្ហានេះឡើយ។ ក្រុមហ៊ុនចម្រុះជាតិដែលបានទិញស្ករសពីក្រុមហ៊ុន មីតផ័រ ភូល រួមមានឈ្មោះដូចជា កូកា-កូឡា ប៉ិបស៊ី ណេសត្លេ និង ម៉ាស (Mars) ត្រូវបានអង្គការមិនមែនរដ្ឋាភិបាលបានស្នើសុំអន្តរាគមន៍ដើម្បីដាក់សម្ពាធលើក្រុមហ៊ុន មីតផ័រ ភូល ឱ្យចូលរួមក្នុងដំណើរការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា និងផ្ដល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពមួយ។ តែរហូតដល់ពេលនេះ ដំណោះស្រាយដែលបានអនុវត្ត គឺមានតិចតួចបំផុត។[159]

ក្នុងចំណោមករណីទាំងបី មានតែករណីមួយប៉ុណ្ណោះ ដែលសហគមន៍បានដាក់ពាក្យបណ្ដឹងទៅកាន់តុលាការកម្ពុជា។ ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស** កាលពីឆ្នាំ២០១៤ សមាជិកសហគមន៍មួយចំនួនបានដាក់ពាក្យបណ្ដឹងទៅកាន់អយ្យការតុលាការខេត្តពោធិ៍សាត់ ប្ដឹងអភិបាលរងខេត្តម្នាក់ ដែលប្រើកម្លាំងប្រដាប់អាវុធចម្រុះមកឈូសឆាយ និងបានបំផ្លាញផ្ទះសម្បែង និងចម្ការរបស់ប្រជាពលរដ្ឋ ១១គ្រួសារ កាលពីខែវិច្ឆិកា ឆ្នាំ ២០១៤ កន្លងមកនេះនៅលើដីតំបន់សេដ្ឋកិច្ចពិសេស។ ពាក្យបណ្ដឹងនេះបានចោទប្រកាន់ថា អភិបាលរងខេត្តគឺជាអ្នកបានបញ្ជាកងកម្លាំងប្រដាប់អាវុធចម្រុះឱ្យធ្វើការបំផ្លិចបំផ្លាញផ្ទះសម្បែង និងចម្ការរបស់ខ្លួន។ ពួកគាត់បានប្ដឹងទារសំណងចំនួន ២.០០០ ដុល្លាសហរដ្ឋអាមេរិកក្នុងមួយគ្រួសារ និងសុំឱ្យចាត់វិធានការផ្លូវច្បាប់ទៅលើអភិបាលរងខេត្តនេះផងដែរ។ ក្នុងកំឡុងពេលសម្ភាសន៍សមាជិកសហគមន៍ទាំងបួនរូបនោះ ពួកគេនិយាយថាពុំមានអ្វីកើតឡើងទេចាប់តាំងពីដាក់ពាក្យបណ្ដឹងនោះមក។

---

[158] "របាយការណ៍ស៊ើបអង្កេតលេខ៖ 1003/2015 ការឆ្លើយតប៖ សិទ្ធិមនុស្សសហគមន៍៖ ក្រុមហ៊ុនស្ករ មីតផ័រ ភូល ផលប៉ះពាល់អវិជ្ជមានលើប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកសំរោង និងស្រុកចុងកាល ខេត្តឧត្តរមានជ័យ ភូមិភាគឦសាននៃប្រទេសកម្ពុជា" *គណៈកម្មការសិទ្ធិមនុស្សថៃ* ថ្ងៃទី១២ខែតុលា ឆ្នាំ២០១៥, https://www.inclusivedevelopment.net/wp-content/uploads/2016/09/Thai-Human-Rights-Commission-Report_Mitr-Phol_Unofficial-translation-.docx; *សូមមើល* ការបង្ហាញពីការរំលោភបំពានរបស់ក្រុមហ៊ុនស្ករសយក្ស", *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី 14 ខែសីហា ឆ្នាំ2014,https://www.phnompenhpost.com/national/sugar-giant-spotlight-abuse; "ពាក្យបណ្ដឹងថ្មីតវ៉ាពីសមាជិកភាពរបស់ក្រុមហ៊ុនថៃនៅក្នុងក្រុមស្ករសប្រកបដោយចីរភាព" *IDI* ថ្ងៃទី១៩ខែកុម្ភៈ ឆ្នាំ២០១៦, https://www.inclusivedevelopment.net/idi-and-partners-challenge-thai-companys-membership-in-sustainable-sugar-group/.

[159] "តុលាការថៃទទួលយកករណីបណ្ដឹងអំពីការរឹបអូសយកដីប្រជាពលរដ្ឋកម្ពុជា បញ្ជាឱ្យមានការដោះស្រាយ" *IDI* ថ្ងៃទី05 ខែកញ្ញា ឆ្នាំ2018 https://www.inclusivedevelopment.net/thai-court-accepts-cambodian-land-grabbing-case-orders-mediation/.

## ៦.៣.ដំណោះស្រាយដែលបានផ្តល់ គឺពុំមែនជាដំណោះស្រាយមានប្រសិទ្ធភាពនៅក្រោមច្បាប់សិទ្ធិមនុស្សឡើយ

ប្រជាពលរដ្ឋជាច្រើនបានទទួលយកយន្តការដោះស្រាយវិវាទដីធ្លីដែលបានផ្តល់ជូន គឺដោយសារការភ័យខ្លាច ហើយប្រសិនបើពួកគាត់បដិសេធទទួលយក នឹងត្រូវគេទុកចោលមិនដោះស្រាយឱ្យទាំងគ្នា។ ជាពិសេសនៅពេលពិភាក្សាអំពីដំណោះស្រាយ គឺមានការគិតគូរតិចតួចបំផុតទៅលើដំណោះស្រាយនៃការរំលោភបំពានសិទ្ធិមនុស្សដែលកើតមានឡើង តែផ្ទុយទៅវិញយន្តការដោះស្រាយវិវាទដីធ្លី គឺផ្តោតសំខាន់តែលើការបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះប៉ុណ្ណោះ។

ដោយយោងតាមច្បាប់សិទ្ធិមនុស្ស ដំណោះស្រាយត្រូវធ្វើឡើងឱ្យទាន់ពេលវេលា និងដោះស្រាយគ្រប់ទិដ្ឋភាពទាំងអស់នៃការរំលោភបំពានសិទ្ធិមនុស្ស។ ជនរងគ្រោះទាំងអស់ត្រូវមានសិទ្ធិទទួលបានសំណងចំពោះការបាត់បង់ទ្រព្យសម្បត្តិដោយមិនគិតអំពីថាពួកគេមានប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិឬគ្មាននោះឡើយ។[160] ជាពិសេសសំណងជាប្រាក់ចំពោះការបណ្តេញចេញដោយបង្ខំ ត្រូវគ្របដណ្តប់លើការខូចខាតដែលអាចវាយតម្លៃជាប្រាក់បានទាំងអស់ ដូចជាការបាត់បង់អាយុជីវិត ឬអវៈយវៈ ឬសត្វពាហនៈ/ដី/ដើមឈើ/ដំណាំ គ្រោះថ្នាក់រាងកាយ ឬផ្លូវចិត្ត បាត់បង់ឱកាស ដូចជាការងារការអប់រំ និងអត្ថប្រយោជន៍សង្គម ការខូចខាតទ្រព្យសម្បត្តិ និងការបាត់បង់ការរកប្រាក់ចំណូលរួមមានការបាត់បង់សក្តានុពលនៃការរកប្រាក់ចំណូល ការខូចខាតផ្នែកសីលធម៌ ការចំណាយនានាដែលត្រូវការសម្រាប់ជំនួយផ្លូវច្បាប់ពីអ្នកជំនាញ ថ្នាំពេទ្យ និងសេវាវេជ្ជសាស្ត្រ ព្រមទាំងសេវាចិត្តសាស្ត្រ និងសង្គម ការចំណាយរដ្ឋបាលការបាត់ការតាំងទីលំនៅឡើងវិញ និងមធ្យោបាយដឹកជញ្ជូន។[161] ក្នុងករណីដែលដីត្រូវបានគេដកហូតយកជនរងគ្រោះត្រូវទទួលបានសំណងលើដី ដែលមានគុណភាពទំហំនិងតម្លៃស្មើគ្នា ឬល្អជាងនោះ។[162] ក្នុងករណីមានការតាំងទីលំនៅថ្មីជាថ្មី រដ្ឋត្រូវធានាថាប្រជាពលរដ្ឋ អាចទទួលបានចំណីអាហារចាំបាច់ ដែលមានគុណភាពនិងសុវត្ថិភាព អនាម័យ ទឹកស្អាតនិងជម្រក និងផ្ទះសម្លៀងសម្លៀក បំពាក់សមរម្យ សេវាវេជ្ជសាស្ត្រសំខាន់ៗ ប្រភពចិញ្ចឹមជីវិត ចំណីសម្រាប់សត្វចិញ្ចឹម និងការទទួលបានធនធានទ្រព្យសម្បត្តិដែលបានពឹងអាស្រ័យពីមុនមក ព្រមទាំងការអប់រំសម្រាប់កូនៗ និងកន្លែងថែទាំកុមារផងដែរ។[163]

ដំណោះស្រាយបីប្រភេទត្រូវបានគេអនុវត្តៈ គោលនយោបាយស្បែកខ្លា សំណងជាប្រាក់ និងការដោះដូរដី។

---

[160] "គោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋាននៃអង្គការសហប្រជាជាតិស្តីពីការបណ្តេញចេញ និងការប្តូរទីលំនៅដោយយោងលើការអភិវឌ្ឍ កថាខណ្ឌ 61។

[161] "គោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋាននៃអង្គការសហប្រជាជាតិស្តីពីការបណ្តេញចេញ និងការប្តូរទីលំនៅដោយយោងលើការអភិវឌ្ឍ កថាខណ្ឌ 60, 63។

[162] "គោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋាននៃអង្គការសហប្រជាជាតិស្តីពីការបណ្តេញចេញ និងការប្តូរទីលំនៅដោយយោងលើការអភិវឌ្ឍ កថាខណ្ឌ 60។

[163] "គោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋាននៃអង្គការសហប្រជាជាតិស្តីពីការបណ្តេញចេញ និងការប្តូរទីលំនៅដោយយោងលើការអភិវឌ្ឍ កថាខណ្ឌ 52។

*គោលនយោបាយស្បែកខ្លា និងដីចម្ការជាលក្ខណៈគ្រួសារ*

ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស** អាជ្ញាធរថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិបានចុះទៅដោះស្រាយវិវាទដីធ្លី។ គ្រួសាររងផលប៉ះពាល់ភាគច្រើន មើលឃើញដីរបស់ពួកគាត់ត្រូវបានគេបោះបង្គោលកំណត់ព្រំក្នុងកំឡុងពេលការអនុវត្តបទបញ្ជាលេខ ០០១។[164] ប៉ុន្តែដីឡូតិ៍របស់ ២៣គ្រួសារ គឺមិនទាន់មានការបោះបង្គោលកំណត់ព្រំនៅឡើយទេ ដោយសារក្រុមហ៊ុន អឹមឌីអេស បានហាមអ្នកស្ម័គ្រចិត្តវាស់ដីទាំងនោះ ដោយអះអាងថាដីនោះជាដីដែលមានវិវាទ ដូច្នេះគឺមិននៅក្នុងវិសាលភាពបទបញ្ជាលេខ០០១ ឡើយ។[165] ប្រជាពលរដ្ឋចំនួនបួនគ្រួសារក្នុងចំណោម ២៣គ្រួសារ អាចបន្តនៅលើផ្នែកខ្លះ ឬដីទាំងអស់របស់ខ្លួនបានដោយយោងតាមគោលនយោបាយស្បែកខ្លា។ ប៉ុន្តែទោះបីដំណើរការនេះផ្តល់ការចេញប័ណ្ណកម្មសិទ្ធិដីក៏ដោយ ក៏ពួកគាត់មិនទាន់បានទទួលបាននៅឡើយទេរហូតមកដល់ពេលនេះ។ ក្នុង **ករណីក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី** នៅឆ្នាំ២០០៩ ប្រជាពលរដ្ឋចំនួន ១៥០ គ្រួសារ បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី ដោយទទួលយក «ដីចម្ការគ្រួសារ»[166] គឺជាដីឡូតិ៍នៅក្នុងបរិវេណសម្បទានដីសេដ្ឋកិច្ចដែលក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី នឹងរៀបចំដីនិងដីចម្ការនិងទីតាំងដីដែលគ្រួសារនីមួយៗ នឹងអាចដាំដុះ ប្រមូលផល និងត្រូវលក់កៅស៊ូឱ្យទៅក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី។ មិនយូរប៉ុន្មានក្រោយមក គ្រួសារជាច្រើនបានដឹងថា កិច្ចសន្យានោះតម្រូវឱ្យពួកគាត់ «ជួលដី» ពីក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី រយៈពេល៦០ឆ្នាំ ដូច្នេះហើយទើបពួកគាត់បានបញ្ចប់កិច្ចសន្យានោះ។ មកទល់បច្ចុប្បន្ននេះ ម.ស.ម.ក មិនមានទិន្នន័យចំនួនសរុបនៃគ្រួសាររងផលប៉ះពាល់ ដែលបានទទួលយកទម្រង់ដោះស្រាយវិវាទដីធ្លីនេះទេ ក៏ប៉ុន្តែ ការចរចាជាថ្មីទៅលើកិច្ចសន្យាទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការសម្រុះសម្រួលជាបន្តបន្ទាប់ដែលបានពិភាក្សាដូចខាងក្រោម។

*សំណងជាប្រាក់*

ក្នុងករណីមានជម្រើសក្នុងការសងសំណងជាប្រាក់ ចំនួនទឹកប្រាក់ដែលស្នើឡើងនោះ គឺមិនគ្រប់គ្រាន់ក្នុងការរ៉ាប់រងលើការបាត់បង់ទាំងអស់នោះទេ និងមិនអាចឱ្យជនរងគ្រោះតាំងទីលំនៅឡើងវិញនៅកន្លែងផ្សេងទៀតដែលមានលក្ខខណ្ឌដូចគ្នានេះដូចដែលពួកគាត់មានមុនពេលវិវាទនោះឡើយ។ ក្នុង**ករណីក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី** សមាជិកសហគមន៍ដែលរងផលប៉ះពាល់ជាច្រើននាក់ បានទទួលយកសំណងជាប្រាក់នៅចន្លោះឆ្នាំ ២០០៩ និង២០១២។ សមាជិកសហគមន៍រងផលប៉ះពាល់ដែល ម.ស.ម.ក បានជួបនៅ ឆ្នាំ២០១៧ បាន

---

[164]"អង្គការ ម.ស.ម.ក មិនមានព័ត៌មានពីចំនួនប្រជាពលរដ្ឋដែលមានដីបោះបង្គោលកំណត់ព្រំដីជាក់ស្តែង និងចំនួនប្រជាពលរដ្ឋដែលអាចទទួលបានប័ណ្ណកម្មសិទ្ធិដីទេ។ អង្គការម.ស.ម.កក៏មិនអាចទទួលបានព័ត៌មានពីចំនួននៃការបោះបង់ដំណើរការដោះស្រាយវិវាទដីធ្លីជាធម្មតាដែរ។

[165]"*សូមមើល*"របាយការណ៍សង្ខេបអំពីផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន MDS ក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់" របាយការណ៍រួម *អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា, មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍, អាដហុក, ម.ស.ម.ក, លីកាដូខេត្តពោធិ៍សាត់*, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ ទំព័រ២-៤ (តែមានឯកសារក្រដាសប៉ុណ្ណោះនៅអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការម.ស.ម.ក)។

[166]"ពេលខ្លះហៅថា "កៅស៊ូលក្ខណៈគ្រួសារ"។

រាយការណ៍ថា ពុំមែនគ្រប់ៗគ្នាទទួលបានសំណងដូចគ្នាចំពោះដីទំហំដូចគ្នានោះទេ អ្នកខ្លះទទួលបាន ១០០ ដុល្លារអាមេរិកក្នុងមួយហិកតា ចំណែកអ្នកផ្សេងទៀត ទទួលបាន២០០ដុល្លារអាមេរិកក្នុងមួយហិកតា។ អ្នកខ្លះបាននិយាយថាសំណងជាប្រាក់មិនគ្រប់គ្រាន់សម្រាប់តែតម្លៃដីនោះផងទេ ពោលគឺ សម្រាប់តែតម្លៃដើមឈើដែលបានដាំនៅលើដីទាំងនោះប៉ុណ្ណោះដែលប្រជាពលរដ្ឋទទួលបានតែ១០.០០០ រៀល(២.៥ ដុល្លារអាមេរិក) ក្នុងមួយដើម។ អាជ្ញាធរបានពន្យល់ថា ទឹកប្រាក់ទទួលបានខុសគ្នាទៅតាមគ្រួសារខុសគ្នាដែរ ដោយគ្រួសារនីមួយៗទៅចរចាដោយខ្លួនឯងជាមួយក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី ។ អ្នកភូមិមួយចំនួនបានប្រាប់អំពីអារម្មណ៍ដែលត្រូវគេបង្ខំឱ្យទទួលយកសំណងនេះ ដោយសារតំណាងក្រុមហ៊ុនបានប្រាប់ពួកគាត់ថា ប្រសិនបើពួកគាត់មិនទទួលយកទេ ពួកគាត់នឹងមិនទទួលបានអ្វីទាំងអស់ ប៉ុន្តែ អាជ្ញាធរបានច្រានចោលការចោទប្រកាន់នេះ ដោយបញ្ជាក់ថាសមាជិកសហគមន៍រងផលប៉ះពាល់ជាច្រើននាក់ បានជ្រើសរើសយកជម្រើសនេះ។ ពួកគាត់បានប្រាប់បន្ថែមថា អ្នកភូមិមួយចំនួនដែលបានទទួលសំណងពីមុន ឥឡូវនេះកំពុងទាមទារប្រាក់បន្ថែមទៀត ដោយសារតម្លៃដីបានកើនឡើង ប៉ុន្តែ ក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី បានប្រាប់ ម.ស.ម.ក កាលពី ឆ្នាំ២០១៧ ថា សំណងជាប្រាក់ដែលបានផ្តល់ឱ្យនោះគឺខ្ពស់ជាងសំណង ដែលបានកំណត់នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមទីមួយ។ បញ្ហាមួយគឺថា តម្លៃដីកើនឡើងខ្លាំងនៅប៉ុន្មានឆ្នាំចុងក្រោយនេះដោយ ធ្វើឱ្យមានការមិនសប្បាយចិត្តរវាងអ្នកដែលទទួលបានសំណងជាប្រាក់ នៅដំណាក់កាលដំបូងនៃវិវាទនេះ និងអ្នកដែលទើបទទួលបានសំណងនៅពេលថ្មីៗនេះដោយសារសំណងនោះ មានភាពខុសគ្នាខ្លាំងពេក។

ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស** ម.ស.ម.ក អាចស្វែងរកព័ត៌មានបានថា មានតែគ្រួសាររងផលប៉ះពាល់ចំនួនបីគ្រួសារក្នុងចំណោម ៩៧គ្រួសារ ប៉ុណ្ណោះបានទទួលសំណងជាប្រាក់៖ ពីរគ្រួសារនៅឆ្នាំ២០១៦ និងមួយគ្រួសារនៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០១៨ ដែលទទួលបានសំណងជាប្រាក់ចំនួន ៦០.០០០ ដុល្លារសហរដ្ឋអាមេរិក។ មួយគ្រួសារ មិនបានទទួលសំណងទេ ដោយសារគ្រួសារនោះបានផ្លាស់ទីលំនៅទៅខេត្តបាត់ដំបង ក្នុងកំឡុងពេលចរចារ ប៉ុន្តែគ្រួសារនេះបានបញ្ឈប់ការតស៊ូមតិស្វែងរកដំណោះស្រាយវិវាទដីធ្លី ដែលខ្លួនមានជាប់ពាក់ព័ន្ធដោយមិនដឹងពីមូលហេតុច្បាស់លាស់។ ដោយយោងតាមអ្នកដែល ម.ស.ម.ក បានសម្ភាសន៍នៅខែឧសភា ឆ្នាំ២០១៨ គ្រួសារដែលទទួលយក និងបានទទួលសំណងជាប្រាក់មិនពេញចិត្តទៅនឹងទឹកប្រាក់ដែលបានផ្តល់ជូននោះទេ។

*ការដោះដូរដី*

សម្បទានដីសង្គមកិច្ច ត្រូវបានបង្ហាញជាទម្រង់ដំណោះស្រាយសម្រាប់ពីរ ក្នុងចំណោមបីករណីនោះ គឺជាករណីក្រុមហ៊ុន មីតផ៉រ ភូល និងក្រុមហ៊ុន អឹមឌីអេស។ ចាប់តាំងពីការចាប់ផ្តើមអនុវត្តគម្រោងនោះមកគឺមានបញ្ហាមួយដោយសារថា សម្បទានដីសង្គមកិច្ចគឺមានគោលបំណងផ្តល់ការកាន់កាប់ដីទៅឱ្យអ្នកដែលគ្មានដីសោះ។ ដូច្នេះ ការទទួលសម្បទានដីសង្គមកិច្ចក្នុងករណីនេះ មិនអាចអះអាងថាបុគ្គលទទួលបានដីនោះគឺដោយសារតែមានវិវាទឡើយ។ លើសពីនេះទៅទៀតសម្បទានដីសង្គមកិច្ចមានការកម្រិតទំហំ៖ សម្បទានដី

សង្គមកិច្ចដែលផ្តល់ដីសម្រាប់ការតាំងទីលំនៅគឺទំហំត្រឹម ១.២០០ម៉ែត្រក្រឡា និងមិនអាចលើសពី ៣.៦០០ ម៉ែត្រក្រឡាឡើយ[167] ចំណែក សម្បទានដីសង្គមកិច្ចដែលផ្តល់ឱ្យសម្រាប់ «ការដាំដុះជាលក្ខណៈគ្រួសារ» ជាទូទៅមានទំហំ ២ហិកតា ទោះបីជាវាអាចកើនដល់ ៥ហិកតាក្តី។[168]

ក្នុង**ករណីក្រុមហ៊ុន អឹមឌីអេស** នៅឆ្នាំ២០១៦ ប្រជាពលរដ្ឋចំនួនបីគ្រួសារយលព្រមទទួលយកសម្បទានដីសង្គមកិច្ច នៅតែមិនទាន់បានទទួលដីមកដល់ពេលសរសេររបាយការណ៍នេះ។[169] បច្ចុប្បន្នសម្បទានដីសង្គមនេះ គឺជាដំណោះស្រាយតែមួយគត់ដែលអាជ្ញាធរបានស្នើឡើង ប៉ុន្តែ ក្តីកង្វល់ជាច្រើននៅតែមានផងដែរ។ កាលដំបូងឡើយ សមាជិកសហគមន៍ខ្លះបានអះអាងអំពីការបង្ខំឱ្យទទួលយកសម្បទានដីសង្គមនៅខែឧសភា ឆ្នាំ២០១៧។ បន្ថែមពីនេះ នៅខែឧសភា ឆ្នាំ២០១៨ តំណាងគ្រួសាររងផលប៉ះពាល់ត្រូវបានគេប្រាប់ថា ប្រសិនបើពួកគាត់មិនទទួលយកសម្បទានដីសង្គមកិច្ចទេ នឹងមិនមានការស្នើសុំដំណោះស្រាយផ្សេងទៀតឡើយ។ ទីពីរ សម្បទានដីសង្គមដែលបានស្នើសុំមានទីតាំងនៅតំបន់ដែលនៅជុំវិញតំបន់សេដ្ឋកិច្ចពិសេសនិងនៅលើផ្ទៃដីដែលមានគ្រាប់មីន។[170] នៅពេល ម.ស.ម.ក បានជួបជាមួយអាជ្ញាធរសាធារណៈនៅខែឧសភា ឆ្នាំ ២០១៨ ពួកគាត់ទទួលបានស្គាល់អំពីបញ្ហានេះ និងបានប្រាប់ថា ដីដែលបានស្នើសុំនោះមិនទាន់បានដោះគ្រាប់មីនចេញនៅឡើយទេ។ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ក្រោយពីទទួលបានលិខិតពីរដ្ឋសភាជាតិ[171] ដែលបានចេញជូនគាត់ បន្ទាប់ពីគ្រួសាររងផលប៉ះពាល់បានដាក់ញ្ញត្តិទៅរដ្ឋសភានោះ[172] ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត បានសន្យាថានឹងដោះស្រាយ ព្រមទាំងបញ្ចប់វិវាទដីធ្លីទាំងនោះនៅត្រឹមថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨។ មិនយូរប៉ុន្មានក្រោយមក តំណាងសហគមន៍សំខាន់ម្នាក់ត្រូវបានស្នើសុំជួបដោយមនុស្សបីនាក់ផ្សេងគ្នាដូចជាមេឃុំ មេបញ្ជាការយោធាដែលធ្វើការនៅតាមព្រំដែន និងតំណាងក្រុមហ៊ុន អឹមឌីអេស ម្នាក់បានសុំជួបនាងដើម្បីពិភាក្សាអំពីដំណោះស្រាយដែលអាចទៅរួច។ អ្នកទាំងនោះបានបញ្ជាក់ថា ដំណោះស្រាយត្រូវតែធ្វើឡើងជាលក្ខណៈបុគ្គលដោយឡែកៗពីគ្នា ហើយថានាងគួរជួបជាមួយពួកគេតែម្នាក់ឯង។ ដំណោះស្រាយនេះផ្ទុយពីធន្ទៈសហគមន៍ដែលត្រូវធ្វើឡើងជាសាធារណៈប្រកបដោយតម្លាភាព

---

[167]"អនុក្រឹត្យលេខ១៩ស្តីពីសម្បទានដីសង្គមកិច្ច ថ្ងៃទី១៩ខែមីនា ឆ្នាំ២០០៣ ប្រការ១៦, http://www.cambodiainvestment.gov.kh/sub-decree-19-on-social-land-concessions_030319.html ("អនុក្រឹត្យលេខ១៩")។

[168]"អនុក្រឹត្យលេខ១៩ ប្រការ១៧។

[169]"ដូចបង្ហាញខាងក្រោម គ្រួសារទាំងនោះមិនទទួលបានទាល់តែសោះនូវ សម្បទានដីសង្គមកិច្ច ដោយសារដីនោះមានគ្រាប់មីន។

[170]"ជាការពិត តំបន់នៃប្រទេសកម្ពុជាតាមបណ្តោយព្រំដែនភាគពាយព្យត្រូវបានគេចាត់ទុកជាតំបន់ចំការមីនច្រើនបំផុតនៅក្នុងពិភពលោក ហើយដី សម្បទានដីសង្គមកិច្ច ដែលបានស្នើសុំនោះមានទីតាំងនៅតំបន់ដែលមានគ្រាប់មីនចាប់តាំងពីសង្គ្រាមស៊ីវិលឆ្នាំ1979-1998។ *សូមមើល* "យុទ្ធសាស្ត្ររបស់អង្គការសកម្មភាពកម្ចាត់មីនជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ2018-2025" ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ សេចក្តីផ្តើម ទំព័រ ១, http://www.cmaa.gov.kh/images/contents/NMAS/NMAS_in%20English.pdf.

[171]"លិខិតដំបូងត្រូវបានផ្ញើចេញនៅថ្ងៃទី០៨ខែវិច្ឆិកា ឆ្នាំ២០១៦ លិខិតទីពីរនៅថ្ងៃទី១១ខែមេសា ឆ្នាំ២០១៧។លិខិតទាំងពីរត្រូវបានផ្ញើជូនក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

[172]" 17 គ្រួសារមានការព្រួយបារម្ភ នៅពេលដែលពួកគាត់បានដាក់ញត្តិ ប៉ុន្តែ ដូចបានលើកឡើងខាងលើ ពីរគ្រួសាររកបានដំណោះស្រាយ ដូច្នេះហើយ ១៥ គ្រួសារនៅសល់កំពុងបន្តស្វែងរកដំណោះស្រាយ។

និងសម្រាប់គ្រួសារទាំងអស់នៅពេលតែមួយ ហើយដោយសារតែការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនផងនោះ តំណាងសហគមន៍មិនបានជួបជាមួយអ្នកទាំងបីនោះទេ។

បច្ចុប្បន្នប្រជាពលរដ្ឋ ១៥គ្រួសារ នៅតែកំពុងរង់ចាំដំណោះស្រាយនៃការវិវាទដីធ្លីនេះ។ ពាក់ព័ន្ធនឹងព័ត៌មានដែលអាជ្ញាធរបានផ្តល់ជូនកាលពី ខែឧសភា ឆ្នាំ២០១៨ អំពីច្រក «នាំចេញនាំចូល» ដែលនឹងមានរវាងប្រទេសកម្ពុជា និងថៃ ដែលទំនិញនឹងដឹកជញ្ជូនឆ្លងកាត់តំបន់សេដ្ឋកិច្ចពិសេសរបស់ក្រុមហ៊ុន អឹមឌីអេស នោះអាចជាសម្ពាធបន្ថែមសម្រាប់គ្រួសារទាំងនោះឱ្យទទួលយកដំណោះស្រាយ និងចាកចេញពីដីរបស់ខ្លួននៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះ ប៉ុន្តែក៏បានបញ្ជាក់ដែរថាសម្បទានដីសង្គមកិច្ច ក៏នឹងត្រូវដាក់បញ្ចូលនូវហេដ្ឋារចនាសម្ពន្ធមូលដ្ឋាន ដូចជាផ្លូវ ទឹក អគ្គិសនី សាលារៀន ទីផ្សារ មណ្ឌលសុខភាព និងសម្ភារៈបរិក្ខាក្នុងការ អភិវឌ្ឍដីសេវានានា ព័ត៌មានអំពីរបៀបនិងពេលវេលាក្នុងការរៀបចំហេដ្ឋារចនាសម្ពន្ធរូបវន្ត និងផ្តល់សេវាសាធារណៈទាំងនោះ[173] ប៉ុន្តែវាហាក់ដូចជាថា ទោះបីពួកគាត់ទទួលយកសម្បទានដីសង្គមកិច្ចនោះក៏ដោយ ក៏ពួកគាត់នឹងមិនអាចប្រើដីទាំងនោះបាន ដោយរង់ចាំយ៉ាងហោចណាស់ជាច្រើនខែទៀតដែរ។

នៅខែមិថុនា ឆ្នាំ២០១៨ **ករណីក្រុមហ៊ុន មីតផ័រ ភូល** អាជ្ញាធរបានប្រាប់ ម.ស.ម.ក និងសហគមន៍រងផលប៉ះពាល់ថា នឹងមានការផ្តល់សម្បទានដីសង្គមកិច្ចដល់ជនរងគ្រោះ ២ហិកតាក្នុងមួយគ្រួសារ។ សម្បទានដីសង្គមកិច្ចនឹងត្រូវផ្តល់ឱ្យប្រជាពលរដ្ឋចំនួន ៤១៤គ្រួសារ ដែលបានចុះបញ្ជីជាមួយមន្ត្រីក្រសួងដែនដីកាលពីខែ តុលា ឆ្នាំ២០១៧ ហើយដីនោះស្ថិតនៅលើអតីតដីរបស់ពួកគាត់នៅក្នុងបរិវេណសម្បទានដីសេដ្ឋកិច្ច។ មានការចាប់ឆ្នោតផ្សងសំណាងជ្រើសយកក្បាលដីបានធ្វើឡើងនៅ ខែមិថុនា ឆ្នាំ២០១៨ ហើយគ្រួសារទាំងអស់ ក៏បានយល់ព្រមទទួលយកសម្បទានដីសង្គមកិច្ចដែលអាជ្ញាធរបានរៀបចំឱ្យពួកគាត់។ ប្រជាពលរដ្ឋចំនួន ៣២៩ គ្រួសារ ដែលមកពីភូមិរងផលប៉ះពាល់ចំនួនប្រាំនោះបានទទួលដីឡូត៍ហើយ។[174] ម.ស.ម.ក បានទទួលដំណឹងថា ផ្នែកផ្សេងទៀតនៃដីនៅក្នុងបរិវេណសម្បទានដីសេដ្ឋកិច្ចនឹងត្រូវផ្តល់ឱ្យអតីតយុទ្ធជនចូលនិវត្តន៍ផងដែរ។

ជាការគួរសោកស្តាយ ដែលមានបញ្ហាមួយចំនួនទាក់ទងនឹងដំណើរការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះ។ កាលពីដំបូង គ្រួសាររងផលប៉ះពាល់ក្នុងវិវាទដីធ្លីនេះមិនបានទទួលព័ត៌មានគ្រប់គ្នានោះទេ និងភាគច្រើនមិនបានចុះបញ្ជីជាមួយមន្ត្រីក្រសួងដែនដីឡើយ ដោយសារពួកគាត់មិនទទួលបានដំណឹង និង/ឬបានធ្វើចំណាកស្រុកទៅធ្វើការក្នុងប្រទេសថៃ ហើយមិនអាចធ្វើដំណើរមកវិញបាន។ ទីពីរ គ្រួសារជាច្រើនបានប្រាប់ ម.ស.ម. ក ថា ពួកគាត់បានព្រមទទួលយកដំណោះស្រាយនោះដោយបារម្ភថា នឹងមិនមានដំណោះស្រាយផ្សេងទៀតក្រៅពីនេះឡើយ។ ទីបី គ្រួសារខ្លះគិតថាពួកគាត់ត្រូវទទួលរងអំពើអយុត្តិធម៌ ហើយគ្រួសារខ្លះទៀតបាននិយាយថាពួកគាត់បានទទួលដីមិនគ្រប់ ២ហិកតាឡើយ និងគ្រួសារខ្លះទៀតបានលើកឡើងថា ពួកគាត់ទទួលបានដីនៅទី

[173]"អនុក្រឹត្យលេខ១៩ ប្រការ១៩ (ច) ការរៀបរាប់លក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំផែនការ សម្បទានដីសង្គមកិច្ច។

[174]"តួលេខនេះដែលទទួលបានដោយផ្ទាល់ពីតំណាងសហគមន៍តាមរយៈការស្រាវជ្រាវរបស់ ម.ស.ម.ក ដែលត្រូវបានផ្ទៀងផ្ទាត់ផងដែរពីអង្គការសមធម៌កម្ពុជា រកឃើញខុសគ្នាពីតួលេខដែល MLMUPC បានផ្តល់ឱ្យមាន៣៨៥ គ្រួសារ។ អ្នកភូមិមានមកពីភូមិតាមាន់ ខ្ទុម ថ្នល់បត់ ត្រពាំងវែង និងបុស។

ឆ្ងាយដាច់ស្រយ៉ាលដែលលំបាកនឹងចូលទៅដល់ ត្រូវចំណាយពេលច្រើន និងកម្លាំងដើម្បីកាប់គាស់សម្អាតដីត្រៀមធ្វើដំណាំទៀតផង។ អ្នកភូមិជាច្រើនក៏បានត្អូញត្អែរថា ដីមានទំហំតូចជាងដីដែលពួកគាត់មានពីមុនមក។ ទីបួន ទោះបីជាអាជ្ញាធរបានហៅដីនោះជាសម្បទានដីសង្គមកិច្ចក៏ដោយ ក៏មិនទាន់មានឯកសារផ្លូវការណាមួយបានបញ្ជាក់ថាដីនោះគឺជាសម្បទានដីសង្គមកិច្ចឡើយ។ មានតែឯកសារដែលបានផ្តល់ឱ្យសមាជិកសហគមន៍ប៉ុណ្ណោះដែលគ្រាន់តែជាឯកសារបញ្ជាក់ពីឈ្មោះ ទំហំដី និងទីតាំងដីរបស់គាត់។ នេះគឺជាក្តីបារម្ភខ្លាំងដោយសារតែដីដែលទទួលបាននោះ គឺជាសម្បទានដីសង្គមកិច្ច ពោលគឺត្រូវរស់នៅលើដីនោះរយៈពេល៥ឆ្នាំឡើងសិនមុនពេលដែលអ្នកទទួលអត្ថប្រយោជន៍អាចស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីបាន និងដែលមិនអាចលក់បានក្នុកំឡុងពេលនោះខុសគ្នាឆ្ងាយពីការដោះដូរដីជាទៀងទាត់ ដែលអាចស្នើសុំប័ណ្ណកម្មសិទ្ធិដីភ្លាមៗ បាននិងដែលអាចលក់ដូរបាន។

ក្នុងពេលជាមួយគ្នានេះផងដែរ ប្រជាពលរដ្ឋ ៣៨៣គ្រួសារ មិនទាន់បានចុះបញ្ជីជាមួយមន្ត្រីក្រសួងដែនដីនោះទេ ដូច្នេះពួកគាត់នៅតែរង់ចាំដំណោះស្រាយវិវាទដីធ្លីនេះ។ ក្នុងចំណោមគ្រួសារទាំងនោះ អាជ្ញាធរបានប្រាប់ប្រជាពលរដ្ឋប្រមាណ ៩២គ្រួសារ ថា អាជ្ញាធរកំពុងរកដំណោះស្រាយជូន ប៉ុន្តែនៅតែស្ថិតកំពុងរង់ចាំដំណោះស្រាយនៅឡើយ។ នៅខែតុលា ឆ្នាំ២០១៨ តំណាងសហគមន៍បានប្រាប់ ម.ស.ម.ក ថា អាជ្ញាធរបានលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ ចំនួន ២៩១គ្រួសារ ដែលនៅសេសសល់ទៅចុះបញ្ជីជាមួយអាជ្ញាធរមូលដ្ឋានជាជាងការស្វែងរកដំណោះស្រាយវិវាទដីធ្លីតាមរយៈតំណាងសហគមន៍។ តួលេខខាងលើនេះ គឺទទួលបានដោយផ្ទាល់ពីតំណាងសហគមន៍ និងត្រូវបានផ្ទៀងផ្ទាត់យ៉ាងម៉ត់ចត់[175] ខុសគ្នាពីតួលេខដែលអាជ្ញាធររដ្ឋបានលើកឡើងនៅពេលសម្ភាសន៍ និងនៅក្នុងឯកសារសាធារណៈ។[176]

វិវាទដីធ្លីទាំងបីករណីខាងលើ បានបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋជាង ១.៦០០នាក់ ហើយជនរងគ្រោះ និងគ្រួសារពួកគាត់មានផលវិបាកខាងផ្លូវកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរជាយូរមកហើយ។ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋប្រមាណជាង ១.០៣៨ គ្រួសារ នៅតែកំពុងស្វែងរកដំណោះស្រាយរួមគ្នា ចំណែកគ្រួសារដែលបានចូលរួមក្នុងដំណោះស្រាយវិវាទដីធ្លីនេះ បានសម្តែងពីអារម្មណ៍គាត់ថា ពួកគាត់មិនមានជម្រើសអ្វីក្រៅពីទទួលយកដំណោះស្រាយនោះទេ។ អ្វីដែលបានបង្ហាញក្នុងករណីទាំងបីនេះគឺថា ទោះបីមានដំណើរការដោះស្រាយវិវាទដីធ្លី និងបានស្នើសុំដំណោះស្រាយជាច្រើនជម្រើសសម្រាប់ជនរងគ្រោះក្តី ក៏ជនរងគ្រោះភាគច្រើននៅតែមិនទាន់បានស្វែងរកដំណោះស្រាយមានប្រសិទ្ធភាពនៅឡើយ ពោលគឺមានរយៈពេលជាច្រើនទសវត្សរ៍មកហើយចាប់តាំងពីវិវាទដីធ្លីនេះកើតឡើងមកម្ល៉េះ។

---

[175] "សិទ្ធិដីធ្លី អង្គការសមធម៌កម្ពុជាដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយបាននឹងកំពុងធ្វើការងាររួមគ្នាជាមួយសហគមន៍រងផលប៉ះពាល់ដើម្បីបង្កើតបញ្ជីគ្រប់ជ្រុងជ្រោយមួយពីគ្រួសាររងផលប៉ះពាល់ដែលអង្គការម.ស.ម.កអាចទទួលបាន និងជាឯកសារសំខាន់បំផុតដែលមាន។

[176] "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពិស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា៖ មតិយោបល់របស់រដ្ឋ", UN Doc A/HRC/39/73/Add.2 ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ ទំព័រ២១, https://undocs.org/A/HRC/39/73/ADD.2.

## របកគំហើញទី ៧ ៖ គួរសម្របសម្រួលឱ្យមានយន្តការដោះស្រាយវិវាទដីធ្លីផ្សេងៗ និងប្រកបដោយភាពច្នៃប្រឌិត

ក្នុងករណីចំនួនពីរដែលមានពាក់ព័ន្ធជាមួយក្រុមហ៊ុនបរទេសនិងដែលជាករណីដែលវិវាទដីធ្លីបានអូសបន្លាយយូរបំផុត (ជាង១០ឆ្នាំ) ជនរងគ្រោះបានប្រើប្រាស់ដំណើរការផ្សេងៗដើម្បីស្វែងរកដំណោះស្រាយវិវាទដីធ្លីនេះ។ ទោះបីដំណើរការដោះស្រាយទាំងនោះមិនអាចប្រើប្រាស់បានទាំងអស់នៅក្នុងដំណើរការដោះស្រាយដែលមាននៅក្នុងប្រទេសកម្ពុជាទាំងមូលក្តី ក៏ដំណើរការទាំងនោះអាចបង្កើតបានជាមធ្យោបាយបន្ថែមដែលជនរងគ្រោះអាចទទួលបានដំណោះស្រាយក្នុងការវិវាទដីធ្លីនេះផងដែរ។

### ៧.១. ដំណោះស្រាយនៅតាន់តុលាការបរទេស

ក្នុងករណីចំនួនពីរ ដែលពាក់ព័ន្ធជាមួយក្រុមហ៊ុនបរទេស សហគមន៍បានព្យាយាមស្វែងរកដំណោះស្រាយតាមរយៈការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីទីកាន់តុលាការដែលក្រុមហ៊ុននោះបានចុះបញ្ជី ៖ នៅប្រទេសថៃ គឺទាក់ទងនឹងក្រុមហ៊ុន មិតផល ភូល និងប្រទេសបារាំង គឺទាក់ទងនឹងក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី។

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ តំណាងសហគមន៍តំណាងឱ្យប្រជាពលរដ្ឋជាង ៧០០គ្រួសារស្មើចំនួន (៣.០០០ នាក់) ដែលមានពាក់ព័ន្ធក្នុងវិវាទជាមួយ**ក្រុមហ៊ុន មីតផល ភូល** បានទៅកាន់ប្រទេសថៃដើម្បីដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីប្តឹងក្រុមហ៊ុន មីតផល ភូល[177]ដោយបង្ហាញពីការរំលោភសិទ្ធិមនុស្សមួយចំនួនក្រោយពី ក្រុមហ៊ុន មីតផល ភូល បានរៀបចំដាំអំពៅរបស់ខ្លួន រួមមានការបណ្តេញចេញដោយបង្ខំ ការផ្លាស់ទីកន្លែងដោយបង្ខំ ការដុតផ្ទះ ការបាត់បង់ផលដំណាំ និងសត្វពាហនៈ និងការរឹបអូសយកដីចម្ការកាន់កាប់ស្របច្បាប់របស់ ពួកគាត់ ហើយអ្នកដែលរឹងទទឹងត្រូវរងការគំរាម កំហែងចាប់ខ្លួន និងចាប់ដាក់ពន្ធនាគារ។[178] បណ្តឹងនេះគឺជាបណ្តឹងដំបូងដែលប្តឹង ដោយជងរងគ្រោះជាបរទេសពាក់ព័ន្ធនឹងការចោទប្រកាន់បទឧក្រិដ្ឋ ដែលកើតមាននៅក្រៅប្រទេសថៃ។[179] បណ្តឹងនេះត្រូវបានទទួលយក ហើយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ចៅក្រមថៃបានរៀបការសម្រុះសម្រួលដោះស្រាយ។[180] យោងតាមព័ត៌មានដែលបានផ្តល់ឱ្យ ម.ស.ម.ក ក្រុមហ៊ុន មីតផល ភូល

---

177 "ប្រជាពលរដ្ឋកម្ពុជាដែលត្រូវផ្លាស់ទីកន្លែងដោយបង្ខំបានដាក់ពាក្យបណ្តឹងជាប្រវត្តិសាស្ត្រប្តឹងក្រុមហ៊ុនផលិតស្ករសធំបំផុតនៅអាស៊ី" *IDI* ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨, https://www.inclusivedevelopment.net/forcibly-displaced-cambodians-file-historic-lawsuit-against-asias-largest-sugar-producer/; "តុលាការថៃទទួលយកករណីបណ្តឹងយកដីប្រជាពលរដ្ឋកម្ពុជា បញ្ជាឱ្យដោះស្រាយសម្របសម្រួល" *IDI* ថ្ងៃទី០៥ខែកញ្ញា ឆ្នាំ២០១៨, https://www.inclusivedevelopment.net/thai-court-accepts-cambodian-land-grabbing-case-orders-mediation/.

178 "ប្រជាពលរដ្ឋកម្ពុជាដែលត្រូវផ្លាស់ទីកន្លែងដោយបង្ខំបានដាក់ពាក្យបណ្តឹងជាប្រវត្តិសាស្ត្រប្តឹងក្រុមហ៊ុនផលិតស្ករសធំបំផុតនៅអាស៊ី" *IDI* ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨, https://www.inclusivedevelopment.net/forcibly-displaced-cambodians-file-historic-lawsuit-against-asias-largest-sugar-producer/;

179 "តុលាការថៃទទួលយកករណីបណ្តឹងយកដីប្រជាពលរដ្ឋកម្ពុស បញ្ជាឱ្យដោះស្រាយសម្របសម្រួល" *IDI* ថ្ងៃទី០៥ខែកញ្ញា ឆ្នាំ២០១៨, https://www.inclusivedevelopment.net/thai-court-accepts-cambodian-land-grabbing-case-orders-mediation/.

180 " *Ibid.*

បានច្រានចោលដំណើរការចរចានេះ។ ដូច្នេះបច្ចុប្បន្នតុលាការកំពុងដំណើរការវាយតម្លៃ ថាតើបណ្តឹង នេះស្ថិតនៅក្រោមប្រព័ន្ធយុត្តាធិការច្បាប់របស់ប្រទេសថៃដែរ ឬយ៉ាងណា។

**ក្នុងករណីក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី** នៅខែកក្កដា ឆ្នាំ២០១៥ តំណាងឱ្យដើមបណ្តឹង ៥១នាក់ មកពីភូមិប៊ូស្រា បានចាប់ផ្តើមដាក់ពាក្យបណ្តឹងទទួលខុសត្រូវរដ្ឋប្បវេណីទៅប្រទេសបារាំង ប្តឹងភាគីពាក់ព័ន្ធ សំខាន់ចំនួនពីររបស់ក្រុមហ៊ុន សុកហ្វិន ខេស៊ីឌី គឺក្រុមហ៊ុន Bollorégroup និងក្រុមហ៊ុន *"Compagnie du Cambodge"* («ក្រុមហ៊ុនមកពីប្រទេសកម្ពុជា») ដែលគ្រប់គ្រងដោយអ្នកជំនួញជនជាតិបារាំង Vincent Bolloré ។[181] ដើមបណ្តឹងបានចោទប្រកាន់ពីការរំលោភបំពានសិទ្ធិមនុស្ស និងការខូចខាតដល់បរិស្ថាន[182] និងបានស្នើឱ្យមានការធ្វើឱ្យដីពួកគាត់ត្រឡប់ដូចដើមវិញ និងទារសំណងចំពោះការខូចខាតទ្រព្យសម្បត្តិ និង ជម្ងឺចិត្តចំនួន ៦៥.០០០ អឺរ៉ូ។[183] នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រោយពីមានការស្នើសុំពីក្រុមហ៊ុនទាំងពីរមកតុលាការតម្រូវឱ្យដើមបណ្តឹងដាក់ឯកសារមួយចំនួនដើម្បីកំណត់ថា ពួកគាត់មានការទាមទារផ្លូវច្បាប់ទៅលើដីដែលពួកគាត់បានចោទក្រុមហ៊ុន ពីបទបានយកដីរួមដោយមានឯកសារផ្លូវការដែលបង្កើតបានជា «អត្តិភាពលក្ខណៈ ទីតាំង ទំហំជាក់ស្តែង និងឯកសារយោង» នៃដីនោះដែលត្រូវស្នើសុំឱ្យប្រគល់ត្រឡប់មកវិញ និងឯកសារផ្លូវការបញ្ជាក់ការបង្កើតបានជាសិទ្ធិលើទ្រព្យរបស់បុគ្គលម្នាក់ៗលើដីមានវិវាទ។[184] សេចក្តីសម្រេចបន្ទាប់ទៀតគឺការរៀបចំសន្និសីទស្តីពីស្ថានភាពនេះនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៧។[185] ម.ស.ម.ក មិនអាចស្វែងរកព័ត៌មានបន្ថែមអំពីករណីនេះបាននៅឡើយទេ ប៉ុន្តែនៅពេលដែលជួបជាមួយសហគមន៍ យើងបានទទួលដំណឹងថាសវនាការនឹងរៀបចំនៅចុងឆ្នាំ២០១៨ ដែលជនរងគ្រោះ នឹងធ្វើដំណើរទៅកាន់ប្រទេសបារាំងដើម្បីស្តាប់សវនាការ។ ម.ស.ម.ក ក៏ទទួលបានដំណឹងថាតំណាងសហគមន៍ខ្លះ បានដកពាក្យបណ្តឹងដើម្បីចូលរួម

---

[181] "*Tribunal de Grande Instance de Nanterre, 6e Chambre*, ថ្ងៃទី១០ខែកុម្ភៈ ឆ្នាំ២០១៧, លេខ 15/10981, (មានតែជាភាសាបារាំងប៉ុណ្ណោះ), https://www.doctrine.fr/d/TGI/Nanterre/2017/FREEBB840C2C3837B691D0?q=socfin-KCD&only_top_results=true&original_query_key=1b5bc479c33900e1aac7ef720a03ed5c&selected_keywords=%5B%5D&position=1&action=result&query_key=1b5bc479c33900e1aac7ef720a03ed5c&event_key=2018-09-04-4958878&source=excerpt_results( "ការសម្រេចរបស់តុលាការ Nanterre ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧") មានការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនៅវែបសាយត៍http://business.sithi.org/show_report_detail_land.php?id=75&lang=en;"នៅក្នុងប្រទេសកម្ពុជា ជនជាតិភ្នងប្រយុទ្ធតស៊ូយកដីប្រឆាំងនឹងក្រុមហ៊ុន Vincent Bolloré", *Mediapart*, ថ្ងៃទី០៤ខែវិច្ឆិកា ឆ្នាំ២០១៥, https://www.mediapart.fr/journal/international/041115/au-cambodge-les-bunongs-luttent-pour-leurs-terres-contre-vincent-bollore?onglet=full(មានតែជាភាសាបារាំងប៉ុណ្ណោះ); "កសិករខ្មែរប្តឹងក្រុមហ៊ុន Bolloré Group ក្នុងប្រទេសបារាំង", *Le Monde* ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥, https://www.lemonde.fr/planete/article/2015/07/29/spoliee-de-sa-terre-une-population-autochtone-du-cambodge-assigne-le-groupe-bollore-en-justice_4703542_3244.html (មានតែជាភាសាបារាំងប៉ុណ្ណោះ)។

[182] "ក្រុមហ៊ុន Bolloré ត្រូវបានវាយប្រហារក្នុងប្រទេសបារាំងចំពោះការដាំដុះរបស់ខ្លួននៅប្រទេសកម្ពុជា" *Mediapart* ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥, https://www.mediapart.fr/journal/economie/280715/bollore-attaque-en-france-pour-ses-plantations-au-cambodge?onglet=full(មានតែជាភាសាបារាំងប៉ុណ្ណោះ)។

[183] "ការសម្រេចរបស់តុលាការ Nanterre ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ទំព័រ៥។

[184] "សេចក្តីសម្រេចរបស់តុលាការ Nanterre ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ទំព័រ៦, ៧។

[185] "សេចក្តីសម្រេចរបស់តុលាការ Nanterre ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ទំព័រ៧, (`*Motifs* - ហេតុផល)។

ក្នុងដំណើរការសម្រុះសម្រួល។ ក្រុមហ៊ុន Bolloré group បានប្រានចោលអំពីការគ្រប់គ្រងណាមួយរបស់ខ្លួនទៅលើសកម្មភាពរបស់ក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី និងអះអាងថាក្រុមហ៊ុននេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកប្រតិបត្តិ ("CEO") Hubert Fabri របស់ក្រុមហ៊ុន សុកហ្វីន គ្រុប។[186] ដោយសារតែមានការលំបាកក្នុងការតម្រូវឱ្យក្រុមហ៊ុនទទួលខុសត្រូវ ចំពោះសកម្មភាពរបស់ក្រុមហ៊ុនបុត្រសម្ពន្ធតែឯង គឺជាអតុល្យភាពរវាងសហគមន៍ជនជាតិដើមភាគតិច ដែលមធ្យោបាយរបស់ពួកគេនៅមានកម្រិត និងក្រុមហ៊ុនពហុជាតិសាសន៍ដែលមានប្រាក់រាប់ពាន់លានអឺរ៉ូ ហើយការពិត បញ្ហាប្រឈមសម្រាប់ដើមបណ្តឹងក្នុងការផ្តល់ឯកសារចាំបាច់ផ្សេងៗនោះ គឺជាឱកាសតិចតួចក្នុងការទទួលជោគជ័យ។

## ៧.២. ការសម្រុះសម្រួលឯករាជ្យ

ក្នុង**ករណីក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី** ប្រជាពលរដ្ឋចំនួន ៥៨៩គ្រួសារ មកពីភូមិចំនួន ៥[187] កំពុងចូលរួម ក្នុងដំណើរការសម្រុះសម្រួលឯករាជ្យដែលកំពុងដំណើរការចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៦ មកដោយអង្គការសម្រុះសម្រួលឯករាជ្យ («អាយ.អឹម.ជី») និងមានការគាំទ្រពីការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា។[188] ការដោះស្រាយនេះគ្របដណ្តប់លើសម្បទានដីសេដ្ឋកិច្ចរបស់វ៉ារ៉ាណាស៊ី សង្ហីកូឡា និងខូវីផាម៉ា។ អ្វីដែល ម.ស.ម.ក បានដឹងនោះគឺថាការប្រើដំណើរការសម្រុះសម្រួលឯករាជ្យនិងរៀបចំជារចនាសម្ពន្ធនេះគឺជាដំណើរការដែលមិនធ្លាប់មានពីមុនមកនៅក្នុងប្រទេសកម្ពុជា។ ដំណើរការនេះត្រូវបានគេសំដៅដល់ការសម្រុះសម្រួលហើយក្នុងដំណើរការនោះ អាចមានជាការសម្រុះសម្រួលជាច្រើនដំណាក់ផងដែរក្នុងពេលតែមួយ សម្រាប់ក្រុមនានាជាច្រើន ដែលគ្របដណ្តប់លើប្រធានបទខុសៗគ្នា ហើយប្រធានបទទាំងនោះអាចហួសពីវិសាលភាពវិវាទដីធ្លី ដូចជាការពិនិត្យមើលលើស្ថានភាព «ចម្ការគ្រួសារ» និងសំណួរពាក់ព័ន្ធអំពីព្រៃស័ក្តិសិទ្ធិក្នុងបរិវេណសម្បទានដីសេដ្ឋកិច្ចនោះជាដើម។ ជាការកត់សម្គាល់ អ្នកទាំងអស់ដែលបានចូលរួមក្នុងដំណើរការសម្រុះសម្រួលនេះ ត្រូវបានតម្រូវឱ្យចុះហត្ថលេខា លើកិច្ចសន្យារក្សាការសម្ងាត់ ដែលនេះជាហេតុផលដែលមានព័ត៌មានតិចតួចបំផុតអំពីដំណើរការនេះ ។

ការសម្រុះសម្រួលមានអ្នកចូលរួមរួមជាតំណាងអ្នកភូមិ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា[189] អតីតសមាជិកក្រុមត្រីភាគី ដែលធ្លាប់ចរចាជាមួយក្រុមហ៊ុន

---

[186] "ក្រុមហ៊ុន Bolloré ត្រូវបានវាយប្រហារក្នុងប្រទេសបារាំងចំពោះការដាំដុះរបស់ខ្លួននៅប្រទេសកម្ពុជា" *Mediapart* ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ https://www.mediapart.fr/journal/economie/280715/bollore-attaque-en-france-pour-ses-plantations-au-cambodge?onglet=full (មានតែជាភាសាបារាំងប៉ុណ្ណោះ)។

[187] "ពូចា ពូរាំង ពូលុ ពូទីត និងប៊ូស្រា។ ប្រភព៖ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា។

[188] "*សូមមើលគេហទំព័រ*៖http://img-cambodia.org/en/imgprojects/claim.

[189] "របាយការណ៍របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច "ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨
កថាខណ្ឌ ២៩, https://undocs.org/A/HRC/39/37.

សុកហ៊ីន ខេស៊ីឌី កន្លងមកតំណាងឱ្យសហគមន៍ តំណាងក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី និងតំណាងមកពីថ្នាក់ឃុំ និងស្រុក។ អង្គការជំនួយផ្លូវច្បាប់កម្ពុជា («អឹល.អេ.ស៊ី») ដែលជាអង្គការមិនមែនរដ្ឋាភិបាលបានផ្តល់សេវាផ្លូវច្បាប់នៅទូទាំងប្រទេសកម្ពុជា បានបណ្តុះបណ្តាលសហគមន៍អំពីជំនាញចរចា និងគាំទ្រដល់ពួកគាត់មុនពេលអំឡុងពេល និងក្រោយពេលដំណើរការសម្រុះសម្រួល។ ក្នុងខណៈនេះ ជំហានដំបូងនៃការសម្រុះសម្រួលគឺទាក់ទងជាមួយដីសហគមន៍ដែលបានបញ្ចប់នៅអំឡុងសប្តាហ៍ទីមួយនៃខែតុលា ឆ្នាំ ២០១៨។ កិច្ចសម្រុះសម្រួលត្រូវបានចុះហត្ថលេខានៅថ្ងៃទី០២ និងទី០៣ ខែតុលាឆ្នាំ២០១៨។ បញ្ហានៅសេសសល់ដែលនឹងត្រូវដោះស្រាយតាមរយៈការសម្រុះសម្រួលនៅពេលនេះមានដូចជា៖ ដីដែលមានព្រំប្រទល់ជាប់នឹងប្រឡាយចម្ការគ្រួសារ និងសំណងជាដីម។ ដំណើរការសម្រុះសម្រួលអាចនឹងបន្តប្រហែលរយៈពេលមួយឆ្នាំទៀត។

ការសម្រុះសម្រួលឯករាជ្យ និងការដាក់ពាក្យបណ្តឹងទៅកាន់តុលាការក្រៅប្រទេសគឺអាចបំពេញបន្ថែមលើយន្តការដោះស្រាយវិវាទ ដែលមានស្រាប់ហើយដែលត្រូវបានមើលឃើញថាអប្រសិទ្ធភាព និង/ឬការមិនពេញចិត្តរបស់ជនរងគ្រោះដោយសារវិវាទដីធ្លីនោះ។ ទោះបីយ៉ាងណា គួររំឭករដ្ឋត្រូវមានកាតព្វកិច្ចចម្បងក្នុងការធានាផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្ស។ ដូច្នេះអត្ថិភាពនៃដំណើរការនោះមិនត្រូវរាំងស្ទះរាជរដ្ឋាភិបាល ក្នុងការស្វែងរកដំណោះស្រាយ ប្រកបដោយយុត្តិធម៌ និងមិនលម្អៀងចំពោះវិវាទដីធ្លីដែលមានស្រាប់ឡើយ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

តាមទ្រឹស្តី ក្របខ័ណ្ឌច្បាប់កម្ពុជាអនុញ្ញាតឱ្យមានការការពាររឹងមាំទៅលើសិទ្ធិដីធ្លី។ ក្របខ័ណ្ឌច្បាប់បានផ្តល់សម្រាប់ការប្រឹក្សាយោបល់ប្រកបដោយអត្ថន័យ ទប់ស្កាត់ការបណ្តេញចេញដោយបង្ខំ និងធានាសិទ្ធិទទួលបានសេរីភាពបញ្ចេញមតិ។ ដូចគ្នានេះដែរ អាជ្ញាធរបានទទួលស្គាល់អំពីបញ្ហាវិវាទដីធ្លីក្នុងប្រទេសកម្ពុជា និងបានប្រកាសជាសាធារណៈអំពីជំហានមួយចំនួន ដែលត្រូវអនុវត្តដើម្បីដោះស្រាយបញ្ហាវិវាទដីធ្លីទាំងនោះ។

ប៉ុន្តែ ការស្រាវជ្រាវរបស់ ម.ស.ម.ក បានបង្ហាញលទ្ធផលផ្ទុយពីនេះ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមមិនត្រូវបានអនុវត្ត ឬមិនត្រូវបានគោរពនោះទេ រីឯសហគមន៍រងផលប៉ះពាល់មិនត្រូវបានគេជូនដំណឹងប្រឹក្សាយោបល់និងស្តាប់ដ៏ត្រឹមត្រូវឡើយ អង្គការការពារសិទ្ធិមនុស្សត្រូវបានគេតាមដានគំរាមកំហែង និងបៀតបៀន ហើយជនរងគ្រោះភាគច្រើនបានប្រាប់ពីការបង្ខំឱ្យចាកចេញពីដីរបស់ខ្លួន និងព្រមទទួលយកទម្រង់ «ដោះស្រាយ» ណាក៏ដោយដែលអាជ្ញាធរបានស្នើឡើង។ អស់រយៈពេលជាច្រើនឆ្នាំក្រោយពីចាប់ផ្តើមមានវិវាទដីធ្លី និងទោះបីជាមានដំណើរការដោះស្រាយវិវាទមួយចំនួនក្តីក្នុងករណីទាំងបី ក៏ជនរងគ្រោះពីការវិវាទដីធ្លីមិនបានទទួលដំណោះស្រាយសមស្រប ដែលគ្របដណ្តប់ទាំងការបាត់បង់ដី និងការរំលោភបំពានសិទ្ធិមនុស្សទៅលើពួកគេឡើយ។

បញ្ហាភាគច្រើនដែលមាននៅក្នុងកំណត់ត្រាសង្ខេបនេះ គួរត្រូវបានបញ្ចៀសប្រសិនបើបុរេលក្ខខណ្ឌដែលតម្រូវមុនការផ្តល់សម្បទានដីសេដ្ឋកិច្ច និងតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានគេអនុលោមតាមយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធភាព ព្រមទាំងមានការអនុវត្ត និងការតាមដានជាក់លាក់នោះ។ ប្រសិនបើអាចធ្វើដូចនោះបាន នោះជាលទ្ធផលភាគីពាក់ព័ន្ធទាំងអស់នឹងអាចសន្សំសំចៃពេលវេលា ប្រាក់កាស និងកិច្ចខិតខំប្រឹងប្រែងនានា ហើយថែមទាំងអាចបញ្ចៀសវិវាទដីធ្លី និងនាំឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

## អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

ទី១ **តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមច្បាស់លាស់មុនពេល** អនុញ្ញាតឱ្យមានគម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងអភិវឌ្ឍន៍ ឬតំបន់សេដ្ឋកិច្ចពិសេសណាមួយ ដោយតម្រូវថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវចែកដល់សហគមន៍រងផលប៉ះពាល់ និងសាធារណជនឱ្យទាន់ពេលវេលា និងទាមទារ **ឱ្យមានយន្តការតាមដានការអនុវត្ត**ដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិរួមមានគោលការណ៍១៨ នៃគោលការណ៍ណែនាំ និងគោលការណ៍ អាយ.អេហ្វ.ស៊ី ព្រមទាំង **គិតគូឡើងវិញអំពីកិច្ចសន្យារបស់ក្រុមហ៊ុន** ដែលប្រតិបត្តិការសម្បទានដីសេដ្ឋកិច្ច ឬតំបន់សេដ្ឋកិច្ចពិសេសតម្រូវឱ្យក្រុមហ៊ុនណា ដែលមិនបានអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីបង្កើតផែនការកាត់បន្ថយចំពោះហានិភ័យនានា ដែលបានរកឃើញ និងតាមដានការអនុវត្តទាំងនោះ ក៏ដូចជាទាមទារឱ្យពួកគេផ្តល់ដំណោះស្រាយមានប្រសិទ្ធភាពផងដែរ។

ទី២ ប្រាកដថាមាន**ការប្រឹក្សាយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍** ដែលរងផលប៉ះពាល់ពីវិវាទដីធ្លីមុនពេលផ្តល់កិច្ចសន្យាណាមួយ និងធានាថាពួកគាត់ នៅតែបន្តចូលរួមការវាយតម្លៃអំពីការអភិវឌ្ឍ ព្រមទាំងធានាឱ្យគោរពតាមគោលការណ៍នៃ**ការយល់ព្រមដោយពេញចិត្ត ដោយប្រាប់ឱ្យដឹងជាមុននឹងទទួលបានព័ត៌មានពេញលេញ**ផងដែរ។

ទី៣ **ធានាអំពីការដោះស្រាយវិវាទដីធ្លីទាន់ពេលវេលា** ការដោះស្រាយមិនដោតជ័យលើដីធ្លីដែលមានវិវាទគប្បីប្រគល់ដីនោះទៅឱ្យជនរងគ្រោះវិញ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិប្រការ ៣ (ក) នៃ ក.អ.ស.ព.ន និងគោលការណ៍២៦ នៃគោលការណ៍ណែនាំ។

ទី៤ ធានាថា **ដំណោះស្រាយត្រូវគោរពតាមបទដ្ឋានអន្តរជាតិ** រួមមានគោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋានអំពីការបណ្តេញចេញ និងការបំលាស់ទីលំនៅ ដោយផ្អែកលើការអភិវឌ្ឍ និងបំពេញតាមលក្ខខណ្ឌតម្រូវអំពីប្រសិទ្ធភាពនៃគោលការណ៍ ៣១ នៃគោលការណ៍ណែនាំ។

ទី៥ **បញ្ឈប់រាល់ទម្រង់ការតាមដានការបៀតបៀន និងការដាក់ទណ្ឌកម្មលើអ្នកការពារសិទ្ធិមនុស្ស** ដែលធ្វើការងារពាក់ព័ន្ធនឹងវិវាទដីធ្លី។

ទី៦ បង្កើត**យន្តការដោះស្រាយវិវាទ (យន្តការទទួលបណ្តឹង) ឯករាជ្យ ឥតលម្អៀង និងមានប្រសិទ្ធភាព** ដើម្បីទទួលនិងដោះស្រាយបណ្តឹងរបស់កម្មករក្នុងតំបន់សេដ្ឋកិច្ចពិសេស និងសហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់យ៉ាងខ្លាំងនៃការរំលោភបំពានសិទ្ធិមនុស្សដោយសារតំបន់សេដ្ឋកិច្ចពិសេស។

ទី៧ បង្កើត និងអនុវត្ត**ផែនការសកម្មភាពថ្នាក់ជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស** ដោយសហការជាមួយសង្គមស៊ីវិលដើម្បីផ្សព្វផ្សាយ និងអនុវត្តគោលការណ៍ណែនាំ។

## អនុសាសន៍សម្រាប់សហគមន៍ធុរកិច្ច

ទី៨ ធ្វើ**ការត្រួតពិនិត្យដ៏ត្រឹមត្រូវ** មុនពេលចាប់ផ្តើមប្រតិបត្តិការណាមួយនៅក្នុងប្រទេសកម្ពុជា ដោយយោងតាមគោលការណ៍ ១៥ ១៧ និង១៨ នៃគោលការណ៍ណែនាំ។

ទី៩ **អនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម** ដោយចែករំលែកលទ្ធផលដល់សហគមន៍រងផលប៉ះពាល់និងសាធារណជនឱ្យទាន់ពេលវេលានិងមាន**យន្តការតាមដានការអនុវត្តរបស់ខ្លួន**ដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដូចជាគោលការណ៍ទី១៨ នៃគោលការណ៍ណែនាំ និងអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ អាយ.អេហ្វ.ស៊ី។

ទី១០ កំណត់អត្តសញ្ញាណសហគមន៍រងផលប៉ះពាល់ធានា**ការប្រឹក្សាយោបល់ប្រកបដោយអត្ថន័យ** និងគោរពតាមគោលការណ៍នៃ**ការយល់ព្រមដោយពេញចិត្ត ដោយប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ** ព្រមទាំង**ចូលរួម**ជាមួយសហគមន៍រងផលប៉ះពាល់ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធនឹងការដោះស្រាយវិវាទដីធ្លីនេះ។

ទី១១ **ដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សទាំងអស់** និងប្រាកដថាដំណោះស្រាយនោះបំពេញតាមលក្ខខណ្ឌតម្រូវអំពីប្រសិទ្ធភាពនៃគោលការណ៍៣១ នៃគោលការណ៍ណែនាំ។

## អនុសាសន៍សម្រាប់អង្គការសង្គមស៊ីវិល

ទី១២ **បន្តតាមដានយ៉ាងសកម្ម**លើវិវាទដីធ្លី និងរក្សាទុកកំណត់ត្រាករណីប៉ះពាល់នីមួយៗ ព្រមទាំងករណីរំលោភបំពានសិទ្ធិមនុស្ស និង**រាយការណ៍ជាសាធារណៈអំពីដំណើរការដោះស្រាយវិវាទដីធ្លី**ផងដែរ។

ទី១៣ **លើកទឹកចិត្តនិងសម្របសម្រួលកិច្ចពិភាក្សា** រវាងសហគមន៍រងផលប៉ះពាល់ តួអង្គក្រុមហ៊ុន និងអាជ្ញាធររដ្ឋដើម្បីពិភាក្សាពីដំណោះស្រាយវិវាទដីធ្លីដោយយោងតាមគោលការណ៍ណែនាំ។

ទី១៤ **បង្កើនការយល់ដឹងអំពីបញ្ហាធុរកិច្ច និងសិទ្ធិមនុស្ស** ដល់ភាគីពាក់ព័ន្ធទាំងអស់រួមមានរាជរដ្ឋាភិបាល តួអង្គក្រុមហ៊ុន សហគមន៍ និងអង្គការសង្គមស៊ីវិល។

ទី១៥ ធានាថា សហគមន៍ទទួលបានដំណឹង និងដឹងអំពី**ដំណើរការដែលជានាំទៅការទទួលបានសំណងប្រកបដោយប្រសិទ្ធភាព តាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ**។